ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# ទីស្ដីការគណៈរដ្ឋមន្ត្រី

# ក្រុមប្រឹក្សាជាតិភាសាខ្មែរ (ក.ជ.ភ.ខ.)

# គណៈកម្មការភាសាវិទ្យា

# សៀវភៅវេយ្យាករណ៍ភាសាខ្មែរ

កម្រិតមធ្យម សម្រាប់ការប្រើប្រាស់ទូទៅ

អាសយដ្ឋាន៖ មហាវិថីសហព័ន្ធរុស្ស៊ី, សង្កាត់កាកាប, ខណ្ឌពោធិ៍សែនជ័យ, រាជធានីភ្នំពេញ
ទូរសព្ទដៃ៖ (៨៥៥) ១២ ៩១១ ៣៥៧ / (៨៥៥) ១២ ៩០៦ ៥៨៥, អ៊ីមែល៖ info@nckl.gov.kh, គេហទំព័រ៖ www.nckl.gov.kh

ឆ្នាំ២០១៨

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

# ទីស្ដីការគណៈរដ្ឋមន្ត្រី
# ក្រុមប្រឹក្សាជាតិភាសាខ្មែរ (ក.ជ.ភ.ខ.)
# គណៈកម្មការភាសាវិទ្យា

# សៀវភៅវេយ្យាករណ៍ភាសាខ្មែរ

កម្រិតមធ្យម សម្រាប់ការប្រើប្រាស់ទូទៅ

អាសយដ្ឋាន៖ មហាវិថីសហព័ន្ធរុស្ស៊ី, សង្កាត់កាកាប, ខណ្ឌពោធិ៍សែនជ័យ, រាជធានីភ្នំពេញ
ទូរសព្ទដៃ៖ (៨៥៥) ១២ ៩១១ ៣៥៧ / (៨៥៥) ១២ ៩០៦ ៥៨៥, អ៊ីមែល៖ info@nckl.gov.kh, គេហទំព័រ៖ www.nckl.gov.kh

ឆ្នាំ២០១៨

# អារម្ភកថា

វេយ្យាករណ៍ជាក្បួនច្បាប់នៃភាសា។ភាសាមួយមានអត្ថិភាពបានអាស្រ័យដោយវេយ្យាករណ៍ ដែលជានានូវវចនាសម្ព័ន្ធរៀបរយ មួយនាំឱ្យមានឯកភាពក្នុងការប្រើប្រាស់។ យ៉ាងណាមិញ ភាសាខ្មែរដែលត្រូវបានប្រើប្រាស់អស់កាលដ៏យូរលង់រហូតដល់ពេលនេះ ក៏អនុលោមតាមវេយ្យាករណ៍របស់ខ្លួនដែរ។

ក្នុងពេលកន្លងមក មានសៀវភៅវេយ្យាករណ៍ជាច្រើនបានបោះពុម្ពផ្សាយដោយផ្អែកលើទស្សនៈរបស់អ្នកនិពន្ធរៀងៗខ្លួន។

ដោយឡែក សៀវភៅវេយ្យាករណ៍ខ្មែរនេះ ត្រូវបានចងក្រងឡើងដោយគណៈកម្មការភាសាវិទ្យានៃក្រុមប្រឹក្សាជាតិភាសាខ្មែរ ប្រកបដោយស្មារតីឯកភាពនិងទទួលខុសត្រូវ។

ទោះជាយ៉ាងណាក៏ដោយ ក៏ចំណុចខ្វះខាតអាចនឹងកើតមានជាយថាហេតុ។ ហេតុនេះ ក្រុមប្រឹក្សាជាតិភាសាខ្មែររង់ចាំទទួលនូវមតិរិះគន់ស្ថាបនាពីប្រិយមិត្តអ្នកអានដោយក្តីសោមនស្សបំផុត។

ក្រុមប្រឹក្សាជាតិភាសាខ្មែរ សូមថ្លែងអំណរគុណទុកជាមុននូវកំណែលម្អពីសំណាក់មិត្តអ្នកអាន ហើយសង្ឃឹមថា សៀវភៅនេះអាចជាពន្លឺមួយបន្ថែមទៀតលើវេយ្យាករណ៍ភាសាខ្មែរយើង។

រាជធានីភ្នំពេញ ថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១៨

**ប្រធានក្រុមប្រឹក្សាជាតិភាសាខ្មែរ**

**បណ្ឌិត ហ៊ាន សុខុម**

**រៀបរៀងចប់នៅដើមខែវិច្ឆិកា ឆ្នាំ២០១៦**
**ដោយសមាជិកគណៈកម្មការភាសាវិទ្យានៃក្រុមប្រឹក្សាជាតិភាសាខ្មែរ**
**ដែលមានសមាសភាពដូចខាងក្រោម៖**

| | |
|---|---|
| ១- ឯ.ឧ.បណ្ឌិតសភាចារ្យ **ព្រុំ ម៉ល់** | ប្រធាន |
| ២- ឯ.ឧ.បណ្ឌិត **ម៉ៅ សុក្កន** | អនុប្រធាន |
| ៣- ឯ.ឧ.បណ្ឌិត **ច័ន្ទ សំណព្វ** | សមាជិក |
| ៤- ឯ.ឧ. **សូ មុយឃៀង** | សមាជិក |
| ៥- ឯ.ឧ. **ដួង រតនា** | សមាជិក |
| ៦- លោក **សឹង ផុស** | សមាជិក |
| ៧- ឯ.ឧ.បណ្ឌិត **នៅ ស៊ុន** | សមាជិក |
| ៨- ឯ.ឧ.បណ្ឌិត **ជួរ គារី** | សមាជិក |
| ៩- លោក **ធន់ ហ៊ិន** | សមាជិក |
| ១០- បណ្ឌិត **ប៊ី សុខគង់** | សមាជិក |
| ១១- បណ្ឌិត **មាឃ បូរ៉ា** | សមាជិក |
| ១២- លោក **អែម ឧត្តម** | សមាជិក |
| ១៣- លោកស្រី **អ៊ឹង ម៉ាល័យ** | សមាជិក |
| ១៤- លោក **កែវ លីណែត** | សមាជិក |

# មាតិកា

## ផ្នែកទី១
## *សូរ សទ្ទតា និង អក្សរខ្មែរ*


**សញ្ញាណទូទៅនៃសូរវិទ្យា**........................................ ១

១- សញ្ញាណទូទៅនៃសូរវិទ្យាមូលដ្ឋាន........................................១

២- សញ្ញាណទូទៅនៃសូរវិទ្យាអនុវត្ត........................................ ២

សូរវិទ្យាបន្លឺ ........................................ ៣

**I- សូរព្យញ្ជនៈខ្មែរ**........................................៤

១- ចំណែកថ្នាក់សូរព្យញ្ជនៈជាសូរមុខជៈឬសូរមោត់និងសូរនាសិកជៈឬសូរច្រមុះ............៤

២- ចំណែកថ្នាក់សូរព្យញ្ជនៈតាមទីបន្លឺ........................................៤

២.១- សូរព្យញ្ជនៈបបូរមាត់ ........................................៤

២.២- សូរព្យញ្ជនៈបបូរមាត់ត្រដុស ........................................៥

២.៣- សូរព្យញ្ជនៈធ្មេញ........................................៥

២.៤- សូរព្យញ្ជនៈជើងធ្មេញ ........................................៥

២.៥- សូរព្យញ្ជនៈក្រអូម ........................................៥

២.៦- សូរព្យញ្ជនៈរនាំងក្រអូម ........................................៥

២.៧- សូរព្យញ្ជនៈដើមក ........................................៥

២.៨- សូរព្យញ្ជនៈចន្លោះខ្សែសំឡេងឬសូរព្យញ្ជនៈគន្លាក់កណ្ឋ ..........................៥
៣- ចំណែកថ្នាក់សូរព្យញ្ជនៈតាមរង្វះខ្យល់ឬរបៀបបន្លឺ ..........................................៦
៣.១- សូរព្យញ្ជនៈស្ទះឬសូរផ្ទុះ .....................................................................៦
៣.២- សូរព្យញ្ជនៈត្រដុស .........................................................................៦
៣.៣- សូរព្យញ្ជនៈលំហូរ .......................................................................... ៧
៤- ចំណែកថ្នាក់សូរព្យញ្ជនៈជាសូរឃោសៈឬសូរឮនិងជាសូរអឃោសៈឬសូរថ្លង់............. ៧
៤.១- សូរព្យញ្ជនៈឃោសៈឬសូរឮ ................................................................ ៧
៤.២- សូរព្យញ្ជនៈអឃោសៈឬសូរថ្លង់ .......................................................... ៧
**II- សូរស្រៈខ្មែរ** .............................................................................................៨
១- ចំណែកថ្នាក់សូរស្រៈតាមចលនាអណ្ដាត(លក្ខណៈទូទៅ)................................ ១០
២- ចំណែកថ្នាក់ជាសូរស្រៈវែងនិងជាសូរស្រៈខ្លី ................................................. ១០
៣- ចំណែកថ្នាក់សូរស្រៈតាមភាពបិទបើក ......................................................... ១០
៤- ចំណែកថ្នាក់ស្រៈតាមចលនាមុខក្រោយនិងតាមចលនាលើក្រោម......................... ១១
៥- ចំណែកថ្នាក់សូរស្រៈទោលនិងសូរស្រៈល្បាយ ............................................ ១២
**III- សទ្ទតាព្យញ្ជនៈនិងសទ្ទតាស្រៈ** ......................................................... ១៣
១- ការស្វែងយល់អំពីសទ្ទតាខ្មែរ ....................................................................... ១៣
២- ការកត់ត្រាសទ្ទតាព្យញ្ជនៈនិងសទ្ទតាស្រៈខ្មែរដោយអក្សរខ្មែរ .............................. ១៥

២.១- ការកត់ត្រាសទ្ទតាព្យញ្ជនៈ ........ ១៥

២.២- ការកត់ត្រាសទ្ទតាស្រៈ ........ ១៦

២.២.១- ការកត់ត្រាសទ្ទតាស្រៈទោល ........ ១៦

២.២.២- ការកត់ត្រាសទ្ទតាស្រៈល្បាយ ........ ១៨

IV- **អក្សរខ្មែររៀបតាមទម្លាប់** ........ ២០

១- ព្យញ្ជនៈ ........ ២០

២- ស្រៈ ........ ២១

២.១- ស្រៈនិស្ស័យ ........ ២១

២.២- ស្រៈពេញតួ ........ ២១

V- **ព្យាង្គ** ........ ២១

១- ទម្រង់ព្យាង្គខ្មែរ ........ ២១

២- ប្រភេទព្យាង្គខ្មែរ ........ ២២

VI- **វណ្ណយុត្តិ** ........ ២២

១- សញ្ញាបន្តក់ ........ ២២

២- សញ្ញាមូសិកទន្ត ........ ២៣

៣- សញ្ញាត្រីសព្ទ ........ ២៤

៤- សំយោគសញ្ញា ........ ២៤

៥- សញ្ញាទណ្ឌឃាត ..................................................................................................២៥

៦- សញ្ញារបាទ ........................................................................................................២៥

៧- សញ្ញាវិសជ្ជនីឬសញ្ញារះមុខ ..............................................................................២៥

៨- សញ្ញានិគ្គហិតឬសញ្ញាដំលើ..............................................................................២៦

៩- សញ្ញាយុគលពិន្ទុឬសញ្ញាចុចពីរ ........................................................................២៦

# ផ្នែកទី២

# វចនវិទ្យា

បញ្ញត្តិមូលដ្ឋាន ........................................................................................................ ២៧

១- វចនសព្ទ................................................................................................................ ២៧

២- វចនប្រភេទ ........................................................................................................... ២៧

I- **ការបង្កើតពាក្យ**............................................................................................... ២៧

១- វិធីកម្លាយ.............................................................................................................. ២៧

០- ផ្នត់និងកាឡារូប  ....................................................................................................... ២៧

០.១- ផ្នត់ដើម ........................................................................................................២៨

០.២- ផ្នត់ដែក.........................................................................................................២៨

០.៣- កាឡារូប.........................................................................................................២៨

១.១- ពាក្យកម្លាយសម្គាល់កិរិយាហេតុ ....................................................................២៨

១.១.១- កិរិយាហេតុកម្លាយចេញពីកិរិយាសកម្មឬអកម្មដែលកើតពីព្យញ្ជនៈទោល.២៨

១.១.២-កិរិយាហេតុកម្លាយចេញពីកិរិយាសព្ទដែលកើតពីកន្សោមព្យញ្ជនៈ(ព្យញ្ជនៈផ្សំ)៣២

១.២- ពាក្យកម្លាយសម្គាល់លទ្ធផលឬភាព ...................................................... ៣៥

១.៣- ពាក្យកម្លាយសម្គាល់ឧបករណ៍ .......................................................................៤០

១.៣.១- ពាក្យកម្លាយសម្គាល់ឧបករណ៍ដែលកើតពីព្យញ្ជនៈទោល.....................៤០

១.៣.២- ពាក្យកម្លាយសម្គាល់ឧបករណ៍ដែលកើតពីកន្សោមព្យញ្ជនៈ(ព្យញ្ជនៈផ្សំ)៤១

១.៤- ពាក្យកម្លាយសម្គាល់ភ្នាក់ងារឬនាមការក៍ ............................................ ៤៣

១.៥- ពាក្យកម្លាយសម្គាល់ស្វ័យកម្ម......................................................................៤៥

១.៦- ពាក្យកម្លាយសម្គាល់ន័យទ្រគោះ.....................................................................៤៦

១.៧- ពាក្យកម្លាយសម្គាល់ទង្វើផ្ទួន ......................................................................៤៦

២- វិធីស្ទើរកម្លាយនិងវិធីស្ទើរបន្សំ .................................................................................៤៨

២.១- វិធីស្ទើរកម្លាយ..............................................................................................៤៨

២.២- វិធីស្ទើរបន្សំ ...............................................................................................៥០

៣- វិធីបន្សំ.............................................................................................................. ៥៣

៣.១- ទម្រង់នៃនាមបន្សំ ................................................................................... ៥៣

៣.២- ទម្រង់នៃគុណនាមបន្សំ ................................................................................៥៥

៣.៣- ទម្រង់នៃកិរិយាសព្ទបន្សំ ..............................................................................៥៦

៣.៤- ទម្រង់នៃគុណកិរិយាបន្សំ ............................................................................៥៧

៣.៥- ទម្រង់នៃធ្នាក់បន្សំ .......................................................................................៥៧

៤- វិធីសមាស.................................................................................................៥៨
៤.១- ពាក្យសមាសដែលគ្មានប្រើសន្ធិសម្រាប់តភ្ជាប់ ....................................៥៨
៤.២- ពាក្យសមាសដែលមានប្រើសន្ធិសម្រាប់តភ្ជាប់ .....................................៥៨
៥- វិធីរូប-សទ្ទតា...............................................................................................៥៩
៥.១- ពាក្យកាត់................................................................................................៥៩
៥.២- ពាក្យកន្សោមកាត់....................................................................................៦០
៥.៣- ពាក្យអក្សរកាត់ .......................................................................................៦០
៥.៤- ពាក្យកាត់កម្លាយ .....................................................................................៦០
៥.៥- ពាក្យកាត់បូក...........................................................................................៦១
II- **ប្រភេទពាក្យ** ..........................................................................................៦១
១- នាម.. ..........................................................................................................៦១
១.១- និយមន័យ...............................................................................................៦១
១.២- ប្រភេទរបស់នាម .....................................................................................៦១
១.២.១- នាមសាធារណ៍និងនាមអសាធារណ៍ ...................................................៦១
១.២.២- នាមរូបីនិងនាមអរូបី ........................................................................៦១
១.២.៣- នាមជីវចលនិងនាមអជីវចល ...............................................................៦២
១.៣- មុខងាររបស់នាមក្នុងសម្ព័ន្ធ ......................................................................៦២
២- សព្វនាម ......................................................................................................៦៣

២.១- និយមន័យ .......... ៦៣

២.២- ប្រភេទផ្សេងៗនៃសព្វនាម .......... ៦៣

២.២.១- សព្វនាមបុរិសៈ .......... ៦៣

២.២.២- សព្វនាមចង្អុល .......... ៦៤

២.២.៣- សព្វនាមសំណួរ .......... ៦៥

២.២.៤- សព្វនាមឈ្នាប់ .......... ៦៥

២.២.៥- សព្វនាមមិនច្បាស់ .......... ៦៦

៣- គុណនាម .......... ៦៧

៣.១- គុណនាមប្រក្រតី .......... ៦៧

៣.២- គុណនាមកំណត់ .......... ៦៨

៣.២.១- គុណនាមចង្អុល .......... ៦៨

៣.២.២- គុណនាមសំណួរ .......... ៦៨

៣.២.៣- គុណនាមមិនច្បាស់ .......... ៦៩

៣.២.៤- គុណនាមចំនួន .......... ៦៩

៤- កិរិយាសព្ទ .......... ៧០

៤.១- និយមន័យ .......... ៧០

៤.២- ប្រភេទផ្សេងៗនៃកិរិយាសព្ទ .......... ៧០

៤.២.១- កិរិយាអកម្ម .......... ៧០

៤.២.២- កិរិយាសកម្ម .......................................................................... ៧០

៥- គុណកិរិយា .......................................................................... ៧១

៥.១- និយមន័យ .......................................................................... ៧១

៥.២- ប្រភេទផ្សេងៗនៃគុណកិរិយា .......................................................................... ៧២

៦- ធ្នាក់. .......................................................................... ៧៣

៦.១- និយមន័យ .......................................................................... ៧៣

៦.២- ប្រភេទនៃធ្នាក់ .......................................................................... ៧៣

៧- ឈ្នាប់ .......................................................................... ៧៤

៧.១- និយមន័យ .......................................................................... ៧៤

៧.២- ប្រភេទផ្សេងៗនៃឈ្នាប់ .......................................................................... ៧៤

៨- ឧទានសព្ទ .......................................................................... ៧៥

## ផ្នែកទី៣
## សម្ព័ន្ធវិទ្យា

បញ្ញត្តិមូលដ្ឋាន .......................................................................... ៧៧

១- សម្ព័ន្ធវិទ្យា .......................................................................... ៧៧

២- កន្សោមពាក្យ .......................................................................... ៧៧

៣- ល្បះ. .......................................................................... ៧៧

**I- ល្បះ** .......................................................................... ៧៧

១- ប្រភេទល្បះ ........................................ ៧៧
១.១- ល្បះប្រកាស ........................................ ៧៨
១.២- ល្បះសំណួរ ........................................ ៧៨
១.៣- ល្បះបញ្ជា ........................................ ៧៨
១.៤- ល្បះឧទាន ........................................ ៧៩
២- ទម្រង់ល្បះ ........................................ ៧៩
២.១- ទម្រង់វិជ្ជមានឬអវិជ្ជមាន ........................................ ៧៩
២.១.១- ទម្រង់វិជ្ជមាន ........................................ ៧៩
២.១.២- ទម្រង់អវិជ្ជមាន ........................................ ៨០
២.២- ទម្រង់មិនសង្កត់បញ្ជាក់ឬសង្កត់បញ្ជាក់ ........................................ ៨១
២.២.១- ទម្រង់មិនសង្កត់បញ្ជាក់ ........................................ ៨១
២.២.២- ទម្រង់សង្កត់បញ្ជាក់ ........................................ ៨១
២.៣- ទម្រង់កត្តុវាចកៈឬកម្មវាចកៈ ........................................ ៨៤
២.៣.១- ទម្រង់កត្តុវាចកៈ ........................................ ៨៤
២.៣.២- ទម្រង់កម្មវាចកៈ ........................................ ៨៤
៣- បែបនៃល្បះ ........................................ ៨៥
៣.១- ល្បះទោល ........................................ ៨៥
៣.២- ល្បះផ្សំ ........................................ ៨៦

៣.៣- ល្បះក្រង ........................................................................................ ៨៦

៤- មុខងារនៃកន្សោមពាក្យក្នុងល្បះនិងមុខងារនៃពាក្យឬកន្សោមពាក្យក្នុងកន្សោមពាក្យ...៨៦

៤.១-មុខងារនៃកន្សោមពាក្យក្នុងល្បះ .............................................................. ៨៧

៤.២- មុខងារនៃពាក្យឬកន្សោមពាក្យក្នុងកន្សោមពាក្យ .................................. ៨៧

៤.២.១- មុខងារនៃពាក្យឬកន្សោមពាក្យក្នុងកន្សោមនាមប្រធាន ........................ ៨៧

៤.២.២- មុខងារនៃពាក្យឬកន្សោមពាក្យក្នុងកន្សោមកិរិយាប្រណាប់ប្រធាន......... ៨៧

៤.២.៣- មុខងារកន្សោមមានធ្នាក់ ឯករាជ្យពីកន្សោមកិរិយាប្រណាប់ប្រធាន ....... ៨៨

II- **សញ្ញាល្បះ** ........................................................................................ ៨៩

១- សញ្ញាខណ្ឌ ........................................................................................ ៨៩

២- សញ្ញាខណ្ឌចប់ .................................................................................. ៨៩

៣- ដកឃ្លាឬដំណកឃ្លា ............................................................................ ៨៩

៤- បេយ្យាលៈ ........................................................................................ ៩០

៥- ដំពីរ . ............................................................................................. ៩០

៦- វង់ធ្មេញសញ្ញាឬគំនូស ......................................................................... ៩១

៧- វង់ក្រចក ............................................................................................ ៩២

៨- ចំណុចមួយ ........................................................................................ ៩២

៩- ចំណុចពីរ ........................................................................................... ៩២

១០- ចំណុចបី .......................................................................................... ៩៣

១១- ចំណុចបីក្នុងវង់ក្រចក ........................................................................ ៩៣

១២- ក្បៀស ........................................................................................... ៩៣

១៣- សញ្ញាសួរ ......................................................................................... ៩៤

១៤- សញ្ញាឧទាន ...................................................................................... ៩៤

១៥- អព្គន្តរៈ ........................................................................................... ៩៤

១៦- គំនូសទ្រេត ....................................................................................... ៩៥

**III- សញ្ញាគ្រាវល្បះ** ............................................................................. ៩៦

១- សញ្ញាស្មើ ........................................................................................... ៩៦

២- សញ្ញា«ទៅជាឬធំជាង» ........................................................................ ៩៧

៣- សញ្ញា«មកពីឬតូចជាង» ....................................................................... ៩៧

៤- សញ្ញា«ផ្ទុយពី...ឬខុសពី...» ................................................................. ៩៧

គន្ថនិទ្ទេស ............................................................................................. ៩៩

# ផ្នែកទី១

# *ស្ករ សទ្ទតា និង អក្សរខ្មែរ*

# សញ្ញាណទូទៅនៃសូរវិទ្យា

លោក ទ្រូបេតស្កយ[៩] (Troubetzkoy) ភាសាវិទូជាតិរុស្ស៊ី ជាអ្នកនិពន្ធស្នាដៃភាសាវិទ្យាដ៏ល្បីមួយឈ្មោះថា «គោលការណ៍សទ្ទតាវិទ្យា» (Principles de phonologie) គុឱ្យនិយមន័យសូរវិទ្យាថា ជាវិទ្យាសាស្ត្ររបស់សូរទាំងឡាយដែលជាផ្នែកមួយនៃរូបធាតុ(matière)របស់សកម្ម ភាពសំដីរបស់មនុស្ស។

សូរវិទ្យា ជាទូទៅ សិក្សាពីកន្សោមលទ្ធភាពសូរភាសារបស់មនុស្ស (សិក្សាតែសូរភាសាមនុស្ស) តាមរយៈភាសាធម្មជាតិ។ម្យ៉ាងទៀត កាលណាគេសិក្សាពីសូរវិទ្យា គេត្រូវតែចែកឱ្យបានជ្រះស្រឡះរវាងសូរនិងសញ្ញាអក្សរ ដោយហេតុថា សញ្ញាអក្សរមួយមិនអាចជាតំណាងសូរមួយឬក៏សូរមួយមិនអាចតាងដោយតួអក្សរមួយបានគ្រប់ពេលនោះឡើយ បានន័យថា ចួនកាលសញ្ញាមួយអាចជាតំណាងសូរពីរឬក៏ច្រើន ឬ សូរពីរអាចតាងដោយសញ្ញាតែមួយក៏មាន, ឧ. ក្នុងភាសាខ្មែរ ក្នុងពាក្យ [kɒ:] យើងឃើញមានសញ្ញា "ក" (គេសរសេរបែបនេះ ដោយគេសន្មត ថាស្រៈ "អ" គ្មានរូប ហើយកប់ក្នុងតួព្យញ្ជនៈ "ក") តែមានសូរពីរគឺ សូរ [k] និង សូរស្រៈ [ɒ:]។ ក្នុងពាក្យ "កក" គេឃើញមានសញ្ញាពីរ តែមានសូរបី : [k]+[ɒ:]+[ʔ]។ ក្នុងពាក្យ "សំដី" មាន សញ្ញាបួន មានសូរប្រាំមួយ : [s]+[ɒ]+[m]+[d]+[e]+[j]។ ដូចគ្នាដែរ ក្នុងភាសាបារាំង ពាក្យ "temps" មានសញ្ញាប្រាំ តែមានសូរពីរ [tã] ពាក្យ "peu" មានសញ្ញាបី តែមានសូរពីរ [pø] ជាដើម។

## ១- សញ្ញាណទូទៅនៃសូរវិទ្យាមូលដ្ឋាន

សូរវិទ្យាមូលដ្ឋានជាសូរវិទ្យាដែលផ្តល់សញ្ញាណខ្លះៗដើម្បីឱ្យយើងអាចយល់សូរវិទ្យាឯទៀត។ សូរវិទ្យាអាគូស្ទិកសិក្សាពីការកកើតសូរដោយកម្លាំងមួយដែលបានប៉ះទង្គិចជាមួយវត្ថុអ្វីមួយ និង បានធ្វើឱ្យវត្ថុនោះមានលំញ័រ។ លំញ័រនោះបានក្លាយទៅជារលក ហើយ រលកនោះក៏រសាត់ទៅប៉ះនឹងត្រចៀកអ្នកស្តាប់។ សូរវិទ្យានេះជួយឱ្យយើងយល់ថា ហេតុអ្វីក៏ខ្យល់ដែលចេញពីសួតអាចបង្កើតបានជាសូរក្នុងសូរវិទ្យាបន្លឺ យល់អំពីការលើកដាក់សំឡេងក្នុងសូរសៀងវិទ្យាដែលមានសូរទាបឬសូរខ្ពស់ទៅតាមចង្វាក់នៃល្បះ។ល។ សូរវិទ្យាបន្លឺឬសូរវិទ្យាសរីរសាស្ត្រជា

---

[៩] Troubetzkoy Nicolaï Sergueevitch, Principes de phonologie, Klincksieck, Paris 1976.

មូលដ្ឋានដ៏សំខាន់ ដើម្បីជួយយើងឱ្យយល់អំពីសូរដែលត្រូវបានបន្លឺឡើងដោយប្រដាប់ដកដង្ហើម (ប្រើជាប្រដាប់បន្លឺសូរ)។ សូរវិទ្យាបន្សំជាតុបង្ហាញអំពីឥទ្ធិពលរវាងសូរក្នុងករណីខ្លះ កាលណាសូរទាំងនោះត្រូវបានគេផ្គុំជាមួយគ្នាដូច ការសម្របសូរ ការប្រើអាគម ការប្រើសន្ធិក្នុងភាសាខ្លះជាដើម។

ការពិសោធដែលប្រើអូស៊ីឡូក្រាម(oscillogramme) ស្ប៊ិចតូក្រាម(spectogramme) សូណូក្រាម(sonogramme) ជាជំនួយដល់សូរវិទ្យាអាគូស្ទិក ដើម្បីឱ្យអ្នកសូរវិទ្យាយល់អំពីលក្ខណៈអាគូស្ទិកផ្សេងៗនៃសូរ។

ប្រដាប់ពិសោធន៍ដែលប្រើគីម៉ូក្រាហ្វ(kymographe)សម្រាប់ពិនិត្យមើលវត្តមានឬអវត្តមាននៃលំញ័រខ្សែសំឡេង, ប៉ាឡាតូក្រាហ្វ (palatographe) សម្រាប់ពិនិត្យមើលកន្លែងដែល អណ្ដាតទៅប៉ះនឹងក្រអូម, វិទ្យុលេខន៍ (radiographie) សម្រាប់វាស់បំណើកមាត់ (តូចឬធំទៅតាមប្រភេទនៃសូរ) ជាបច្ចេកវិទ្យាដែលជួយដល់សូរវិទ្យាបន្លឺដែលគេទទួលស្គាល់ថាជាបច្ចេកវិទ្យាដ៏មានប្រសិទ្ធភាពនៅសករាជមុនសករាជអេឡិចត្រូនិក។ ឧបករណ៍ទាំងនេះជួយឱ្យយើងយល់អំពីទីបន្លឺសូរ របៀបបន្លឺសូរ ផ្លូវខ្យល់ចេញពីសួតមកក្រៅ (តាមមាត់ឬតាមច្រមុះ) លំញ័រខ្សែសំឡេង (ញ័រឬមិនញ័រ)។

នៅពេលបច្ចុប្បន្ន គេប្រើប្រអប់អេឡិចត្រូនិក(ផ្គុំជាមួយកុំព្យូទ័រនិងមីក្រូហ្វូន) ដែលមានកម្មវិធីរៀបចំឡើងដើម្បីថតយកលក្ខណៈអាគូស្ទិកផ្សេងៗនៃសូរ ដូចជាឆាយាកូត(ស្នាមស្ប៊ិចនៃសូរ) និង លក្ខណៈអាគូស្ទិកឯទៀត ព្រមទាំងបន្ទាត់បង្ហាញការឡើងចុះនៃកម្ពស់របស់សូរក្នុងការលើកដាក់សំឡេង កាលណាយើងអានល្បះ ផងទៀត។

## ២- សញ្ញាណទូទៅនៃសូរវិទ្យាអនុវត្ត

គេអាចផ្អែកលើសូរវិទ្យាមូលដ្ឋានដើម្បីសិក្សាធ្វើការប្រៀបធៀបសូររវាងភាសាពីរឬក៏ច្រើន។ ការប្រៀបធៀបអាចធ្វើឡើងរវាងសូរនៃភាសាបរទេសឬរវាងសូរនៃភាសាកណ្ដាលនិងសូរនៃការនិយាយស្ដីរបស់អ្នករស់នៅតាមតំបន់(dialecte) ហៅ«ទេសយោបាយ»[២]។ សូរវិទ្យាប្រវត្តិសាស្ត្រដែលសិក្សាពីការវិវត្តសូរភាសាក្នុងចន្លោះប្រវត្តិសាស្ត្រសង្គមក៏ជាការអនុវត្តសូរវិទ្យាមូលដ្ឋានដែរ។

[២] «ទេសយោបាយ» នេះ ជាបច្ចេកសព្ទរបស់បណ្ឌិត ព្រុំ ម៉ល់ : ***មូលដ្ឋាននៃសង្គមភាសាវិទ្យា***, ផ្សាយចេញលើកទី ៤, ភ្នំពេញ, ២០១៣, ទំព័រ១២។

# សូរវិទ្យាបន្លឺ

ការសិក្សាសូរវិទ្យារបស់យើងនៅពេលនេះ គឺផ្តោតជាសំខាន់ទៅលើសូរវិទ្យាបន្លឺ។ សូរវិទ្យាបន្លឺហៅឈ្មោះសូរដោយផ្អែកលើឈ្មោះចំណែកផ្សេងៗរបស់ប្រដាប់បន្លឺសូរ(ដែលជាប្រដាប់ដកដង្ហើម)។ អាស្រ័យហេតុនេះ យើងត្រូវបង្ហាញប្រដាប់បន្លឺសូរជាមុនសិន មុននឹងវិភាគសូរទៅតាមទីបន្លឺ តាមរង្វះខ្យល់ឬរបៀបបន្លឺ។ល។

## ប្រដាប់ដកដង្ហើម ប្រើជាប្រដាប់បន្លឺសូរ

(គំនូរប្រៀបធៀបការបន្លឺសូរនាសិកជៈនិងសូរមុខជៈ)




រូបតាងទី១ : ការបន្លឺសូរនាសិកជៈ (សូរច្រមុះ)

(ក្នុងការបន្លឺសូរនាសិកជៈ រនាំងក្រអូមត្រូវធ្លាក់ចុះមកក្រោមដើម្បីបើកផ្លូវច្រមុះឱ្យខ្យល់ដែលចេញពីសួតអាចចេញតាមច្រមុះ)។

រូបតាងទី២ : ការបន្លឺសូរមុខជៈ (សូរមាត់)

(ក្នុងការបន្លឺសូរមុខជៈ រនាំងក្រអូមត្រូវឡើងទៅលើដើម្បីបិទផ្លូវច្រមុះកុំឱ្យខ្យល់ដែលចេញពីសួតអាចចេញតាមច្រមុះ)។

## I- **សូរព្យញ្ជនៈខ្មែរ**

សូរព្យញ្ជនៈកើតឡើងដោយសារការបិទឬការខិតជិតគ្នានៃប្រដាប់បន្លឺក្នុងគុហាមាត់និងគុហាច្រមុះ។

តាមការសិក្សាបែបអាគូស្ទិក គេមិនងាយចាប់សូរព្យញ្ជនៈ ជាពិសេស សូរព្យញ្ជនៈស្ទះ-អឃោសៈបានទេ ជាពិសេសទៅទៀត ក្នុងករណីដែលសូរព្យញ្ជនៈទាំងនោះផ្សំជាមួយសូរស្រៈ។ ទោះជាយ៉ាងនេះក៏ដោយ ក៏គេត្រូវតែជ្រើសយកស្រៈដែលមានសូរខ្លីជាងគេបំផុតមកផ្សំជាមួយសូរព្យញ្ជនៈ ដើម្បីឱ្យងាយស្រួលស្ដាប់នឹងត្រចៀក។ សូរស្រៈខ្លីបំផុតដែលគេនិយមប្រើគឺ [ə]។

### **១-ចំណែកថ្នាក់សូរព្យញ្ជនៈជាសូរមុខជៈឬសូរមាត់និងជាសូរនាសិកជៈឬសូរច្រមុះ**

សូរព្យញ្ជនៈមុខជៈឬសូរមាត់ជាសូរព្យញ្ជនៈដែលនៅពេលបន្លឺ រនាំងក្រអូមបិទផ្លូវច្រមុះ ដើម្បីឱ្យខ្យល់ចេញពីសួតមកក្រៅតែតាមមាត់។ ក្នុងភាសាខ្មែរ សូរព្យញ្ជនៈមុខជៈឬសូរមាត់មាន [p], [b], [w], [s], [k], [c], [t], [d], [j], [l], [r], [h] និង [ʔ]។ ចំណែកឯ សូរព្យញ្ជនៈនាសិកជៈឬសូរច្រមុះជាសូរព្យញ្ជនៈដែលនៅពេលបន្លឺ រនាំងក្រអូមបើកចំហដើម្បីឱ្យខ្យល់ចេញពីសួតមកក្រៅតាមច្រមុះផងនិងតាមមាត់ផង។សូរព្យញ្ជនៈនាសិកជៈឬសូរច្រមុះ មាន [ŋ], [ɲ], [m], [n]។

### **២- ចំណែកថ្នាក់សូរព្យញ្ជនៈតាមទីបន្លឺ**

ទីបន្លឺគឺជាចំណុចនៅផ្នែកខាងលើនៃគុហាមាត់(ធ្មេញលើ ជើងធ្មេញលើ ក្រអូម រនាំងក្រអូម ចុងរនាំងក្រអូមឬកន្ទើត...) ដែលអណ្ដាតធ្វើចលនាទៅប៉ះ ដើម្បីបង្កើតសូរណាមួយ។ តាមទីបន្លឺ គេចែកសូរព្យញ្ជនៈខ្មែរជាៈ

#### **២.១- សូរព្យញ្ជនៈបបូរមាត់**

សូរព្យញ្ជនៈបបូរមាត់ជាសូរព្យញ្ជនៈមួយពួកដែលក្នុងការបន្លឺ បបូរមាត់ក្រោមប៉ះនឹងបបូរមាត់លើទាំងស្រុង ហើយ លំហូរខ្យល់ចេញពីសួតមកក្រៅក៏បើកបបូរមាត់ឱ្យឃ្លាតចេញពីគ្នាវិញ។ ក្នុងភាសាខ្មែរ សូរព្យញ្ជនៈបបូរមាត់មាន [p], [b] និង [m]។

## ២.២- ស្វរព្យញ្ជនៈបបូរមាត់ត្រដុស

សូរព្យញ្ជនៈបបូរមាត់ត្រដុសជាសូរព្យញ្ជនៈដែលក្នុងការបន្លឺបបូរមាត់បើកចំហបន្តិច ដើម្បីឱ្យខ្យល់ដែលចេញពីសួតទៅត្រដុសនឹងបបូរមាត់ទាំងពីរ។ ក្នុងភាសាខ្មែរ សូរព្យញ្ជនៈបបូរមាត់ត្រដុសមាន [w]។

## ២.៣- ស្វរព្យញ្ជនៈធ្មេញ

សូរព្យញ្ជនៈធ្មេញជាសូរព្យញ្ជនៈមួយពួកដែលក្នុងការបន្លឺ ចុងអណ្ដាតទៅប៉ះនឹងធ្មេញឬគន្លាក់ជើងធ្មេញ។ ក្នុងភាសាខ្មែរ សូរព្យញ្ជនៈធ្មេញមាន [d], [t] និង [n] ។

## ២.៤- ស្វរព្យញ្ជនៈជើងធ្មេញ

សូរព្យញ្ជនៈជើងធ្មេញជាសូរព្យញ្ជនៈមួយពួកដែលក្នុងការបន្លឺ ចុងអណ្ដាតទៅជិតឬប៉ះនឹងជើងធ្មេញលើ។ ក្នុងភាសាខ្មែរ សូរព្យញ្ជនៈជើងធ្មេញមាន [s], [l] និង [r] ។

## ២.៥- ស្វរព្យញ្ជនៈក្រអូម

សូរព្យញ្ជនៈក្រអូមជាសូរព្យញ្ជនៈមួយពួកដែលក្នុងការបន្លឺ ខ្នងអណ្ដាតទៅជិតឬប៉ះនឹងផ្នែកនានានៃក្រអូម(ផ្នែកខាងមុខ ផ្នែកកណ្ដាល និង ផ្នែកខាងក្រោយ)។ ក្នុងភាសាខ្មែរ សូរព្យញ្ជនៈក្រអូមមាន [c], [ɲ] និង [j]។

## ២.៦- ស្វរព្យញ្ជនៈរនាំងក្រអូម

សូរព្យញ្ជនៈរនាំងក្រអូមជាសូរព្យញ្ជនៈមួយពួកដែលក្នុងការបន្លឺ ខ្នងអណ្ដាតទៅប៉ះនឹងរនាំងក្រអូម។ ក្នុងភាសាខ្មែរ សូរព្យញ្ជនៈរនាំងក្រអូមមាន [k] និង [ŋ]។

## ២.៧- ស្វរព្យញ្ជនៈដើមក

សូរព្យញ្ជនៈដើមកជាសូរព្យញ្ជនៈមួយពួកដែលក្នុងការបន្លឺ គល់អណ្ដាតខិតទៅជិតផ្ទៃខាងក្រោយនៃដើមក។ ក្នុងភាសាខ្មែរ សូរព្យញ្ជនៈដើមកមាន [h]។

## ២.៨- ស្វរព្យញ្ជនៈចន្លោះខ្សែសំឡេងឬស្វរព្យញ្ជនៈគន្លាក់កណ្ឋ

សូរព្យញ្ជនៈចន្លោះខ្សែសំឡេងឬសូរព្យញ្ជនៈគន្លាក់កណ្ឋ(consonne glottale) ជាសូរព្យញ្ជនៈដែលកើតឡើង កាលណាមានបំណើកមួយភ្លែតនៃគន្លាក់កណ្ឋ(glotte)។

**តារាងទី១ : ចំណែកថ្នាក់សូរព្យញ្ជនៈតាមទីបន្លឺ**

| សូរបបូរមាត់ | | សូរបបូរមាត់គ្រដុស | | សូរធ្មេញ | | សូរជើងធ្មេញ | | សូរក្រអូម | | សូររនាំងក្រអូម | | សូរដើមក | | សូរចន្លោះខ្សែសំឡេង | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| មុខជៈ | នាសិកជៈ | មុខជៈ | នាសិកជៈ | មុខជៈ | នាសិកជៈ | មុខជៈ | នាសិកជៈ | មុខជៈ | នាសិកជៈ | មុខជៈ | នាសិកជៈ | មុខជៈ | នាសិកជៈ | មុខជៈ | នាសិកជៈ |
| [p] [b] | [m] | | | [t] [d] | [n] | | | [c] | [ɲ] | [k] | [ŋ] | | | [ʔ] | |
| | | [w] | | | | [s] | | [j] | | | | [h] | | | |
| | | | | | | [l] [r] | | | | | | | | | |

## ៣- ចំណែកថ្នាក់សូរព្យញ្ជនៈតាមរន្ធខ្យល់ឬរបៀបបន្លឺ

របៀបបន្លឺ គឺជាបែបផែននៃលំហូរខ្យល់ដែលធ្វើឱ្យមានរង្វះខ្យល់ដំណាកដង្ហើមធំឬតូច។ តាមរបៀបបន្លឺ គេចែកសូរព្យញ្ជនៈខ្មែរជា៖

### ៣.១- សូរព្យញ្ជនៈស្ទះឬសូរផ្ទុះ

សូរព្យញ្ជនៈស្ទះឬសូរផ្ទុះជាសូរព្យញ្ជនៈដែលក្នុងពេលបន្លឺ ដំណើរខ្យល់ចេញពីសួតមកប៉ះខ្លាំងនឹងប្រដាប់បន្លឺសំឡេង បណ្តាលឱ្យមានបន្ទុះ។ ក្នុងភាសាខ្មែរ សូរព្យញ្ជនៈស្ទះឬសូរផ្ទុះមាន [k], [ŋ], [c], [ɲ], [d], [t], [n], [b], [p], [m] និង [ʔ]។

### ៣.២- សូរព្យញ្ជនៈគ្រដុស

សូរព្យញ្ជនៈគ្រដុសជាសូរព្យញ្ជនៈដែលក្នុងពេលបន្លឺ ដំណើរខ្យល់ចេញពីសួតគ្រដុសនឹងដើមក ផ្ទៃគុហាមាត់(ធ្មេញ អណ្តាត ក្រអូម) និង បបូរមាត់ ហើយ បង្កើតបានជាសូរគ្រដុស។ ក្នុងភាសាខ្មែរ សូរព្យញ្ជនៈគ្រដុសមាន [w], [s], [j] និង [h]។

### ៣.៣- សូរព្យញ្ជនៈលំហូរ

សូរព្យញ្ជនៈលំហូរជាសូរព្យញ្ជនៈដែលក្នុងពេលបន្លឺ ចុងអណ្ដាតប៉ះនឹងជើងធ្មេញលើដោយទុកចន្លោះឱ្យដំណើរខ្យល់ចេញពីសួតហូរចេញមកក្រៅ។ ក្នុងភាសាខ្មែរ សូរព្យញ្ជនៈលំហូរមាន [l]និង[r]។ ពិតមែនតែសូរព្យញ្ជនៈទាំងពីរនេះនៅក្នុងក្រុមជាមួយគ្នា ក៏ក្នុងការបន្លឺសូរព្យញ្ជនៈ [l] អណ្ដាតប៉ះនឹងជើងធ្មេញលើច្រើនជាងក្នុងការបន្លឺសូរព្យញ្ជនៈ[r] ដោយទុកចន្លោះសងខាងអណ្ដាតឱ្យដំណើរខ្យល់ចេញពីសួតបន្តដំណើរមកក្រៅ។ យើងហៅសូរព្យញ្ជនៈ[l]ថាសូរព្យញ្ជនៈលំហូរខាង(consonne latérale)។ ចំពោះសូរព្យញ្ជនៈ[r] វិញ ចុងអណ្ដាតប៉ះស្រាលនឹងជើងធ្មេញលើហើយរលាស់។ យើងហៅសូរព្យញ្ជនៈ[r]នេះថាសូរព្យញ្ជនៈលំហូរញ័រ(consonne vibrante)។ ក្នុងភាសាខ្លះគ្មាន [l] និង [r] ទេ។

**តារាងទី២ : ចំណែកថ្នាក់សូរព្យញ្ជនៈតាមរង្វះខ្យល់ចូរចៀវចន្លី**

| | មុខជំ: | ទាស៊ីកជំ: | មុខជំ: | ទាស៊ីកជំ: | មុខជំ: | ទាស៊ីកជំ: | មុខជំ: | ទាស៊ីកជំ: | មុខជំ: | ទាស៊ីកជំ: | មុខជំ: | ទាស៊ីកជំ: | មុខជំ: | ទាស៊ីកជំ: | មុខជំ: | ទាស៊ីកជំ: |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| សូរស្ទះឬសូរផ្ទុះ | [p] [b] | [m] | | | [t] [d] | [n] | | | [c] | [ɲ] | [k] | [ŋ] | | | [ʔ] | |
| សូរត្រដុស | | | [w] | | | | [s] | | [j] | | | | [h] | | | |
| សូរលំហូរ | | | | | | | [l] [r] | | | | | | | | | |

## ៤- ចំណែកថ្នាក់សូរព្យញ្ជនៈជាសូរឃោសៈឬសូរព្ធនិងជាសូរអឃោសៈឬសូរថ្លង់

### ៤.១- សូរព្យញ្ជនៈឃោសៈឬសូរព្ធ

សូរព្យញ្ជនៈឃោសៈឬសូរព្ធ កើតឡើងដោយសារការចូលរួមរបស់ខ្សែសំឡេង។ ក្នុងភាសាខ្មែរ សូរព្យញ្ជនៈឃោសៈឬសូរព្ធមាន [b], [m], [d], [n], [w], [l], [r], [j], [ɲ] និង[ŋ]។

### ៤.២- សូរព្យញ្ជនៈអឃោសៈឬសូរថ្លង់

សូរព្យញ្ជនៈអឃោសៈឬសូរថ្លង់ កើតឡើងដោយគ្មានការចូលរួមនៃខ្សែសំឡេង។ ក្នុងភាសាខ្មែរ សូរព្យញ្ជនៈអឃោសៈឬសូរថ្លង់មាន [p], [t], [s], [c], [k], [h] និង [ʔ]។

**តារាងទី៧ : ចំណែកថ្នាក់សូរព្យញ្ជនៈជាសូរអឃោសៈនិងជាសូរឃោសៈ**

| វង្វះខ្យល់ ឬ របៀបបន្លឺ \ ទីបន្លឺ | | | សូរបបូរមាត់ | | សូរបបូរមាត់ ត្រដុស | | សូរធ្មេញ | | សូរជើងធ្មេញ | | សូរក្រអូម | | សូរទាំងក្រអូម | | សូរដើមក | | សូរចន្លោះខ្សែសំឡេង | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| ព្យញ្ជនៈ | អឃោសៈឬឃោសៈ | | - | + | - | + | - | + | - | + | - | + | - | + | - | + | - | + |
| | សូរផ្ទុះ | នាសិកជៈ | | m | | | | n | | | | ɲ | | ŋ | | | | |
| | | មុខជៈ | p | b | | | t | d | | | c | | k | | | | ʔ | |
| | សូរត្រដុស | មុខជៈ | | | | w | | | s | | | j | | | h | | | |
| | សូរលំហូរ | មុខជៈ | | | | | | | | l r | | | | | | | | |

<u>កំណត់សម្គាល់</u> :

- សញ្ញា(-)សម្គាល់លក្ខណៈអឃោសៈនៃសូរព្យញ្ជនៈ
- សញ្ញា(+)សម្គាល់លក្ខណៈឃោសៈនៃសូរព្យញ្ជនៈ
- តារាងទី៣នេះ អាចចាត់ទុកជាតារាងដែលបង្ហាញសញ្ញាតាមន្លឺទាំងបួន(traits articulatoires) នៃសូរព្យញ្ជនៈ គឺមុខជៈឬនាសិកជៈ, ទីបន្លឺ, វង្វះខ្យល់ឬរបៀបបន្លឺ និង លក្ខណៈអឃោសៈឬឃោសៈ។

## II- សូរស្រៈខ្មែរ

តាមនិយមន័យទូទៅ សូរស្រៈជាសូរមួយប្រភេទដែលគ្មានឧបសគ្គឬទំនប់អ្វីមួយមករាំង ក្នុងការបន្លឺ។ ក្នុងការបន្លឺសូរស្រៈទៀតសោត ខ្សែសំឡេងញ័រខ្លាំង វង្វះខ្យល់បើកធំ និង គ្មានបម្រឹង សាច់ដុំរបស់ប្រដាប់បន្លឺទេ។

ភាសាខ្មែរក៏ដូចជាភាសាដទៃទៀតក្នុងក្រុមមន-ខ្មែរ(ក្នុងនោះមានភាសាព្រៅ ជាដើម) ជាភាសាដែលមានសូរស្រៈច្រើនជាងសូរព្យញ្ជនៈគឺមានលើសពី៣០សូរ ទោះបីអ្នកស្រាវជ្រាវមិនទាន់ យល់ស្របគ្នាទាំងស្រុងចំពោះចំនួនសូរនេះក៏ដោយ ប៉ុន្តែការខ្វែងគំនិតគ្នាមានតិចតួច, ឧ. ស្រៈ ៃ ប្រើជាមួយព្យញ្ជនៈពួក «អ» ត្រូវបានលោក ឃួន សុខម្ភូ ចាត់ទុកថាជា ស្រៈផ្សំ (diphtongue) ហើយ កត់ត្រាដោយ API (Alphabet Phonétique International) ដូច ស្រៈផ្សំ [ai] ក្នុង

ពាក្យអង់គ្លេស [taim](time) ហើយ ក្រុមយើងយល់ថា សូរនេះកើតពីស្រះ(អាខ្លី(អា់)ប្រកប នឹងព្យញ្ជនៈទៅវិញទេ គឺជាព្យាង្គ(ស្រះ + ព្យញ្ជនៈ))។ តាមពិត ការខ្វែងគំនិតគ្នា មានចំនួនតិចតួច។ ក្រោយពីការពិចារណាថ្លឹងថ្លែងគ្រប់ជ្រុងជ្រោយ ក្រុមយើងបានសម្រេចបន្ថយចំនួនសូរស្រះ ជាពិសេសសូរស្រះល្បាយ ដូចមានក្នុងតារាងជាបន្តបន្ទាប់ខាងក្រោយ។

សូរស្រះបិទគឺជាប្រភេទសូរស្រះដែលក្នុងពេលបន្លឺ ចលនាអណ្តាតឡើងទៅលើហួសពីអ័ក្សកណ្តាលនៃគុហាមាត់។ សូរស្រះបិទមាន [i], [i:], [ɯ], [ ɯ: ], [u], [u:]។

សូរស្រះខ្លីគឺជាសូរស្រះដែលក្នុងការបន្លឺសូរ គេឃើញថា រយៈពេលនៃការបន្លឺមានរយៈពេលខ្លី។ ក្នុងភាសាមួយចំនួនដែលក្នុងនោះមានភាសាខ្មែរផងដែរ គេឃើញវត្តមានសូរស្រះខ្លីនៅក្នុងព្យាង្គខ្សោយ គឺព្យាង្គដែលមិនទទួលការសង្កត់សូរ(សូរសង្កត់)[៣](stress) ដូចជា ក្នុងពាក្យ "កករ"[kɒkɒ:] សូរស្រះ[ɒ] ក្នុងព្យាង្គទីមួយដែលជាព្យាង្គខ្សោយឮសូរកញ្ឆក់ខ្លីជាងសូរស្រះ[ɒ:] ក្នុងព្យាង្គទីពីរដែលជាព្យាង្គខ្លាំងឬព្យាង្គដែលទទួលការសង្កត់សូរ។

តាមចលនាមុខក្រោយនៃអណ្តាត ក្នុងការបន្លឺ គេបែងចែកសូរស្រះជាសូរស្រះមុខ សូរស្រះកណ្តាល និង សូរស្រះក្រោយ។ ដោយផ្អែកលើចលនាលើក្រោមនៃអណ្តាតវិញ គេចែកសូរស្រះជាសូរស្រះលើ សូរស្រះមធ្យម និង សូរស្រះក្រោម។ ក្នុងភាសាខ្មែរ សូរស្រះ [i], [i:] ជាដើម ជាសូរស្រះមុខផង ជាសូរស្រះលើផង ព្រោះថា ក្នុងការបន្លឺ បើគិតតាមចលនាមុខក្រោយនៃអណ្តាត យើងឃើញថា អណ្តាតរុញទៅមុខ។ បើគិតតាមចលនាលើក្រោម គេឃើញចលនាអណ្តាត ឡើងលើហួសអ័ក្សកណ្តាលនៃគុហាមាត់។ សូរស្រះ[u]និង[u:] ជាសូរស្រះក្រោយ និង ជាសូរស្រះលើ។ ក្នុងការបន្លឺ សូរស្រះទាំងពីរនេះ គេឃើញថា ខ្នងអណ្តាតរុញទៅក្រោយទៅរកនាំងក្រអូម និងទៅលើ។ ចំណែកឯសូរស្រះ[ɯ]និងសូរស្រះ[ɯ:] ត្រូវបានគេចាត់ជាសូរស្រះកណ្តាល និងជាសូរស្រះលើ។ តាមអ្វីដែលបានពណ៌នាពីខាងលើ គេអាចតាងចំណែកថ្នាក់ទូទៅនៃសូរស្រះ តាមចលនាអណ្តាត ដូចតារាងខាងក្រោម។

---

[៣] វាក្យសព្ទរបស់បណ្ឌិត ព្រុំ ម៉ល់។

## ១- ចំណែកថ្នាក់ស្វរស្រៈតាមចលនាអណ្តាត (លក្ខណៈទូទៅ)

**តារាងទី៤ : ស្វរស្រៈតាមចលនាអណ្តាត**

| ចលនាមុខក្រោយ / ចលនាលើក្រោម | មុខ | កណ្តាល | ក្រោយ |
| --- | --- | --- | --- |
| លើ | [i] (អ៊ិ) | [ɯ:] (អ៊ឺ) | [u] (អ៊ុ) |
| មធ្យម | [e] (អិ) | | [o] (អុ) |
| ក្រោម | | [a] (អ៉) | |

## ២- ចំណែកថ្នាក់ជាស្វរស្រៈវែងនិងជាស្វរស្រៈខ្លី

អ្នកសិក្សាស្រាវជ្រាវភាសាខ្មែរទាំងអស់ស្របមតិគ្នាក្នុងការចែកស្វរស្រៈខ្មែរ ជាស្វរស្រៈវែង និងស្វរស្រៈខ្លី។ ស្វរស្រៈខ្លីក្នុងភាសាខ្មែរក៏ដូចជាក្នុងភាសាដទៃទៀត ភាគច្រើនជាស្វរស្រៈបិទ និងជាស្វរស្រៈដែលមានរយៈពេលបន្លឺខ្លី។ ស្វរស្រៈខ្លីមាន [i], [e], [ea], [ɯ], [œ], [ə], [u], [o], [a], [ɔ], [ɒ] ។ ចំណែកស្វរស្រៈវែងជាស្វរស្រៈដែលក្នុងការបន្លឺ មានរយៈពេលវែង។ ស្វរស្រៈវែងមាន [i:], [ie], [e:], [œ:], [ɯ:], [u:], [uə], [aə], [ɯə], [ɛ], [aɛ], [ẹ], [ɤ], [o:], [ọ], [a:], [ɒ:], [ɔ:], [ea:], [oa], [ao]។

## ៣- ចំណែកថ្នាក់ស្វរស្រៈតាមភាពបិទបើក

កាលណាគេនិយាយពីស្វរស្រៈបិទនិងស្វរស្រៈបើក នោះគេគិតពីចលនាលើក្រោមនៃអណ្តាត។ ក្នុងការបន្លឺស្វរស្រៈណាមួយ បើខ្នងអណ្តាតខិតទៅជិតចំណុចណាមួយនៃផ្ទៃក្រអូម គេថាស្វរស្រៈនោះជាស្វរស្រៈបិទ តែបើក្នុងការបន្លឺស្វរស្រៈណាមួយ ខ្នងអណ្តាតមិនទៅជិតនឹងផ្ទៃក្រអូម គេហៅស្វរស្រៈនោះ ថាជាស្វរស្រៈបើក។ និយាយរួម ស្វរស្រៈលើជាស្វរស្រៈបិទ ស្វរស្រៈកណ្តាល និង ស្វរស្រៈក្រោមជាស្វរស្រៈបើក។ ក្នុងភាសាខ្មែរ ស្វរស្រៈបិទមាន [i], [i:], [ɯ], [ɯ:], [u] និង [u:]។ ចំពោះស្វរស្រៈដទៃក្រៅពីនេះ គេចាត់ទុកថាជាស្វរស្រៈបើក ទោះបីជាស្វរស្រៈខ្លះមានកម្រិតបើកតិចតួចក៏ដោយ ដូចជា [ea], [ea:], [ie], [œ], [œ:], [a], [a:] ជាដើម។

## ៤- ចំណែកថ្នាក់ស្របស្រៈតាមចលនាមុខក្រោយនិងតាមចលនាលើក្រោម

សូរស្រៈតាមចលនាមុខក្រោយ ជាសូរស្រៈដែលគេធ្វើការបែងចែកដោយគិតពីចលនាលាតនៃអណ្ដាត (ចលនាមុខក្រោយនៃអណ្ដាត) ក្នុងពេលបន្លឺសូរស្រៈណាមួយ។ សូរស្រៈតាមចលនាលើក្រោមជាសូរស្រៈបែងចែកដោយគិតពីចលនាបញ្ឈរនៃអណ្ដាត(ចលនាលើក្រោមនៃអណ្ដាត)។

<u>កំណត់សម្គាល់</u> :

១- ក្នុងភាសាខ្មែរក៏ដូចភាសាមួយចំនួនធំទៀត សូរស្រៈក្រោយសុទ្ធសឹងជាសូរស្រៈដែលលោក ឃួន សុខម្ភ ហៅថាស្រៈមូល។

២- សូរស្រៈលើសុទ្ធសឹងជាសូរស្រៈបិទ។

ការបែងចែកសូរស្រៈខ្មែរតាមចលនាមុខក្រោយនិងតាមចលនាលើក្រោមមានបង្ហាញក្នុងតារាងខាងក្រោម។

**តារាងទី៥ : សូរស្រៈខ្មែរតាមចលនាមុខក្រោយនិងតាមចលនាលើក្រោម**

| ចលនាមុខក្រោយ / ចលនាលើក្រោម | មុខ | កណ្ដាល | ក្រោយ |
|---|---|---|---|
| **លើ** | [i] (អ៊ិ) [i:] (អ៊ី) [ie] (អៀ) | [ɯ] (អ៊ឹ) [ɯ:] (អ៊ឺ) [ɯə] (អឿ) | [u] (អ៊ុ) [u:] (អ៊ូ) [uə] (អួ) |
| **មធ្យម** | [ẹ] (អេ៊) [e:] (អេ) [e] (អិ) [ea] (អាំ) [ea:] (អ៊ា) [ɛ] (អ៊ែ) [aɛ] (អែ) | [ɤ] (អឺ៊) [œ]/[ə] (អឹ) [œ:] (អឺ) | [o] (អុ) [o:] (អូ) [ọ] (អ៊ោ) [ɔ] (អ៊់) [ɔ:] (អ៊) [oa] (អ៊័) |
| **ក្រោម** | [a] (អាំ) [a:] (អា) | [aə] (អើ) | [ɒ] (អ់) [ɒ:] (អ) [ao] (អៅ) |

## ៥- ចំណែកថ្នាក់សូរស្រៈទោលនិងសូរស្រៈល្បាយ

យើងបានផ្ដល់ទឡ្ហីករណ៍ម្ដងហើយ នៅពេលដែលយើងចាប់ផ្ដើមនិយាយពី *«សូរស្រៈក្នុងភាសាខ្មែរ»* ដែលមានសេចក្ដីដូចតទៅ «ភាសាខ្មែរក៏ដូចជាភាសាដទៃទៀតក្នុងក្រុមមន-ខ្មែរ(ក្នុងនោះមាន ភាសាព្រៅ ជាដើម) ជាភាសាដែលមានសូរស្រៈច្រើនជាងសូរព្យញ្ជនៈ គឺមានលើសពី ៣០សូរ ទោះបីអ្នកស្រាវជ្រាវមិនទាន់យល់ស្របគ្នាទាំងស្រុងចំពោះចំនួនសូរនេះក៏ដោយ ប៉ុន្តែការខ្វែងគំនិតគ្នាមានតិចតួច, ឧ.ស្រៈ ៃ ប្រើជាមួយព្យញ្ជនៈពួក«អ» ត្រូវលោកបណ្ឌិត ឃួន សុខម្ភូ បានចាត់ទុកថាជាស្រៈផ្សំ (diphtongue) ហើយ កត់ត្រាដោយ API (Alphabet Phonétique International) ដូចស្រៈផ្សំ [ai] ក្នុងពាក្យអង់គ្លេស [taim] (time) ប៉ុន្តែក្រុមយើងយល់ថា សូរនេះកើតពីស្រៈអាខ្លីប្រកបនឹងព្យញ្ជនៈទៅវិញទេ គឺជាព្យាង្គ (ស្រៈ + ព្យញ្ជនៈ)។ តាមពិត ការខ្វែងគំនិតគ្នាមានចំនួនតិចតួច។ ក្រោយពីការពិចារណាថ្លឹងថ្លែងគ្រប់ជ្រុងជ្រោយ ក្រុមយើងបានសម្រេចបន្ថយចំនួនសូរស្រៈ ជាពិសេស សូរស្រៈល្បាយ ដូចមានក្នុងតារាងជាបន្តបន្ទាប់»។

នេះជាតារាងបង្ហាញចំនួនសូរស្រៈទោលនិងសូរស្រៈល្បាយដែលក្រុមយើងបានអនុម័តយក៖

**តារាងទី១ : សូរស្រៈទោល ( មាន ២២ សូរ )**

| ចលនាមុខក្រោយ / ចលនាលើក្រោម | មុខ | កណ្ដាល | ក្រោយ |
|---|---|---|---|
| **លើ** | [i] (អ៊ិ) [i:] (អ៊ី) | [ɯ] (អ៊ឹ) [ɯ:] (អ៊ឺ) | [u] (អ៊ុ) [u:] (អ៊ូ) |
| **មធ្យម** | [e] (អិ) [e:] (អេ)<br>[ẹ] (អ៊េ)<br>[ɛ] (អ៊ែ) | [ɤ] (អ៊ើ)<br>[œ]/[ə](អឹ) [œ:](អឺ) | [o] (អុ) [o:] (អូ)<br>[ọ] (អ៊ោ)<br>[ɔ] (អ៊ ) [ɔ:] (អ៊) |
| **ក្រោម** | [a] (អា់) [a:] (អា) | | [ɒ] (អ់) [ɒ:] (អ) |

**តារាងទី៧ : សូរស្រៈល្បាយ(មាន ៩ សូរ )**

| ចលនាមុខក្រោយ / ចលនាលើក្រោម | មុខ | កណ្ដាល | ក្រោយ |
|---|---|---|---|
| លើ | [ie] (អៀ) | [ɯə] (អឿ) | [uə] (អួ) |
| មធ្យម | [ea] (អ៊ា៎) [ea:] (អ៊ា) | | [oa] (អ៊ុំ) |
| ក្រោម | [aɛ] (អែ) | [aə] (អើ) | [ao] (អោ) |

<u>កំណត់សម្គាល់</u> : តារាងទី៦និងទី៧ អាចចាត់ទុកជាតារាងសរុបចំនួនសូរស្រៈទោលនិងសូរស្រៈល្បាយ ទាំងប៉ុន្មានដែលយើងបានអនុម័តយកសម្រាប់ភាសាខ្មែរ។

## III- សទ្ទតាព្យញ្ជនៈនិងសទ្ទតាស្រៈ

### ១- ការស្វែងយល់អំពីសទ្ទតាខ្មែរ

**<u>ការពន្យល់ទី១៖</u>**

សទ្ទតាជាឯកតាអប្បបរមាគ្មានន័យរបស់ភាសា[៤] ហើយ មានមុខងារញែក/មុខងារបំប្លែកនៅក្នុងរូបតានិងវចនតា។ សទ្ទតាជារូបធាតុគ្រឹះសម្រាប់បង្កើតរូបតានិងវចនតា ដូចជា /t/និង/n/ ដែលមានមុខងារញែក/មុខងារបំប្លែកនៅចុងព្យាង្គ /ba:t/និង/ba:n/ ជាសទ្ទតា។ ដូចគ្នានេះដែរ /p/និង/b/ ដែលមានមុខងារញែក/មុខងារបំប្លែកនៅដើមព្យាង្គ /pɒ:m/និង/bɒ:m/ ក៏ជាសទ្ទតាដែរ។ រីឯ /ea:/និង/ɤ/ ក៏មានមុខងារញែក/មុខងារបំប្លែករវាង /lea:/និង/lɤ/ ដែរ ដូច្នេះវាជាសទ្ទតា។

យើងអាចពិនិត្យបន្តមុខងារញែក/មុខងារបំប្លែករបស់សទ្ទតា ដូចដែលយើងបានធ្វើខាងលើនេះ ដើម្បីបង្ហាញថា សូរក្នុងភាសាខ្មែរដែលយើងបានវិភាគឃើញខាងដើម(ផ្នែកសូរវិទ្យា) ជាសទ្ទតា[៥]។

---

[៤] ចំពោះភាសាដែលចាត់ទុកសទ្ទតា ជាឯកតាតូចបំផុតរបស់ភាសានោះ។

[៥] លើកលែងតែសូរ [ʔ]ដែលឥតមានមុខងារញែកជាទូទៅទេ វាមានមុខងារនេះតែក្នុងករណីខ្លះដែលយើងហៅថា បាតុភូតសូរវិស័យ( phénomène phonétique )។

## ការពន្យល់ទី២៖

ការពន្យល់ទី២អំពីសទ្ទតា ផ្អែកលើបញ្ញត្តិមូលដ្ឋានពីរ គឺ *បរិបទ* និង *ទីតាំង*។

*បរិបទ* នៃ*ឯកតាភាសា*( unité linguistique )[៦]ណាមួយ គឺជាឯកតាភាសាឯទៀតដែលស្ថិតនៅខាងឆ្វេងនិង/ឬខាងស្តាំ នៃឯកតាភាសានោះ, ដូចក្នុងពាក្យ / kon / :

- បរិបទរបស់ [k] គឺ [- on] ( មាន [on] នៅខាងស្តាំ );
- បរិបទរបស់ [n] គឺ [ko -] ( មាន [ko] នៅខាងឆ្វេង );
- បរិបទរបស់ [o] គឺ [k - n] ( មាន [k] នៅខាងឆ្វេង និង [n] នៅខាងស្តាំ )។

*ទីតាំង* ក្នុងន័យទូលាយ គឺជាកន្លែងដែលឯកតាភាសាណាមួយស្ថិតនៅ។ ក្នុងន័យចង្អៀតនៅទីនេះ *ទីតាំង* គឺជាទីតាំងរបស់សទ្ទតា គឺកន្លែងដែលសទ្ទតាណាមួយស្ថិតនៅ( ដើមព្យាង្គ, កណ្តាលព្យាង្គ, ចុងព្យាង្គ, ក្នុងព្យាង្គបើក, ក្នុងព្យាង្គបិទ, ... )។

សទ្ទតាជាឯកតាភាសាអប្បបរមាដែលឥតមានន័យ ប៉ុន្តែវាមាន«មុខងារបំប្លែក»[៧]( fonction distinctive ) រវាងពាក្យ, ឧ. សទ្ទតា/s/ និង សទ្ទតា/c/ បំប្លែកពាក្យ [so:k]និងពាក្យ [co:k] ក្នុងបរិបទតែមួយ [-o:k] ឱ្យប្លែកគ្នា ពីព្រោះ ក្នុងពាក្យទី១ មានសទ្ទតា/s/ និង ក្នុងពាក្យទី២ មានសទ្ទតា/c/ នៅដើមព្យាង្គដូចគ្នា( ពាក្យ១ព្យាង្គ )។

វិធីដែលយើងបានប្រើសម្រាប់វិភាគរកសទ្ទតាព្យញ្ជនៈ ក៏ជាវិធីដែលត្រូវប្រើដើម្បីវិភាគរកសទ្ទតាស្រៈដែរ។ បើយើងពិនិត្យសូរដែលយើងបានវិភាគឃើញទាំងប៉ុន្មានខាងដើម( ផ្នែកសូរវិទ្យា) ដោយផ្អែកលើ *ទីតាំង* និង*បរិបទ* ដូចដែលយើងបានពិនិត្យរួចមកហើយ យើងនឹងឃើញថា សូរទាំងនោះជាសទ្ទតា( លើកលែងតែសូរ [ʔ][៨] )៖

---

[៦] ឯកតាភាសាជាបណ្តុំមួយដែលមានអត្តិភាពប្លែកពីឯកតាភាសាឯទៀតនិងដាច់ពីឯកតាភាសាទាំងនោះ នៅក្នុងប្រព័ន្ធណាមួយ។ ឯកតាភាសាអាចជាសូរ, សទ្ទតា។

[៧] «មុខងារបំប្លែក» គឺមុខងារធ្វើឱ្យពាក្យមួយប្លែកពីពាក្យមួយទៀតឬពាក្យឯទៀត, ឧ. [bɒ:ŋ] ≠ [bɒ:n] ពីព្រោះ ក្នុងពាក្យទី១ មានសទ្ទតា /ŋ/ និង ក្នុងពាក្យទី២ មានសទ្ទតា /n/ នៅខាងចុងដូចគ្នា ដែលធ្វើឱ្យពាក្យ [bɒ:ŋ] ប្លែកពីពាក្យ [bɒ:n]។

[៨] សូរ [ʔ] មិនអាចស្ថិតនៅគ្រប់បរិបទទេ ដូច្នេះវាមិនមែនជាសទ្ទតាឡើយ។

- សទ្ទតាព្យញ្ជនៈមានចំនួន១៧ គឺ /p/, /b/, /t/, /d/, /c/, /k/, /m/, /n/, /ɲ/, /ŋ/, /s/, /h/, /r/, /l/, /w/, /j/ និង /ʔ/។
- សទ្ទតាស្រៈទោលមានចំនួន២២ គឺ /i/, /i: /, /ɯ/, /ɯ:/, /u/, /u:/, /e/, /e:/, /ɤ/, /o/, /o:/, /ẹ/, /œ/, /œ:/, /ọ/, /ɛ/, /a/, /a:/, /ɒ/, /ɒ:/, /ɔ/, /ɔ:/។
- សទ្ទតាស្រៈល្បាយមានចំនួន៩ គឺ /ie/, /ɯə/, /uə/, /ea/, /ea:/, /oa/, /aɛ/, /aə/, /ao/។

## ២- ការកត់ត្រាសទ្ទតាព្យញ្ជនៈនិងសទ្ទតាស្រៈខ្មែរដោយអក្សរខ្មែរ

### ២.១- ការកត់ត្រាសទ្ទតាព្យញ្ជនៈ

(១)- សទ្ទតា /p/ កត់ត្រាដោយសញ្ញាប៉&ព, ឧ. /pahpoal/ (ប៉ះពាល់), /pi:/ (ពី/ពីរ)។

(២)- សទ្ទតា /b/ កត់ត្រាដោយសញ្ញាប&ប៊, ឧ. /bej/ (បី), /but/ (ប៊ុត)។

(៣)- សទ្ទតា /t/ កត់ត្រាដោយសញ្ញាត&ទ, ឧ. [ta:](តា), [ti:](ទី)។

(៤)- សទ្ទតា /d/ កត់ត្រាដោយសញ្ញាដ&ឌ, ឧ. /dej/(ដី), /dɯ:/ (ឌឺ)។

(៥)- សទ្ទតា /c/ កត់ត្រាដោយសញ្ញាច&ជ, ឧ. /caot/ (ចោត), /cu:/ (ជូរ)។

(៦)- សទ្ទតា /k/ កត់ត្រាដោយសញ្ញាក&គ, ឧ. /ka:/(កា/ការ), /kɔ:ki:/ (គគីរ)។

(៧)- សទ្ទតា /m/ កត់ត្រាដោយសញ្ញាម៉&ម, ឧ. /mɒt/ (ម៉ត់), /muŋ/ (មុង)។

(៨)- សទ្ទតា /n/ កត់ត្រាដោយសញ្ញាណ&ន, ឧ. /nat/ (ណាត់), /nea:m/ (នាម)។

(៩)- សទ្ទតា /ɲ/ កត់ត្រាដោយសញ្ញាញ៉&ញ, ឧ. /ɲaŋ/ (ញុាំង), /ɲi:/ (ញី)។

(១០)- សទ្ទតា /ŋ/ កត់ត្រាដោយសញ្ញាង៉&ង, ឧ. /ŋɒk/ (ង៉ក់), /ŋea:k/ (ងាក)។

(១១)- សទ្ទតា /s/ កត់ត្រាដោយសញ្ញាស&ស៊, ឧ. /sej/ (សី), /si:/ (ស៊ី)។

(១២)- សទ្ទតា /h/ កត់ត្រាដោយសញ្ញាហ&ហ៊, ឧ. /ha:m/ (ហាម), /hea:n/ (ហ៊ាន)។

(១៣)- សទ្ទតា /r/ កត់ត្រាដោយសញ្ញារ៉&រ, ឧ. /rɯəŋra:w / (រឿងរ៉ាវ), /rea:n/ (រាន)។

(១៤)- សទ្ទតា /l/ កត់ត្រាដោយសញ្ញាឡ&ល, ឧ. /lo:la:/ (ឡូឡា), /li:/ (លី)។

(១៥)- សទ្ទតា /w/ កត់ត្រាដោយសញ្ញាវ៉&វ, ឧ. /wa:/ (វ៉ា) (ឡានវ៉ាគ្នា), / wea:/ (វា)។

(១៦)- សទ្ទតា /j/ កត់ត្រាដោយសញ្ញាយ៉&យ , ឧ. /ja:ŋ/ (យ៉ាង), /ju:/ (យូរ)។

(១៧)- សទ្ទតា /ʔ/ មិនអាចមានតម្លៃជាសទ្ទតាដើមព្យាង្គទី១ ក្នុងទម្រង់ «ពស»និង«ពសព» បានទេ តែវាមានតម្លៃជាសទ្ទតាដើមព្យាង្គទី២(ព₂) ក្នុងទម្រង់ ព₁ព₂ស, ឧ. /sʔa:/ «ស្អា» (ក្នុងពាក្យនេះ /ʔ/ ជាព₂) និងព₁ព₂សព₃, ឧ. /pʔa:ʔ/«ផ្អាក» (ក្នុងពាក្យនេះ /ʔ/ ជាព₂ និងជាព₃ផង) និង មានតម្លៃជាសទ្ទតាចុងព្យាង្គក្នុងទម្រង់ព₁ព₂សព₃, ឧ. /kraʔ/ «ក្រាក់»(ក្នុងពាក្យនេះ /ʔ/ជាព₃)។

<u>កំណត់សម្គាល់</u> :

ក្នុងចំណោមអក្សរខ្មែរ សញ្ញាព្យញ្ជនៈមួយចំនួនកត់ត្រាសទ្ទតាពីរផ្សេគ្នា រួមមាន៖

(១)- សញ្ញា ខ឴ ឃ កត់ត្រាដោយសទ្ទតាពីរផ្សំគ្នា គឺ [kh], ឧ. ខឹង [khœŋ], ឃើញ [khɤɲ]។

(២)- សញ្ញា ឆ ឈ កត់ត្រាដោយសទ្ទតាពីរផ្សំគ្នា គឺ [ch], ឧ. ឆាប [cha:p], ឈាន [chea:n]។

(៣)- សញ្ញា ឋ ឍ ថ ធ កត់ត្រាដោយសទ្ទតាពីរផ្សំគ្នា គឺ [th], ឧ.ឋាន [tha:n], ឍាល [thea:l], ថែម [thaɛm], ធូរ [thu:]។

(៤)- សញ្ញា ផ ភ កត់ត្រាដោយសទ្ទតាពីរផ្សំគ្នា គឺ [ph], ឧ.ផ្ទង [pho:ŋ], ភើច [phɤc]។

<u>សេចក្តីបញ្ជាក់</u> : សញ្ញា អ ទទួលស្រះនិស្ស័យដូចសញ្ញាព្យញ្ជនៈឯទៀតដែរ ព្រមទាំងមានជើងផង គឺ ្អ (ដូច ជើង ្ក , ជើង ្ខ ... ដែរ)។ បើយើងមើលនឹងភ្នែក វាមានលក្ខណៈដូចសញ្ញាព្យញ្ជនៈឯទៀតដែរ។ ប៉ុន្តែ បើយើងស្តាប់តាមត្រចៀកវិញ វាមានសូរដូចសូរស្រៈឬសទ្ទតាស្រៈ, ឧ. អ [ɒ:], អា [a:], អិ [e], ...។

## ២.២- ការកត់ត្រាសទ្ទតាស្រៈ

- សទ្ទតាស្រៈទោលមានចំនួន២២ គឺ /i/, /i:/, /ɯ/, /ɯ:/, /u/, /u: /, /e/, /e:/, /ɤ/, /o/, /o:/, /ẹ/, /œ/, /œ:/, /ọ/, /ɛ/, /a/, /a: /, /ɒ/, /ɒ:/, /ɔ/, /ɔ:/។
- សទ្ទតាស្រៈល្បាយមានចំនួន៩ គឺ /ie/, /ɯə/, /uə/, /ea/, /ea:/, /oa/, /aɛ/, /aə/, /ao/។

### ២.២.១- ការកត់ត្រាសទ្ទតាស្រៈទោល

(១)- សទ្ទតា/i/(អ៊ិ) កត់ត្រាដោយសញ្ញាស្រៈ"ិ" ប្រើជាមួយព្យញ្ជនៈពួកអិ, ឧ.ជិប(១ជិប)/cip/។

(២)- សទ្ទតា/i:/ (អ៊ី) កត់ត្រាដោយសញ្ញាស្រៈ"ី" ប្រើជាមួយព្យញ្ជនៈពួកអិ, ឧ. ជីប /ci:p/។

(៣)- សទ្ទតា/ɯ/ (អ៊ឹ) កត់ត្រាដោយសញ្ញាស្រៈ"ឹ" ប្រើជាមួយព្យញ្ជនៈពួកអិ, ឧ. យឹត /jɯt/។

(៤)- សទ្ទតា/ɯ:/ (អ៊ឺ) កត់ត្រាដោយសញ្ញាស្រៈ"ឺ" ប្រើជាមួយព្យញ្ជនៈពួកអិ, ឧ. យឺត /jɯ:t/។

(៥)- សទ្ទតា/u/ (អ៊ុ) កត់ត្រាដោយសញ្ញាស្រៈ"ុ" ប្រើជាមួយព្យញ្ជនៈពួកអ៊, ឧ. ទ្រុង /truŋ/, ឧត្តម/utdɒm/។

(៦)- សទ្ទតា/uː/ (អ៊ូ) កត់ត្រាដោយសញ្ញាស្រៈ"ូ" ប្រើជាមួយព្យញ្ជនៈពួកអ៊, ឧ. ទ្រូង /truːŋ/។

(៧)- សទ្ទតា/e/ (អិ) កត់ត្រាដោយសញ្ញាស្រៈ"ិ" ប្រើជាមួយព្យញ្ជនៈពួកអ ឬ ដោយសញ្ញាស្រៈ ពេញតួ «ឥ», ឧ. ច្រិចៗ /creccrec/, ឥត /et/។

(៨)- សទ្ទតា/eː/(អេ) កត់ត្រាដោយសញ្ញាស្រៈ" េ" ប្រើជាមួយព្យញ្ជនៈពួកអ, ឧ. ច្រេច /creːc/។

(៩)- សទ្ទតា/ɤ/ (អ៊ើ) កត់ត្រាដោយសញ្ញាស្រៈ" ើ" ប្រើជាមួយព្យញ្ជនៈពួកអ៊, ឧ.ទើរ /tɤ/។

(១០)- សទ្ទតា/o/ (អុ) កត់ត្រាដោយសញ្ញាស្រៈ"ុ" ប្រើជាមួយព្យញ្ជនៈពួកអ ឬ ដោយសញ្ញាស្រៈពេញតួ «ឧ», ឧ. ចុក /cok/, ឧកញ៉ា /okɲaː/។

(១១)- សទ្ទតា /oː/ (អូ) កត់ត្រាដោយសញ្ញាស្រៈ"ូ" ប្រើជាមួយព្យញ្ជនៈពួកអ, ឧ. ចូក /coːk/។

(១២)- សទ្ទតា /ẹ/ (អ៊េ) កត់ត្រាដោយសញ្ញាស្រៈ" េ" ប្រើជាមួយព្យញ្ជនៈពួកអ៊, ឧ.គេ /kẹ]។

(១៣)- សទ្ទតា/œ/ (អឹ) កត់ត្រាដោយសញ្ញាស្រៈ"ឹ" ប្រើជាមួយព្យញ្ជនៈពួកអ, ឧ.ប៉ឹង/pœŋ]។

(១៤)- សទ្ទតា/œː/ (អឺ) កត់ត្រាដោយសញ្ញាស្រៈ"ឺ" ប្រើជាមួយព្យញ្ជនៈពួកអ, ឧ. ប៉ឺង /pœːŋ]។

(១៥)- សទ្ទតា/ọ/ (អ៊ោ) កត់ត្រាដោយសញ្ញាស្រៈ" ោ" ប្រើជាមួយព្យញ្ជនៈពួកអ៊, ឧ. គោ /kọ/។

(១៦)- សទ្ទតា /ɛ/ (អ៊ែ) កត់ត្រាដោយសញ្ញាស្រៈ" ែ" ប្រើជាមួយព្យញ្ជនៈពួកអ៊, ឧ. គែ /kɛ/។

(១៧)- សទ្ទតា /a/ (អា់) គ្មានសញ្ញាសម្រាប់កត់ត្រាទេ ប៉ុន្តែ ក្នុងព្យាង្គឬក្នុងពាក្យ គេប្រើសញ្ញាស្រៈ«ា»ជាមួយព្យញ្ជនៈពួក អ ដោយដាក់សញ្ញាបន្តក់លើព្យញ្ជនៈចុងព្យាង្គ, ឧ. ចាក់ [caʔ]។

(១៨)- សទ្ទតា/aː/(អា)កត់ត្រាដោយសញ្ញាស្រៈ«ា»ប្រើជាមួយព្យញ្ជនៈពួកអ,ឧ.ចាក[caːʔ]។

(១៩)- សទ្ទតា /ɒ/(អ់) គ្មានសញ្ញាសម្រាប់កត់ត្រាទេ។ ប៉ុន្តែ ក្នុងសំណេរ គេប្រើវាជាមួយព្យញ្ជនៈពួក អ ដោយប្រើសញ្ញាបន្តក់ «់» លើព្យញ្ជនៈចុងព្យាង្គ, ឧ.សក់[៩] [sɒʔ]។

---

[៩] ក្នុងពាក្យពីរព្យាង្គដែលសរសេរត្រួត គេមិនប្រើសញ្ញាបន្តក់ «់» សម្រាប់សម្គាល់សូរ [ɒ] (អ់) ទេ, ឧ. បង្កើត, កណ្តាល, សង្កត់ ...។

(២០)- សទ្ទតា /ɒ:/ (អ) ជាទូទៅតាងដោយសញ្ញា «ា»[១០] តែមិនត្រូវបានកត់ត្រាក្នុងសំណេរ ព្យាង្គឬពាក្យទេ, ឧ. បក [bɒ:ʔ]។

(២១)- សទ្ទតា /ɔ/ (អ៊ៈ) គ្មានសញ្ញាសម្រាប់កត់ត្រាទេ។ ប៉ុន្តែ នៅក្នុងសំណេរ គេប្រើវាជាមួយព្យញ្ជនៈពួកអ៊ ដោយប្រើសញ្ញាបន្តក់ «់» លើព្យញ្ជនៈចុងព្យាង្គ, ឧ. លង់[១១][lɔŋ]។

(២២)- សទ្ទតា[ɔ:] (អ៊) គ្មានសញ្ញាសម្រាប់កត់ត្រាទេ។ ប៉ុន្តែ នៅក្នុងសំណេរ គេប្រើវាជាមួយព្យញ្ជនៈពួកអ៊, ឧ. ពង [pɔ:ŋ]។

## ២.២.២- ការកត់ត្រាសទ្ទតាស្រៈល្បាយ

(១)- សទ្ទតា /ie/ (អៀ) កត់ត្រាដោយសញ្ញាស្រៈ"ៀ" ប្រើជាមួយព្យញ្ជនៈពួកអផងនិងព្យញ្ជនៈពួកអ៊ផង,ឧ. កៀង /kieŋ/, ជៀស /cieh/។

(២)- សទ្ទតា /ɯə/(អឿ) កត់ត្រាដោយសញ្ញាស្រៈ "ឿ" ប្រើជាមួយព្យញ្ជនៈពួកអផងនិងព្យញ្ជនៈពួកអ៊ ផង, ឧ. កឿង /kɯəŋ/, គ្រឿង /krɯəŋ/។

(៣)- សទ្ទតា /uə/ (អួ) កត់ត្រាដោយសញ្ញាស្រៈ"ួ" ប្រើជាមួយព្យញ្ជនៈពួកអផង និង ព្យញ្ជនៈពួកអ៊ ផង,ឧ. កួរ, គួរ /kuə/។

(៤)- សទ្ទតា/ea/ (អ៊ាៈ) គ្មានសញ្ញាស្រៈសម្រាប់កត់ត្រាទេ ប៉ុន្តែ ក្នុងព្យាង្គឬក្នុងពាក្យ គេប្រើសញ្ញាស្រៈ "ា" ជាមួយព្យញ្ជនៈពួកអ៊ដោយដាក់សញ្ញាបន្តក់ពីលើព្យញ្ជនៈចុងព្យាង្គ, ឧ. ពាក់ /peaʔ/។

(៥)- សទ្ទតា/ea:/ (អ៊ា) កត់ត្រាដោយសញ្ញាស្រៈ"ា "ប្រើជាមួយព្យញ្ជនៈពួកអ៊, ឧ. ពាក្យ /pea:ʔ/។

(៦)- សទ្ទតា/oa/(អ៊ំ) គ្មានសញ្ញាសម្រាប់កត់ត្រាទេ ប៉ុន្តែ ភាគច្រើន គេប្រើសំយោគសញ្ញាលើព្យញ្ជនៈពួកអ៊ប្រកបនឹង រ, ឧ. ជ័រ /coa/, ទំព័រ /tumpoa/ ជាដើម ហើយ ក្នុងពាក្យមួយចំនួន គេប្រើរបាទដាក់លើព្យញ្ជនៈ ណ, ឧ. ពណ៌ /poa/, ពណ៌នា /poarənea:/។

---

[១០] តាមសំណើរបស់បណ្ឌិត ចន្ទ សំណព្វ ដើម្បីឱ្យសមស្របតាមវេយ្យាករណ៍ប្រពៃណីដែលមានស្រាប់។

[១១] ដូចស្រៈ [ɒ] (អៈ) ដែរ, ក្នុងពាក្យពីរព្យាង្គដែលសរសេរត្រួត គេមិនប្រើសញ្ញាបន្តក់ «់» សម្រាប់សម្គាល់សូរ [ɔ] (អ៊ៈ), ឧ. ជង្គង់, ទន្ទេញ ...។

(៧)- សទ្ទតា/aɛ/ (អែ) កត់ត្រាដោយសញ្ញាស្រៈ"ែ" ប្រើជាមួយព្យញ្ជនៈពួកអឬសញ្ញាស្រៈពេញ តួ «ឯ», ឧ. កែង /kaɛŋ/, ឯង/aɛŋ/ ។

(៨)- សទ្ទតា/aə/(អើ) កត់ត្រាដោយសញ្ញាស្រៈ"ើ"ប្រើជាមួយព្យញ្ជនៈពួកអ, ឧ. ដើរ/daə/។

(៩)- សទ្ទតា /ao/ (អោ) កត់ត្រាដោយសញ្ញាស្រៈ" ោ" ប្រើជាមួយព្យញ្ជនៈពួកអឬដោយសញ្ញាស្រៈពេញតួ «ឱ», ឧ. កោត /kaot/, ឱកាស /aokah/។

<u>កំណត់សម្គាល់</u> :

ក្នុងចំណោមអក្សរខ្មែរ សញ្ញាស្រៈមួយចំនួនកត់ត្រាសូរស្រៈល្បាយនឹងព្យញ្ជនៈ រួមមាន៖

(១)- សញ្ញា «ី» ប្រើជាមួយព្យញ្ជនៈពួកអនិងសញ្ញាស្រៈពេញតួ «ឥ», «ឦ» កត់សូរ [e] + [j] > [ej] (អី), ឧ. កី[kej], ឥឡូវ [ejlow], ឦសាន[ejsa:n]។

(២)- សញ្ញា «ៃ» ប្រើជាមួយព្យញ្ជនៈពួកអនិងសញ្ញាស្រៈពេញតួ «ឰ» កត់សូរ [a] + [j] > [aj] (អៃ), ឧ. កៃ[kaj], ឰដ៏[ajdɒ:] និង ប្រើជាមួយព្យញ្ជនៈពួកអឺ កត់សូរ [i] + [j] > [ij], ឧ. នៃ[nij], ទៃ [tij]។

(៣)- សញ្ញា «ៅ» ប្រើជាមួយព្យញ្ជនៈពួកអនិងសញ្ញាស្រៈពេញតួ «ឪ» កត់សូរ [a] + [w] > [aw] (អៅ), ឧ. កៅ[kaw], ក្រឪ [krɒʔaw] និង ប្រើជាមួយព្យញ្ជនៈពួកអឺ កត់សូរ [ɔ] + [w] > [ɔw], ឧ. នៅ [nɔw], ទៅ [tɔw]។

(៤)-សញ្ញា « ុំ» ប្រើជាមួយព្យញ្ជនៈពួកអ កត់សូរ [o] + [m] > [om] (អុំ), ឧ. កុំ [kom] និង ប្រើជាមួយព្យញ្ជនៈពួកអឺ កត់សូរ [u] + [m] > [um], ឧ. ទុំ [tum]។

(៥)- សញ្ញា «ំ» ប្រើជាមួយព្យញ្ជនៈពួកអ កត់សូរ [ɒ] + [m] > [ɒm] (អំ), ឧ. ដំ [dɒm] និង ប្រើជាមួយព្យញ្ជនៈពួកអឺ កត់សូរ [ɔ] + [m] > [ɔm], ឧ. នំ [nɔm]។

(៦)- សញ្ញា « ាំ » ប្រើជាមួយព្យញ្ជនៈពួកអ កត់សូរ [a] + [m] > [am] (អាំ), ឧ. កាំ [kam] និង ប្រើជាមួយព្យញ្ជនៈពួកអឺ កត់សូរ [oa] + [m] > [oam], ឧ. នាំ [noam]។

(៧)- សញ្ញា «ះ» ប្រើជាមួយព្យញ្ជនៈពួកអ កត់សូរ [a] + [h] > [ah] (អះ), ឧ. ខ្លះ [klah] និង ប្រើជាមួយព្យញ្ជនៈពួកអឺ កត់សូរ [ea] + [h] > [eah], ឧ. ទះ [teah]។

(៨)- សញ្ញា «ុះ» ប្រើជាមួយព្យញ្ជនៈពួកអ កត់សូរ [o] + [h] > [oh] (អុះ), ឧ. ចុះ [coh] និង ប្រើជាមួយព្យញ្ជនៈពួកអ៊ កត់សូរ [u] + [h] > [uh], ឧ. ជ្រុះ [cruh]។

(៩)- សញ្ញា «េះ» ប្រើជាមួយព្យញ្ជនៈពួកអ កត់សូរ [e] + [h] > [eh], ឧ. កេះ [keh] និង ប្រើជាមួយព្យញ្ជនៈពួកអ៊ កត់សូរ [i]+[h] > [ih] (អ៊ិះ), ឧ. នេះ [nih]។

(១០)- សញ្ញា «ោះ» ប្រើជាមួយព្យញ្ជនៈអ កត់សូរ [ɒ] + [h] > [ɒh] (អោះ), ឧ. កោះ [kɒh] និង ប្រើជាមួយព្យញ្ជនៈពួកអ៊ កត់សូរ [ɔ] + [h] > [ɔh] (អ៊ោះ), ឧ. គោះ [kɔh]។

(១១)- សញ្ញា«ឪ» កត់សូរ [ow], ឧ. ឪពុក [owpuk]។

(១២)- សញ្ញា«ឫ» កត់សូរ [rɯ], ឧ. ឫកពា [rɯkpea:]។

(១៣)- សញ្ញា«ឬ» កត់សូរ [rɯ:],ឧ. រឺ [rɯ:]។

(១៤)- សញ្ញា«ឭ» កត់សូរ /lɯ/, ឧ. រឭក [rɔ:lɯk]។

(១៥)- សញ្ញា«ឮ» កត់សូរ [lɯ:], ឧ. លឺ [lɯ:]។

## IV- អក្សរខ្មែររៀបតាមទម្លាប់

ដោយអក្សរខ្មែរត្រូវបានយកទៅរៀបតាមលក្ខណៈសូរឬសទ្ទតានៃភាសាខ្មែរ(តាមទីបន្លឺ វង្វះខ្យល់ឬរបៀបបន្លឺ ...) យើងមានភារកិច្ចដាក់ជូនសាធារណជននូវអក្សរខ្មែរតាមទម្លាប់ដែលគេធ្លាប់បានចេះចាំមាត់រួចមកហើយ ដើម្បីជួយគេឱ្យអាចរកពាក្យក្នុងវចនានុក្រមភាសាខ្មែរ។

### ១- ព្យញ្ជនៈ

| | | | | | | | |
|---|---|---|---|---|---|---|---|
| ក្ក | ខ្ខ | គ្គ | ឃ្ឃ | ង្ង | | | |
| ច្ច | ឆ្ឆ | ជ្ជ | ឈ្ឈ | ញ្ញ | | | |
| ដ្ដ | ឋ្ឋ | ឌ្ឌ | ឍ្ឍ | ណ្ណ | | | |
| ត្ត | ថ្ថ | ទ្ទ | ធ្ធ | ន្ន | | | |
| ប្ប | ផ្ផ | ព្ព | ភ្ភ | ម្ម | | | |
| យ្យ | រ្រ | ល្ល | វ្វ | ស្ស | ហ្ហ | ឡ្ឡ | អ្អ។ |

## ២- ស្រៈ

### ២.១- ស្រៈនិស្ស័យ

◌ា ◌ិ ◌ី ◌ឹ ◌ឺ ◌ុ ◌ូ ◌ួ ◌ើ ◌ឿ
◌ៀ ◌េ ◌ែ ◌ៃ ◌ោ ◌ៅ ◌ុំ ◌ំ ◌ាំ ◌ះ
◌ុះ ◌េះ ◌ិះ ◌ឹះ ◌ោះ។

### ២.២- ស្រៈពេញតួ

អ អា ឥ ឦ ឧ ឩ ឪ ឫ ឬ ឭ ឮ ឯ ឰ ឱ ឳ។

## V- ព្យាង្គ[១២]

ព្យាង្គ គឺជាសូរបន្លឺឡើងក្នុងមួយបន្សាយសំឡេងឯករាជ្យ ដែលកើតឡើងដោយសំណុំសទ្ទតា[១៣](ព្យញ្ជនៈនិងស្រៈ) ហើយ ជាទម្រង់គ្រឹះនៃខ្សែសំដី។

## ១- ទម្រង់ព្យាង្គខ្មែរ

ព្យាង្គខ្មែរចែកជាទម្រង់ដូចខាងក្រោម៖

-ទម្រង់បីសទ្ទតាជាទម្រង់ដែលមានផ្នែកដើមព្យាង្គ ណ្វៃយ៉ូ[១៤]និងផ្នែកចុងព្យាង្គ តាងដោយ «ពសព» ក្នុងនេះ «ព» ជាព្យញ្ជនៈ(ផ្នែកដើមព្យាង្គ) «ស» ជាស្រៈ(ណ្វៃយ៉ូ) «ព» ជាព្យញ្ជនៈ(ផ្នែកចុងព្យាង្គ) ដូចជា [kap] «កាប់» ក្នុងនោះ [k] ជា «ព» [a] ជា «ស» និង [p] ជា «ព»។

---

[១២] ក្នុងភាសាខ្មែរ កាលណាគេនិយាយពីព្យាង្គ គឺគេគិតអំពីអក្សរផង (ដូចជាគេនិយាយពីព្យាង្គត្រួត ព្យាង្គរាយជាដើម) និង គេគិតពីសូរផងគឺព្យាង្គជាសូររួមនៃសទ្ទតាដែលបន្លឺក្នុងមួយបន្សាយសំឡេង។ តាមទ្រឹស្តីភាសាវិទ្យាក្នុងគ្រប់ភាសាទាំងអស់ កាលណាគេនិយាយពីព្យាង្គ គេគិតតែលើសូរប៉ុណ្ណោះ។ សម្រាប់សៀវភៅវេយ្យាករណ៍នេះ ព្យាង្គទាក់ទងតែនឹងសូរមិនទាក់ទងនឹងអក្សរទេ។

[១៣] សំណុំសទ្ទតាអាចមានសទ្ទតាតែមួយ។

[១៤] ពាក្យ«ណ្វៃយ៉ូ» ជាពាក្យកម្ចី«noyau» ពីភាសាដែលមានន័យថា «ស្នូលឬគ្រាប់»។

-ទម្រង់ពីរសទ្ទតាដែលតាងដោយ «ពស»និង«សព» ក្នុងនេះ «ព» ជាព្យញ្ជនៈ(ផ្នែកដើមព្យាង្គឬផ្នែកចុងព្យាង្គ) «ស» ជាស្វៃយ៉ូ ដូចជា ក្នុងទម្រង់ «ពស» [ka:] «កា» ក្នុងនោះ [k] ជា «ព» និង [a:] ជា«ស» និង ក្នុងទម្រង់ «សព» [a:n] «អាន» ក្នុងនោះ [a:] ជា«ស» និង [n] ជា «ព»[១៥] ។

គេឃើញមានទម្រង់«ពពសព» ដែលជាខ្នែងនៃទម្រង់«ពសព» ដូចជា[kba:l] «ក្បាល» និងទម្រង់ «ពពស» ដែលជាខ្នែងនៃទម្រង់ «ពស» ដូចជា [pdo:] «ប្ដូរ»។

-ទម្រង់មួយសទ្ទតា«ស» ដូចជា [o:] «អូរ», [a:] «អា», [ɒ:] «អរ» ...។

## ២- ប្រភេទព្យាង្គខ្មែរ

ព្យាង្គខ្មែរមានពីរប្រភេទគឺព្យាង្គបិទនិងព្យាង្គបើក។

ព្យាង្គបិទគឺជាព្យាង្គដែលមានព្យញ្ជនៈនៅខាងចុង។ ព្យាង្គបិទមានទម្រង់ «ពសព», «ពពសព» និង«សព»។ ព្យាង្គបើកគឺជាព្យាង្គដែលគ្មានព្យញ្ជនៈនៅខាងចុង។ ព្យាង្គបើកមានទម្រង់«ពស», «ពពស» និង «ស»។

## VI- វណ្ណយុត្តិ

ជាទូទៅ វណ្ណយុត្តិជាសញ្ញាសម្រាប់ប្រើផ្សំជាមួយនឹងអក្សរ។

វណ្ណយុត្តិមាន៖

### ១- សញ្ញាបន្តក់ (')

ជាទូទៅ សញ្ញាបន្តក់ប្រើសម្រាប់កាត់ព្យាង្គវែងឱ្យទៅជាព្យាង្គខ្លី ដូចជា កក > កក់, ទង > ទង់, សាក > សាក់, លាក > លាក់, ... ។

សញ្ញាបន្តក់ប្រើដាក់នៅលើព្យញ្ជនៈចុងព្យាង្គ ដូចជា៖

---

[១៥] បណ្ឌិត ច័ន្ទ សំណព្វ យល់ឃើញថា នៅក្នុងព្យាង្គខ្មែរ ទម្រង់«ស»និង«សព»នេះ អាចមានការវិភាគតាមសូរវិទ្យា ដោយផ្ដល់លទ្ធផលថា វាអាចមានទម្រង់«ពស»និង«ពសព»ទៅវិញ ដោយសារនៅក្នុងព្យាង្គ ទម្រង់ទាំងនេះមានវត្តមានព្យញ្ជនៈនៅខាងដើមព្យាង្គ។

(១)- ព្យញ្ជនៈដើមវគ្គ និង ព្យញ្ជនៈចុងវគ្គនៃវគ្គទី១ :

- ក ឧ. បក់, លក់, បាក់,លាក់, ...។
- ង ឧ. ចង់, លង់, ...។

(២)- ព្យញ្ជនៈដើមវគ្គ និង ព្យញ្ជនៈចុងវគ្គនៃវគ្គទី២ :

- ច ឧ. កាច់, ...។
- ញ ឧ. ចាញ់, ស្រឡាញ់, ...។

(៣)- ព្យញ្ជនៈដើមវគ្គ និង ព្យញ្ជនៈចុងវគ្គនៃវគ្គទី៤ :

- ត ឧ. បត់, គត់, បាត់, ...។
- ន ឧ. បន់, លន់, ប៉ាន់, ...។

(៤)- ព្យញ្ជនៈដើមវគ្គនៃវគ្គទី៥ :

- ប ឧ. សប់,សាប់, ...។

(៥)- ព្យញ្ជនៈ២តួក្នុងសេសវគ្គ :

- ល ឧ. ដល់, ទល់, ដាល់, ...។
- ស ឧ. អស់, លស់, ចាស់, ...។

***<u>កំណត់សម្គាល់</u>*** :

(១)- សញ្ញាបន្តក់មិនប្រើចំពោះពាក្យខ្ចីពីបាលីឬសំស្ក្រឹត ទោះបីជាមានព្យញ្ជនៈប្រកបទាំងប៉ុន្មានខាងលើក៏ដោយ ក៏គេមិនប្រើសញ្ញាបន្តក់ដែរ ដូចជា កុហក សន្ទត ជន កុសល ...។

(២)- ព្យញ្ជនៈ ជ មិនទទួលសញ្ញាបន្តក់ទេ លើកលែងតែពាក្យ *ផជ់* តែមួយគត់។

## ២- **សញ្ញាមូសិកទន្ត**(")

ជាទូទៅ សញ្ញាមូសិកទន្តប្រើសម្រាប់ដាក់លើព្យញ្ជនៈចុងវគ្គពួកអ៊ *ង ញ ន ម* និង ព្យញ្ជនៈសេសវគ្គ *យ រ ល វ* ឱ្យក្លាយជាព្យញ្ជនៈពួកអ ដូចជា៖

- ង > ង៉ ឧ. កូនង៉ែត, ...។

- ញ > ញ៉ ឧ. ឧកញ៉ា, ...។
- ន > ន៉ ឧ. ម៉េឌីន៉ា, ...។
- ម > ម៉ ឧ. ម៉ែ, ...។
- យ > យ៉ ឧ. យ៉ាប់យ៉ឺន, ...។
- រ > រ៉ ឧ. រ៉ែ, ...។
- ល > ល៉ ឧ. លើកល៉ះ, មល៉ាយូ, ...។
- វ > វ៉ ឧ. តវ៉ា, ... ។

***កំណត់សម្គាល់*** : មូសិកទន្តប្រើលើព្យញ្ជនៈ *ប* ឱ្យក្លាយទៅជា *ប៉* ដែលជាព្យញ្ជនៈពួកអ ដូច *ប* ដែរ។

***សង្កេត*** : សញ្ញាមូសិកទន្ត កាលណាគេប្រើជាមួយសញ្ញាស្រៈនិស្ស័យដែលនៅខាងលើព្យញ្ជនៈ គេត្រូវជំនួសសញ្ញាមូសិកទន្តនេះ ដោយសញ្ញាបុកជើងវិញ, ឧ. ញុាំញី, ង៉ុកង៉ក់, ...។

## ៣- សញ្ញាត្រីសព្ទ ( ៊ )

សញ្ញាត្រីសព្ទប្រើសម្រាប់ដាក់លើព្យញ្ជនៈពួក *អ* មួយចំនួន ឱ្យក្លាយជាព្យញ្ជនៈពួក *អ៊* ដូចជា៖

- ប > ប៊ ឧ. ប៊ីចេង, ...។
- ស > ស៊ ឧ. តស៊ូ, ...។
- ហ > ហ៊ ឧ. តៅហ៊ូ, ...។
- អ > អ៊ ឧ. អ៊ូអរ, ...។

*សង្កេត* : សញ្ញាត្រីសព្ទ កាលណាគេប្រើជាមួយសញ្ញាស្រៈនិស្ស័យដែលនៅខាងលើព្យញ្ជនៈ គេត្រូវជំនួសសញ្ញានេះដោយសញ្ញាបុកជើងវិញ លើកលែងតែ *ប៊* ដែលត្រូវរក្សាសញ្ញាត្រីសព្ទឱ្យនៅដដែល ដើម្បីកុំឱ្យច្រឡំនឹង *ប៉*។

## ៤- សំយោគសញ្ញា ( ័ )

សំយោគសញ្ញា ប្រើសម្រាប់សម្គាល់៖

- ស្វរ [អា៎] ឧ. ធស័ក វិស័យ រហ័ស ការិយាល័យ ...។

- សូរ [អ៊ា] ឧ. ល័ខ ភ័ក ទម័ក ...។
- សូរ [អ៊ុំ] ឧ. ជ័រ ទំព័រ ទ័ល ទ័ព ...។
- សូរ [អ៊ុ] កាលណាមានព្យញ្ជនៈ *យ* នៅខាងចុងព្យាង្គ ឧ. ជ័យ វិន័យ ភ័យ ...។

## ៥- សញ្ញាទណ្ឌឃាត ( ៍ )

សញ្ញាទណ្ឌឃាតប្រើសម្រាប់ដាក់លើតួព្យញ្ជនៈឬតួស្រៈខាងចុង ដើម្បីកាត់សូរព្យាង្គឬបន្ថយចំនួនព្យាង្គក្នុងពាក្យ ដែលភាគច្រើនមានប្រភពពីសំស្ក្រឹតនិងបាលី ដូចជា ឧបករណ៍ ប្រយោជន៍ ពោធិ៍ អាទិ៍ ...។

ក្នុងករណីពាក្យសាមញ្ញជាពាក្យខ្មែរសុទ្ធ សញ្ញាទណ្ឌឃាតមាននាទីធ្វើឱ្យព្យាង្គបិទទៅជាព្យាង្គបើក ដូចជា មក → មក៍ យក → យក៍ ...។

## ៦- សញ្ញារបាទ ( ៌ )

សញ្ញារបាទប្រើសម្រាប់ជំនួសតួ "រ" ដែលកត់សូរ[r] នៅលើអក្សរក្នុងពាក្យដែលមានប្រភពមកពីសំស្ក្រឹត ដូចជា ពណ៌នា ពិពណ៌នា ជាដើម។

លើសពីនេះទៀត ក្នុងករណីខ្លះ សញ្ញារបាទប្រើជំនួសតួ * វ* ដែលរួមបង្កើតសូរ [oa] ដូចជា ពណ៌ ធម៌ ជាដើម។

ចំពោះពាក្យដែលវចនានុក្រមអនុញ្ញាតឱ្យសរសេរពីរយ៉ាង ដូចជា ទុគ៌តឬទុរគត ទុគ៌មឬទុរគម ទុយ៌សឬទុរយស មត៌កឬមរតក ជាដើម គណៈកម្មការភាសាវិទ្យាសម្រេចឱ្យសរសេរជា ទុរគត ទុរគម ទុរយស មរតក ... បែបនេះវិញ។

## ៧- សញ្ញាវិសជ្ជនីយ៍ឬសញ្ញារះមុខ (ះ)

សញ្ញាវិសជ្ជនីឬសញ្ញារះមុខប្រើសម្រាប់ជំនួសសូរព្យញ្ជនៈចុងព្យាង្គ *ហ* ដើម្បីរួមបង្កើតសូរព្យាង្គ ដូចជាពាក្យ ត្រិះរិះ[trehrih], គ្រឹះ[krɯh], ចង្កឹះ[cɒŋkoeh], ប្រែះ[craɛh], កែះ [kaɛh] ជាដើម។

## ៨- សញ្ញានិគ្គហិតឬសញ្ញាដំលើ( ំ)

សញ្ញានិគ្គហិតឬសញ្ញាដំលើប្រើសម្រាប់ជំនួសសូរព្យញ្ជនៈចុងព្យាង្គ ង ដើម្បីរួមបង្កើតសូរព្យាង្គក្នុងពាក្យដែលមានប្រភពពីបាលីសំស្ក្រឹត ដូចជា សំស្ក្រឹត សំយោគ អ្នកសច្ចំ មំសាសី មំសាសត្វ ហឹសា ហនេយ្យំ ...។

## ៩- សញ្ញាយុគលពិន្ទុឬសញ្ញាចុចពីរ( ះ)

សញ្ញាយុគលពិន្ទុប្រើសម្រាប់កត់ត្រាសូរ [អាក់ឬអ៊ាក់] នៃព្យាង្គរបស់ពាក្យដែលខ្ចីពីបាលី សំស្ក្រឹត ដូចជា កុម្ភៈ, ខណៈ, ឋានៈ, ទុក្ករៈ, ធុរៈ, នរៈ, ព្យញ្ជនៈ ...។

ជាទូទៅ គេលុបសញ្ញាយុគលពិន្ទុក្នុងពាក្យផ្សំមួយចំនួន ដូចជា មរណភាព, ភារកិច្ច, ធុរជន, វុក្ខជាតិ, គណបក្ស, រតនគិរី, លក្ខណសម្បត្តិ។ល។

<u>កំណាត់សម្គាល់</u> :

គេរក្សាសញ្ញាយុគលពិន្ទុក្នុងពាក្យផ្សំមួយចំនួន ដូចជា កាលៈទេសៈ, គណៈកម្មការ, គណៈកម្មាធិការ, គណៈរដ្ឋមន្ត្រី, គណៈសង្ឃ, គណៈប្រតិភូ, នរៈនារី, រយៈពេល, វារៈវិនបត, ... ។

# ផ្នែកទី២
# វចនវិទ្យា

# បញ្ញត្តិមូលដ្ឋាន

វចនវិទ្យាជាផ្នែកមួយនៃភាសាវិទ្យាដែលសិក្សាអំពីវចនសព្ទ ដោយរួមបញ្ចូលទាំងការបង្កើតពាក្យ ប្រភេទពាក្យ ទម្រង់ពាក្យ ជាដើម។

### ១- វចនសព្ទ

វចនសព្ទជាពាក្យឬកម្រងពាក្យដែលជាឯកតាភាសា ដូចជា ផ្ទះ ដើរ ល្អ ស្បែកជើង ...។

### ២- វចនប្រភេទ

ពាក្យត្រូវបានបែងចែកជាច្រើនវចនប្រភេទ ដូចតទៅ៖ ពាក្យកម្លាយ ពាក្យបន្សំ(ពាក្យសមាស) ...។

## I- ការបង្កើតពាក្យ

ដើម្បីបង្កើតពាក្យ ជាទូទៅ គេប្រើវិធីកម្លាយ វិធីស្ទើរកម្លាយ វិធីស្ទើរបន្សំ វិធីបន្សំ វិធីសមាស វិធីរូប-សទ្ទតា ...។

### ១- វិធីកម្លាយ

វិធីកម្លាយជាវិធីបង្កើតពាក្យដោយប្រើផ្នត់(ផ្នត់ដើម ផ្នត់ដែក) ហើយ ជួនកាល គេក៏មានប្រើកាឡារូបរបស់ផ្នត់ខ្លះផងដែរ។

### ០- ផ្នត់និងកាឡារូប

ផ្នត់គឺជាកន្ទេចពាក្យ[១៦]ដែលឥតមានអត្ថិភាពជាពាក្យឯករាជ្យក្នុងភាសាខ្មែរ ហើយ មានរូបនឹងនរនិងមានន័យនឹងនរ[១៧]លើកលែងតែមានការវិវត្តសូរនិងការវិវត្តន័យចំពោះផ្នត់ខ្លះ។ ទោះផ្នត់គ្មានអត្ថិភាពជាពាក្យឯករាជ្យក្នុងភាសាខ្មែរក្តី ក៏ខ្មែរទូទៅបានស្គាល់និងអាចប្រើប្រាស់សម្រាប់

[១៦] «កន្ទេចពាក្យ» នេះ ខ្ចីពីលោក អៀវ កើស : ***ភាសាខ្មែរ***, បណ្ណាគារ មិត្តសេរី, ភ្នំពេញ ១៩៦៧, ទំព័រ១៦៨។

[១៧] ផ្នត់ពីរ(ឬលើសពីពីរ) ដែលមានរូបដូចគ្នា តែសម្គាល់បញ្ញត្តិផ្សេងគ្នា គឺជាសទិសសូរវេយ្យាករណ៍វិស័យ (homonymie grammaticale) ដូចជា ផ្នត់ដែក [-ɒm-/-ɔm-]([-អ'ម-/-អ៊'ម-]) ជាដើម ដែលប្រើសម្រាប់បង្កើតកិរិយាហេតុផង, ឧ. ត្រូវ + [-អ'ម-] > តម្រូវ, សម្រាប់បង្កើតពាក្យសម្គាល់ឧបករណ៍ផង, ឧ. គ្រប + [-អ៊'ម-] > គម្រប និង សម្រាប់បង្កើតពាក្យសម្គាល់លទ្ធផលផង, ឧ. ក្រង + [-អ'ម-] > កម្រង។

ដាក់ភ្ជាប់ជាមួយពាក្យឫសក្នុងភាសាខ្មែរ(ឬពាក្យកម្ចីដែលចូលស៊ប់ក្នុងភាសាខ្មែរ) ដើម្បីបង្កើតពាក្យកម្លាយ។

### ០.១ - ផ្នត់ដើម

ផ្នត់ដើមគឺជាផ្នត់ដែល ក្នុងកម្លាយពាក្យ គេយកទៅដាក់ជាប់ខាងឆ្វេងពាក្យឫស ដូចជា៖
- [ប៉-] + ដឹង > ប្ដឹង,
- [ប៉-] + ដូរ > ប្ដូរ ...។

### ០.២- ផ្នត់ដែក

ផ្នត់ដែកគឺជាផ្នត់ដែល ក្នុងកម្លាយពាក្យ គេយកទៅដាក់ញែកពាក្យឫស ដូចជា កើយ + [-ន-] > ខ្នើយ, ជួញ + [-ម-] > ឈ្មួញ, ...។

### ០.៣- កាឡារូប

កាឡារូប គឺការប្រែប្រួលនៃរូបដើមរបស់ផ្នត់ណាមួយ(តិចឬច្រើន)ទៅតាមករណី/បរិបទ ដូចជា ផ្នត់ /ប៉-/ ដែល ក្នុងការនិយាយស្ដី ខ្មែរយើងប្រើសម្រាប់បង្កើតកិរិយាហេតុជាច្រើន, ឧ. ប៉ដឹង, ប៉យ្ឃូរ, ប៉ខំ, ប៉ចូល, ប៉ស៊ី, ប៉បួស, ... ដែល ក្នុងអក្ខរាវិរុទ្ធ បុព្វបុរសយើងសរសេរដូចនេះ៖ ប្ដឹង[១៨], ព្យួរ, បង្ខំ, បញ្ចូល, បន្ស៊ី, បំបួស, ... ទៅវិញ។ យើងគិតថា /ប៉/ ជារូបដើមនៃផ្នត់ដើមសម្រាប់បង្កើតកិរិយាហេតុជាច្រើន រីឯរូបស្រដៀងគ្នានេះ ដូចជា [ផ-], [ព-], [ក-], [ប'ង-/ព'ង-], [ប'ញ-], [ប'ន-/ព'ន-], [ប'ម-], ... ជាកាឡារូបរបស់/ប៉/។

## ១.១- ពាក្យកម្លាយសម្គាល់កិរិយាហេតុ

### ១.១.១- កិរិយាហេតុកម្លាយចេញពីកិរិយាសកម្មឬអកម្ម[១៩]ដែលកើតពីព្យញ្ជនៈទោល

ផ្នត់ដែលចូលរួមក្នុងការបង្កើតកិរិយាហេតុ កម្លាយចេញពីកិរិយាសកម្មឬអកម្ម ដែលកើតពីព្យញ្ជនៈទោលមាន៖

---

[១៨] សញ្ញាព្យញ្ជនៈ «ប» ខ្មែរមានសូរពីរ គឺ [ប] ផង ដូចក្នុងពាក្យ បង, បុក, បាន, ... និង [ប៉] ផង ដូចក្នុងពាក្យ ប្ដឹង, ប្រុង, ឧបាជ, ឧបទ្វីប ជាដើម។

[១៩] ពាក្យឫសច្រើនលើសលប់ដែលជាប្រកពនៃកិរិយាហេតុ ជាកិរិយាអកម្ម។

### ១.១.១.១- ផ្នត់ [ប៉]និងកាឡូរូបរបស់វា

**(១)- ផ្នត់ដើមទម្រង់ [ព-]**

ផ្នត់ដើមទម្រង់[ព-]មាន [ប៉-], [ផ-], [ព-] និង [ភ-]៖

**(១.១)- ផ្នត់ដើម** [ប៉-]

- [ប៉-] + ដឹង > ប្ដឹង
- [ប៉-] + ដូរ > ប្ដូរ[២០]
- [ប៉-] + រាប > ប្រាប[២១]...។

**(១.២)- ផ្នត់ដើម [ផ-]**

- [ផ-] + គាប់ > ផ្គាប់
- [ផ-] + ចាញ់ > ផ្ចាញ់
- [ផ-] + ទញ់ > ផ្ទញ់
- [ផ-] + ទឹម > ផ្ទឹម
- [ផ-] + សាយ > ផ្សាយ
- [ផ-] + អាប់ > ផ្អាប់ ...។

**(១.៣)- ផ្នត់ដើម [ព-]**

- [ព-] + យួរ > ព្យួរ ...។

**(១.៤)- ផ្នត់ដើម [ភ-]**

- [ភ-] + ងើយ > ភ្ងើយ

---

[២០] ក្នុងកន្សោមព្យញ្ជនៈ ព្យញ្ជនៈទី១ដែលជាសូរទោលត្រូវបានគេអានជាសូរផ្សំវិញ ដូចជាពាក្យ ក្លាហាន [kla:ha:n] គេអានថា ខ្លាហាន[khla:ha:n] ជាដើម។

[២១] តាមវចនានុក្រមខ្មែរ ពាក្យ *ប្រាប* នេះមានន័យថា«ធ្វើឱ្យរាប, ឱ្យបាក់បប, ឱ្យចុះចាញ់ : ប្រាបសត្រូវ, ...។

- [ក-] + ជាប់ > ក្ជាប់

- [ក-] + ញាស់ > ក្ញាស់ ... ។

**(២)- ផ្នត់ដើមទម្រង់ [ពសព-]**

ផ្នត់ដើមទម្រង់[ពសព-]មាន [ប់ង-/ព់ង-], [ប់ញ-], [ប់ន-/ព់ន-], [ប់ម-]៖

**(២.១)- ផ្នត់ដើម [ប់ង-/ព់ង-]**

- [ប់ង-] + កើត > បង្កើត

- [ប់ង-] + ខំ > បង្ខំ

- [ប់ង-] + គេច > បង្គេច

- [ប់ង-] + ហាត់ > បង្ហាត់

- [ប់ង-] + អាប់ > បង្អាប់

- [ព់ង-] + រាប > ពង្រាប

- [ព់ង-] + វក់ > ពង្វក់ ...។

**(២.២)- ផ្នត់ដើម [ប់ញ-]**

- [ប់ញ-] + ចុក > បញ្ចុក

- [ប់ញ-] + ជិះ > បញ្ជិះ

- [ប់ញ-] + ឈឺ > បញ្ឈឺ ...។

**(២.៣)- ផ្នត់ដើម [ប់ន-/ព់ន-]**

- [ប់ន-] + ដើរ > បណ្ដើរ

- [ប់ន -] + ថយ > បន្ថយ

- [ប់ន-] + ទន់ > បន្ទន់

- [ប់ន-] + លី > បន្លី
- [ប់ន-] + ស៊ី > បន្ស៊ី
- [ព់ន-] + លិច > ពន្លិច
- [ព់ន-] + លើស > ពន្លើស
- [ព់ន-] + យល់ > ពន្យល់ ...។

**(២.៤)- ផ្នត់ដើម [ប់ម-]** ដែល ក្នុងការសរសេរ បុព្វបុរសយើងផ្លាស់មកជា «បំ», ឧទាហរណ៍ :

- [ប់ម-] + បាក់ > បំបាក់
- [ប់ម-] + ផឹក > បំផឹក
- [ប់ម-] + ពើង > បំពើង
- [ប់ម-] + ភ័យ > បំភ័យ ...។

### ១.១.១.២- ផ្នត់ដើម [ប៉-][២២]

ផ្នត់ដើម[ប៉-]មានទម្រង់[ពស-], ឧ. [ប៉-] + ប៉ះ > ប៉ប៉ះ ...។

### ១.១.១.៣- ផ្នត់ដើម [ប្រ-]

ផ្នត់ដើម[ប្រ-]មានទម្រង់[ពពស-], ឧ. [ប្រ-] + មូល > ប្រមូល ...។

**១.១.១.៤- ផ្នត់ដើមទម្រង់[ពសព-] មាន [រ់ម-]** ដែល ក្នុងការសរសេរ បុព្វបុរសយើងផ្លាស់មកជា «រំ», ឧទាហរណ៍ :

- [រ់ម-] + កិល > រំកិល
- [រ់ម-] + លេប > រំលេប
- [រ់ម-] + ហួត > រំហួត ...។

---

[២២] [ប៉] នេះប្លែកពី[ប៉] ប្រើក្នុង«ប្ដឹង» ជាដើម ពីព្រោះ ក្នុងពាក្យ«ប្ដឹង» [ប៉][p] ជាព្យញ្ជនៈដើមនៃកន្សោមព្យញ្ជនៈ [ប្ដ-][pd-](ដែលឥតមានស្រៈកប់តួ) រីឯ [ប៉]នៅទីនេះ គឺជា[ប៉] មានស្រៈកប់តួ[ɒː]។

**១.១.១.៥- ផ្នត់ដើមទម្រង់[ពសព-]មាន [ដ់ម-]** ដែល ក្នុងការសរសេរ បុព្វបុរសយើងផ្លាស់មកជា «ដំ», ឧ. **[ដ់ម-]** + ឡើង > ដំឡើង[២៣]។

### ១.១.២- កិរិយាហេតុកម្លាយចេញពីកិរិយាសព្ទដែលកើតពីកន្សោមព្យញ្ជនៈ(ព្យញ្ជនៈផ្សំ)

ផ្នត់ប្រើក្នុងការបង្កើតកិរិយាហេតុកម្លាយចេញពីកិរិយាសព្ទដែលកើតពីកន្សោមព្យញ្ជនៈ មានដូចខាងក្រោម៖

**(១)- ផ្នត់ដើមទម្រង់ [ពសព-]**

ផ្នត់ដើមទម្រង់[ពសព-]មាន [ប់ង-], [ប់ញ-], [ប់ម-]៖

**(១.១)- ផ្នត់ដើម [ប់ង-]**

- [ប់ង-] + គ្រប់ > បង្គ្រប់
- [ប់ង-] + ឃ្លាត > បង់ឃ្លាត ...។

**(១.២)- ផ្នត់ដើម [ប់ញ-]**

- [ប់ញ-] + ជ្រោះ > បញ្ជ្រោះ
- [ប់ញ-] + ជ្រាប > បញ្ជ្រាប ...។

**(១.៣)- ផ្នត់ដើម [ប់ម-]** ដែល ក្នុងការសរសេរ បុព្វបុរសយើងផ្លាស់មកជា«បំ», ឧទាហរណ៍ :

- [ប់ម-] + ព្រាត់ > បំព្រាត់
- [ប់ម-] + ភ្លេច > បំភ្លេច
- [ប់ម-] + ភ្លឺ > បំភ្លឺ ...។

**(២)- ផ្នត់ដែកទម្រង់ [-សព-]**

ផ្នត់ដែកទម្រង់[-សព-]មាន [-អ់ម-/-អ៊ំម-], ឧទាហរណ៍ :

- ត្រូវ + [-អ់ម-] > តម្រូវ
- ច្រើន + [-អ់ម-] > ចម្រើន
- ជ្រះ + [-អ៊់ម-] > ជម្រះ

---

[២៣] យើងសង្កេតឃើញថា ផ្នត់ដើម [ដំ-] ត្រូវបានប្រើតែក្នុងពាក្យ *ដំឡើង* មួយប៉ុណ្ណោះ។ បើយើងសរសេរ **តម្លើង* ហើយ ចាត់ទុកថាជាពាក្យកម្លាយចេញពី *ល្ងើង* (ដែលមានន័យថា អ្នកដែលឡើងចាង, ដែល ព្រហើន,មហាត) យើងអាចបញ្ចូលពាក្យ *តម្លើង* នេះ ក្នុងក្រុម *តម្រូវ, ចម្រើន, តម្លា, ជម្រះ, ទម្លាយ, ទម្លុះ*, ...។

- ធ្លាយ + [-អ៊ំម-] > ទម្លាយ

- ធ្លុះ + [-អ៊ំម-] > ទម្លុះ ...។

<u>**តារាងសរុប បង្ហាញការបង្កើតពាក្យសម្គាល់កិរិយាហេតុ**</u>

| ពាក្យកម្លាយ / ពាក្យឫស | ១ | ២ | ៣ | ៤ | ៥ | ៦ |
|---|---|---|---|---|---|---|
| | [ប៉-]និងកាឡាវូប | [ប៉-] ទម្រង់[ពស-] | [ប្រ-] | [រំម-] | [-អំម-/ -អ៊ំម-] | [ជំម-] |
| កិល | | | | រំកិល | | |
| កើត | បង្កើត | | | | | |
| ខាន | | | | រំខាន | | |
| ខំ | បង្ខំ | | | | | |
| គេច | បង្គេច | | | | | |
| គាប់ | ផ្គាប់ | | | | | |
| គ្រប់ | បង្គ្រប់ | | | | | |
| ឃ្លាត | បង់ឃ្លាត | | | | | |
| ច្រោះ | បញ្ច្រោះ | | | | | |
| ជ្រាប | បញ្ជ្រាប | | | | | |
| ងើយ | ភ្ងើយ | | | | | |
| ចាញ់ | ផ្ចាញ់ | | | | | |
| ចុក | បញ្ចុក | | | | | |
| ច្រើន | | | | | ចម្រើន | |
| ជាប់ | ភ្ជាប់ | | | | | |
| ជិះ | បញ្ជិះ | | | | | |
| ជ្រះ | | | | | ជម្រះ | |
| ឈឺ | បញ្ឈឺ | | | | | |
| ញាស់ | ភ្ញាស់ | | | | | |
| ដឹង | ប្តឹង | | | | | |

| | | | | | | |
|---|---|---|---|---|---|---|
| ដើរ | បណ្ដើរ | | | | | |
| ដូរ | ប្ដូរ | | | | | |
| ត្រូវ | | | | | តម្រូវ | |
| ថយ | បន្ថយ | | | | | |
| ទន់ | បន្ទន់ | | | | | |
| ទឹម | ផ្ទឹម | | | | | |
| ធ្លាយ | | | | | ទម្លាយ | |
| ធ្លុះ | | | | | ទម្លុះ | |
| បាក់ | បំបាក់ | | | | | |
| ប៉ះ | | ប៉ប៉ះ | | | | |
| ផឹក | បំផឹក | | | | | |
| ពើង | បំពើង | | | | | |
| ភ័យ | បំភ័យ | | | | | |
| ភ្លេច | បំភ្លេច | | | | | |
| មូល | | | ប្រមូល | | | |
| យល់ | ពន្យល់ | | | | | |
| យួរ | ព្យួរ | | | | | |
| រសាយ | | | | | រំសាយ | |
| រាប | ប្រាប | | | | | |
| វក់ | ពង្វក់ | | | | | |
| លី | បន្លី | | | | | |
| លិច | ពន្លិច | | | | | |
| លេប | | | | រំលេប | | |
| លើស | ពន្លើស | | | | | |
| សាយ | ផ្សាយ | | | | | |
| ស៊ី | បន្ស៊ី | | | | | |
| ហាត់ | បង្ហាត់ | | | | | |
| ហួត | | | | រំហួត | | |
| ឡើង | | | | | | ដំឡើង |
| អាប់ | ផ្អាប់,<br>បង្អាប់ | | | | | |

## ១.២- ពាក្យកម្លាយសម្គាល់លទ្ធផលឬភាព

ដើម្បីបង្កើតពាក្យកម្លាយសម្គាល់លទ្ធផលឬភាព គេប្រើ៖

**១- ផ្នត់ដែក [-អម.ណ-/-អ៊ម.ន-], ឧទាហរណ៍** :

- កាត់ + [-អម.ណ-] > កំណាត់
- ចាស់ + [-អម.ណ-] > ចំណាស់
- ដឹង + [-អម.ណ-] > ដំណឹង
- បិទ + [-អម.ណ-] > បំណិទ
- អរ + [-អម.ណ-] > អំណរ
- គួរ + [-អ៊ម.ន-] > គំនួរ
- ទាក់ទង( ទាក់ + [-អ៊ម.ន-] > ទំនាក់ និង ទង + [-អ៊ម.ន-] > ទំនង) :
  ទំនាក់ + ទំនង > ទំនាក់ទំនង
- ពិត + [-អ៊ម.ន-] > ពំនិត ...។

**២- ផ្នត់ដែក [-ប-][២៤] ប្រើជាមួយព្យញ្ជនៈ យ រ ល, ឧទាហរណ៍** :

- លាស់ + [-ប-] > ល្បាស់
- លេង + [-ប-] > ល្បេង > ល្បែង
- យល់ + [-ប-] > យ្បល់ > យោបល់
- យំ + [-ប-] > យ្បំ > យោបំ
- រក + [-ប-] > ប្រក > របក
- រៀប + [-ប-] > ប្រៀប > របៀប
- រាំ + [-ប-] > ប្រាំ > របាំ ...។

---

[២៤] តាមលោកគ្រូ សូ មុយឃៀង ផ្នត់ដែក [-ប-] មានកាឡូរូបពីរ គឺ [-អ៊.ប-] សម្រាប់ប្រើជាមួយពាក្យដើមកើតពីព្យញ្ជនៈ *រ* និង កាឡូរូប[-អោ.ប-] សម្រាប់ប្រើជាមួយពាក្យឫសកើតចេញពីព្យញ្ជនៈ *យ* ។
ចំពោះប្រធាននៃគណៈកម្មការភាសាវិទ្យានិងលោកគ្រូ នៅ ស៊ុន ពាក្យកម្លាយ យល់ > យ្បល់ > យោបល់ និង ពាក្យកម្លាយ រៀប > ប្រៀប > របៀប វាគ្រាន់តែជាការសម្រួលសូរ/បម្រែសូរ មិនខុសគ្នាអ្វីពីពាក្យកម្លាយ គួរ + [-អ៊ម.ន-] > [គអ៊មនួរ] (គម់នួរ ) > [គុមនួរ] (សរសេរ : [គំនួរ]) ដែលមានបម្រែបម្រួលសូរតាមការវិវត្តនោះឡើយ។

## ៣- ផ្នត់ដែក[-អម-/-អឹម-] និង កាឡូរូប ដូចជា [-អង-/-អឹង-] ... មានការប្រើប្រាស់ ដូចតទៅ៖

### ៣.១- ផ្នត់ដែក [-អម-/-អឹម-]

៣.១.១- ប្រើជាមួយពាក្យឫសកើតចេញពីសញ្ញាព្យញ្ជនៈទោលដែលកត់សូរផ្សំ( ខ = ក + ហ > ក្ហ, ឆ = ច + ហ > ច្ហ, ឈ = ជ + ហ > ជ្ហ, ឃ = គ + ហ > គ្ហ, ...), ឧទាហរណ៍ :

- ខឹង + [-អម-] > កំហឹង
- ឆេះ + [-អម-] > ចំហេះ
- ឈាន + [-អឹម-] > ជំហាន
- ឈឺ + [-អឹម-] > ជំហឺ > ជំងឺ[២៥]
- (រក)ឃើញ + [-អឹម-] > (របក)គំហើញ ...។

៣.១.២- ប្រើជាមួយពាក្យឫសកើតចេញពីកន្សោមព្យញ្ជនៈ, ឧទាហរណ៍ :

- ក្រ + [-អម-] > កម្រ
- គ្រេច + [-អឹម-] > គម្រេច
- ឆ្ងាយ + [-អម-] > ចម្ងាយ
- ត្រា + [-អម-] > តម្រា
- ធ្លាប់ + [-អឹម-] > ទម្លាប់
- ប្រាម + [-អម-] > បម្រាម
- ស្ដើង + [-អម-] > សម្ដើងឬសំដើង
- ល្អ + [-អឹម-] > លម្អឬលំអ
- ល្ហ + [-អឹម-] > លម្ហឬលំហ ...។

---

[២៥] ពាក្យ ជំងឺ < ជំហឺ : ជាលទ្ធផលនៃបម្រែបម្រួលសូរ។

**៣.២- ផ្នត់ជែក[-អង-/-អ៊ង-], [-អណ-/-អ៊ន-] ... , ឧទាហរណ៍ :**

- ធ្វើ + [-អ៊ង-] > ទង្វើ
- ថ្វាយ + [-អង-] > តង្វាយ
- ព្រោះ + [-អ៊ង-] > ពង្រោះ
- ប្ដឹង + [-អណ-] > បណ្ដឹង
- ស្ដាប់ + [-អណ-] > សណ្ដាប់
- ផ្ដាំ + [-អណ-] > បណ្ដាំ
- ភ្លឺ + [-អ៊ន-] > ពន្លឺ
- ភ្លូក + [-អ៊ន-] > ពន្លូក ...។

**៤- ផ្នត់ជែក [-ន-], ឧទាហរណ៍** :

- ធូត + [-ន-] > ធ្នូត
- ដើរ + [-ន-] > ថ្នើរ
- បួស + [-ន-] > ផ្នួស
- ពែន + [-ន-] > ភ្នែន ...។

**៥- ផ្នត់ដើម [លម-] ប្រើជាមួយពាក្យឫសកើតចេញពីព្យញ្ជនៈនាសិកជៈនិងព្យញ្ជនៈ ហ, ឧទាហរណ៍** :

- [លម-] + ញ័រ > លំញ័រ
- [លម-] + នាច > លំនាច
- [លម-] + នឹង > លំនឹង
- [លម-] + នាំ > លំនាំ
- [លម-] + ហាត់ > លំហាត់ ...។

**៦- ផ្នត់ដើម [អម-], ឧទាហរណ៍** :

- [អម-] + បុក > អំបុក
- [អម-] + វែក > អំវែក ...។

# តារាងសរុប បង្ហាញការបង្កើតពាក្យសម្គាល់លទ្ធផលឬភាព

| ពាក្យកម្លាយ / ពាក្យឫស | ១ | ២ | ៣ | ៤ | ៥ | ៦ |
|---|---|---|---|---|---|---|
| | [-អំ.ណ-/-អុំ.ន-] | [-ប-] | [-អំ-/-អុំ-] និង កាឡាវូប | [-ន-] | [លំ-] | [អំ-] |
| កាត់ | កំណាត់ | | | | | |
| គួរ | គំនួរ | | | | | |
| ចាស់ | ចំណាស់ | | | | | |
| ជិះ | ជំនិះ | | | | | |
| តាង | តំណាង | | | | | |
| ទាប | ទំនាប | | | | | |
| ទាក់ទង | ទំនាក់ទំនង | | | | | |
| បិទ | បំណិទ | | | | | |
| ពិត | ពំនិត | | | | | |
| ស្ងក | សំណួក | | | | | |
| អរ | អំណរ | | | | | |
| លាស់ | | ល្បាស់ | | | | |
| លេង | | ល្បែង | | | | |
| យល់ | | យោបល់ | | | | |
| យំ | | យោបំ | | | | |
| រៀប | | របៀប | | | | |
| រាំ | | របាំ | | | | |
| ខឹង | | | កំហឹង | | | |
| ឆេះ | | | ចំហេះ | | | |
| ឈាន | | | ជំហាន | | | |
| (រក)ឃើញ | | | (របក)គំហើញ | | | |
| ធាត់ | | | ទំហាត់ | | | |
| ក្រុ | | | កម្រុ | | | |
| គ្រេច | | | គម្រេច | | | |
| ឆ្ងាយ | | | ចម្ងាយ | | | |
| ត្រា | | | តម្រា | | | |
| ធ្លាប់ | | | ទម្លាប់ | | | |

| | | | | | | |
|---|---|---|---|---|---|---|
| ប្រាម | | | បម្រាម | | | |
| ស្ទើង | | | សម្ទើង | | | |
| ល្អ | | | លម្អឬលំអ | | | |
| ល្ហ | | | លម្ហឬលំហ | | | |
| ផ្ញើ | | | ទង្ញើ | | | |
| ថ្វាយ | | | តង្វាយ | | | |
| គ្រោះ | | | ពង្រោះ | | | |
| ប្ដឹង | | | បណ្ដឹង | | | |
| ស្ដាប់ | | | សណ្ដាប់ | | | |
| ផ្ដាំ | | | បណ្ដាំ | | | |
| ភ្លឺ | | | ពន្លឺ | | | |
| ភ្លូក | | | ពន្លូក | | | |
| ឆ្ងូត | | | | ឆ្នូត | | |
| ជើរ | | | | ថ្នើរ | | |
| បួស | | | | ផ្នួស | | |
| ពែន | | | | ភ្នែន | | |
| ញ័រ | | | | | លំញ័រ | |
| នាច | | | | | លំនាច | |
| នឹង | | | | | លំនឹង | |
| នាំ | | | | | លំនាំ | |
| ហាត់ | | | | | លំហាត់ | |
| បុក | | | | | | អំបុក |
| វែក | | | | | | អំវែក |

## ១.៣- ពាក្យកម្លាយសម្គាល់ឧបករណ៍

### ១.៣.១- ពាក្យកម្លាយសម្គាល់ឧបករណ៍ដែលកើតពីព្យញ្ជនៈទោល

ផ្នត់ដែលចូលរួមក្នុងការបង្កើតពាក្យកម្លាយសម្គាល់ឧបករណ៍ដែលកើតពីព្យញ្ជនៈទោល មាន៖

**(១)- ផ្នត់ដែក[-ន-]និងកាឡារូប, ឧទាហរណ៍ :**

- កោស + [-ន-] > ខ្នោស
- ចុក + [-ន-] > ឆ្នុក
- ចាំ + [-ន-] > ឆ្នាំ[២៦]
- ដាក់ + [-ន-] > ថ្នាក់
- ដោល + [-ន-] > ថ្នោល
- គាប + [-ន-] > ឃ្នាប
- ជាន់ + [-ន-] > ឈ្នាន់
- ទឹម + [-ន-] > ធ្នឹម
- រាស់ + [-អ៊.ន-] > រនាស់ ...។

**<u>កំណត់សម្គាល់</u> : ពាក្យសម្គាល់ឧបករណ៍ខ្លះដែលកើតចេញពីផ្នត់ដែក [-ន-] ត្រូវបានគេសម្រួលអំណានដោយបន្ថែមអាគម [រ][២៧] ដូចជា ដោត + [-ន-] > ត្នោត > ត្រណោត, ជង់ + [-ន-] > ជ្នង់ > ជ្រនង់[២៨], ទំ + [-ន-] > ទ្នំ > ទ្រនំ, ...។**

**<u>សង្កេត</u> : ពាក្យ ទ្រនួល នឹង ត្រណម មិនសម្គាល់ឧបករណ៍ទេ។**

---

[២៦] តាមលោកគ្រូ ឡុង សៀម ដែលជាអ្នកជំនាញខាងខ្មែរបុរាណ ដែលបានតាមដានពាក្យ«ឆ្នាំ»នេះ តាំងពីកំណើតមក ពាក្យនេះមានន័យថា«ឧបករណ៍សម្រាប់ចងចាំ»។

[២៧] ធាតុ /-រ-/ ដែលមានក្នុងពាក្យ ជ្រនង់, ត្រណោត, ទ្រនំ, ... មិនមែនជាកាឡារូបចេញពីផ្នត់ណាមួយទេ តែជាសូរសម្រាប់សម្រួលអំណានតែប៉ុណ្ណោះ។ ជាតុបែបនេះមានក្នុងភាសាជាច្រើនក្នុងលោក ហើយ ក្នុងភាសាបាលី គេហៅថា *អាគម* ដែលត្រូវនឹងភាសាបារាំង épenthèse (ឧ. ចតុ + អង្គ > ចតុអង្គ > ចតុរង្គ)៖ យើងសុំប្រើពាក្យសព្ទ *អាគម* នេះ សម្រាប់សៀវភៅវេយ្យាករណ៍នេះផងដែរ។

[២៨] ជ្រនង់មានន័យពីរ គឺ ១ : ឧបករណ៍; ២ : សាច់ដែលគេដោតជង់។

**(២)- ផ្នត់ជែក [-អម.ណ-]/[-អិម.ន-] , ឧទាហរណ៍ :**

- ចង + [-អម.ណ-] > ចំណង
- ជិះ + [-អិម.ន-] > ជំនិះ ...។

**(៣)- ផ្នត់ដើម [ រ- ], ឧទាហរណ៍ :**

- [ រ-] + បុក > របុក
- [ រ-] + បាំង > របាំង ... ។

**(៤) - ផ្នត់ដើម [អម-/អិម-]និងកាឡារូប, ឧទាហរណ៍ :**

- [អម-] + បោស > អម្បោស/អំបោស ...។
- [អង-] + រុត > អង្រុត
- [អង-] + រូស > អង្រូស
- [អញ-] + ជុល > អញ្ជុល
- [អន-] + ទាក់ > អន្ទាក់
- [អន-] + លីង > អន្លីង ... ។

**(៥)- ផ្នត់ដើម [រម-]និងកាឡារូប, ឧទាហរណ៍** :

- [រម-] + វាត់ > រំវាត់ > រំពាត់
- [រង-] + វាល់ > រង្វាល់
- [រង-] + វាស់ > រង្វាស់ ... ។

### ១.៣.២- ពាក្យកម្លាយសម្គាល់ឧបករណ៍ដែលកើតពីកន្សោមព្យញ្ជនៈ(ព្យញ្ជនៈផ្សំ)

ផ្នត់ដែលចូលរួមក្នុងការបង្កើតពាក្យកម្លាយសម្គាល់ឧបករណ៍ដែលកើតពីកន្សោមព្យញ្ជនៈ មាន៖

**ផ្នត់ជែក [-អម-/-អិម-]និងកាឡារូប, ឧទាហរណ៍ :**

- ច្រូង + [-អម-] > ចម្រូង
- ទ្រ + [-អិម-] > ទម្រ

- ក្លាស់ + [-អន-]  > កន្លាស់

- ស្ទះ  + [-អន-]  > សន្ទះ

- ស្លង់  + [-អន-]  > សន្លង់

- ថ្លឹង  + [-អ៊ន-]  > ទន្លឹង

- ទ្រាប់ + [-អ៊.ន-]  > ទ្រនាប់

- ទ្រ  + [-អ៊.ន-]  > ទ្រ-ន(ទ្វីប) ...។

## តារាងសរុប បង្ហាញការបង្កើតពាក្យសម្គាល់ឧបករណ៍

| ពាក្យកម្លាយ / ពាក្យឫស | ១ | ២ | ៣ | ៤ | ៥ | ៦ |
|---|---|---|---|---|---|---|
| | [-ន-] និង កាឡាវូប, [-ន-]ផ្សំនឹង អាគម [រ] | [-អម.ណ-] | [រ-] | [អម-/អ៊ម-] និងកាឡាវូប | [រម-] | [-អម-/-អ៊ម-] និង កាឡាវូប |
| កោស | ខ្នោស | | | | | |
| បុក | ផ្នុក | | | | | |
| ចាំ | ឆ្នាំ | | | | | |
| ដាក់ | ថ្នាក់ | | | | | |
| ដោល | ថ្នោល | | | | | |
| គាប | ឃ្នាប | | | | | |
| ជាន់ | ឈ្នាន់ | | | | | |
| ទឹម | ថ្នឹម | | | | | |
| រាស់ | រនាស់ | | | | | |
| ដោត | ត្រណោត | | | | | |
| ជង់ | ជ្រនង់ | | | | | |
| ទំ | ថ្នំ >ទ្រនំ | | | | | |
| បង | | បំណាង | | | | |
| បុក | | | របុក | | | |
| បាំង | | | របាំង | | | |

| | | | | | | |
|---|---|---|---|---|---|---|
| បោស | | | | អម្បោសឬ អំបោស | | |
| រុត | | | | អង្រុត | | |
| រូស | | | | អង្រូស | | |
| ជុល | | | | អញ្ចុល | | |
| ទាក់ | | | | អន្ទាក់ | | |
| លីង | | | | អន្លីង | | |
| វាត់ | | | | | រំពាត់ | |
| វាល់ | | | | | រង្វាល់ | |
| វាស់ | | | | | រង្វាស់ | |
| ច្រូង | | | | | | ចម្រូង |
| ទ្រ | | | | | | ទម្រ |
| ក្លាស់ | | | | | | កន្លាស់ |
| ស្ទះ | | | | | | សន្ទះ |
| ស្លង់ | | | | | | សន្លង់ |
| ថ្លឹង | | | | | | ទន្លឹង |
| ទ្រាប់ | | | | | | ទ្រនាប់ |
| ទ្រ | | | | | | ទ្រ-ន |

## ១.៤- ពាក្យកម្លាយសម្គាល់នាមភ្នាក់ងារឬនាមការក៍

ដើម្បីបង្កើតពាក្យកម្លាយសម្គាល់នាមភ្នាក់ងារឬនាមការក៍ គេប្រើះ

(១)- **ផ្នត់ដែក [-ម-], ឧទាហរណ៍** :

- កាន់ + [-ម-] > ខ្មាន់
- ចាំ + [-ម-] > ឆ្មាំ
- ជួញ + [-ម-] > ឈ្មួញ
- ដើរ + [-ម-] > ថ្មើរ
- សូន + [-ម-] > ស្មូន
- ទាក់ + [-រ.ម-] > ទ្មាក់ > ទ្រមាក់
- បង់ + [-រ.ម-] > ប្មង់ > ប្រមង់

- បាញ់ + [-រ.ម-] > ប្មាញ់ > ប្រមាញ់
- ផឹក + [-រ.ម-] > ប្មឹក > ប្រមឹក ...។

<u>សង្កេត</u> : ការច្រឡំគ្នារវាងផ្នត់ជែក [-ន-] និង ផ្នត់ជែក [-ម-] បាននាំឱ្យ៖

- ពាក្យ "ឃ្មោះ" បែរជាសម្គាល់ឧបករណ៍ទៅវិញ(គួរតែសម្គាល់ភ្នាក់ងារ)
- ពាក្យ "ឈ្នួល" បែរជាសម្គាល់ភ្នាក់ងារទៅវិញ(គួរតែសម្គាល់ឧបករណ៍)។

**(២)- ផ្នត់ជែក [-ន-],** ឧ. ជួល + [-ន-] > ឈ្នួល ...។

**(៣)- ផ្នត់ដើម [ត-],** ឧ. [ត-] + ឡើង > ឋ្លើង[២៩] ...។

<u>សង្កេត</u> : ពាក្យកម្លាយសម្គាល់ភ្នាក់ងារកើតដោយផ្នត់ដើម [ត-] មានតែពាក្យ ថ្លើង នេះទេ។

<u>**តារាងសរុប បង្ហាញការបង្កើតពាក្យសម្គាល់នាមភ្នាក់ងារឬនាមការក៍**</u>

| ពាក្យកម្លាយ / ពាក្យឫស | [-ម-] | [-ន-] | [ត-] |
|---|---|---|---|
| កាន់ | ខ្មាន់ | | |
| ចាំ | ឆ្មាំ | | |
| ជួញ | ឈ្មួញ | | |
| ដើរ | ថ្មើរ | | |
| សួន | ស្មួន | | |
| ទាក់ | ទ្មាក់ > ទ្រមាក់ | | |
| បង់ | ប្មង់ > ប្រមង់ | | |
| បាញ់ | ប្មាញ់ > ប្រមាញ់ | | |
| ផឹក | ប្មឹក > ប្រមឹក | | |
| ជួល | | ឈ្នួល | |
| ឡើង | | | ថ្លើង |

[២៩] តាមវចនានុក្រមខ្មែរ ពាក្យនេះមានន័យថា «អ្នកដែលឡើងចាង, ដែលព្រហើន, មហាត»។

សរុបនិទ្ទេស : យើងអាចសន្និដ្ឋានថា ផ្នត់ដែកសម្រាប់បង្កើតពាក្យកម្លាយសម្គាល់នាមឆ្នាក់ងារឬនាមការក៏ គឺផ្នត់ដែក [-ម-] ហើយ ក្នុងករណីខ្លះ គេបន្ថែមអាគមរៀផង(លើកលែងតែក្នុងពាក្យ "ឈ្មួល"និងក្នុងពាក្យ "ផ្ទើង")។

## ១.៥- ពាក្យកម្លាយសម្គាល់ស្វ័យកម្ម[៣០]

ដើម្បីបង្កើតពាក្យកម្លាយសម្គាល់កិរិយាស្វ័យកម្ម គេប្រើផ្នត់ដើម [រ-], ឧទាហរណ៍ :

- [រ-] + ងាប់ > រងាប់
- [រ-] + ជក > រជក
- [រ-] + ដោះ > រដោះ
- [រ-] + បូត > របូត
- [រ-] + បើក > របើក
- [រ-] + លត់ > រលត់
- [រ-] + ហូត > រហូត
- [រ-] + ហែក > រហែក ...។

<u>**តារាងសរុប បង្ហាញការបង្កើតពាក្យសម្គាល់កិរិយាស្វ័យកម្ម**</u>

| ពាក្យកម្លាយ / ពាក្យឫស | [រ-] |
|---|---|
| ងាប់ | រងាប់ |

[៣០] ស្វ័យកម្មជាពាក្យសម្រាប់សម្គាល់ស្ថានភាពឯកឯង ឬ ការធ្វើអំពើដោយខ្លួនឯង ការរងអំពើខ្លួនឯង។

| | |
|---|---|
| ដក | រដក |
| ដោះ | រដោះ |
| បូត | របូត |
| បើក | របើក |
| លត់ | រលត់ |
| ហូត | រហូត |

## ១.៦- ពាក្យកម្លាយសម្គាល់ន័យទ្រគោះ

ដើម្បីបង្កើតពាក្យកម្លាយសម្គាល់ន័យទ្រគោះ គេប្រើផ្នត់ដើម [ក-]និងកាឡូរូប,ឧទាហរណ៍ :

- [ក់ញ-] + ចាស់ > កញ្ចាស់
- [ក់ញ-] + ឆែប > កញ្ឆែប
- [ក់ន-] + តឿ > កន្តឿ
- [ក់ន-] + ទ្រួក > កន្ទ្រួក
- [ក់ន-] + ធាត់ > កន្ធាត់
- [ក់ម-] + បាក់ > កំបាក់
- [ក់ម-] + បែក > កំបែក ...។

## ១.៧- ពាក្យកម្លាយសម្គាល់ទង្វើផ្ទួន

ដើម្បីបង្កើតពាក្យកម្លាយសម្គាល់ទង្វើផ្ទួន ជាទូទៅ គេធ្វើទ្វេនីយកម្មទៅលើសញ្ញាព្យញ្ជនៈទី១នៃពាក្យឫស[៣១] (ពាក្យដែលជាប្រភពនៃពាក្យកម្លាយ) ដោយរក្សាទុកសូរអានដែលសញ្ញា

---

[៣១] ចំពោះបណ្ឌិត ច័ន្ទ សំណព្វ ករណីនេះមិនមែនជាការធ្វើទ្វេនីយកម្មទៅលើព្យញ្ជនៈទី១នៃពាក្យឫសទេ គឺជាការកម្លាយពាក្យឫសដោយផ្នត់ទម្រង់[ពស-] ក្នុងបរិបទសូរនៃពាក្យឫសមួយកំណត់ច្បាស់លាស់។

ព្យញ្ជនៈនោះមានក្នុងអក្ខរក្រមខ្មែរ ហើយ ក្នុងករណីកន្សោមព្យញ្ជនៈ គេធ្វើទ្វេនីយកម្មតែទៅ លើសញ្ញាព្យញ្ជនៈទី១ទេ ឬ ក្នុងករណីខ្លះទៀតក៏មានការសម្រួលសូរអានផង ...។

**១.៧.១- ករណីទូទៅ**, ឧទាហរណ៍ :

- កាយ > កកាយ
- ងក់ > ងងក់
- ចឹក > ចចឹក
- ជីក > ជជីក
- ញាក់ > ញញាក់
- តូង > តតូង
- ទើម > ទទើម
- បក់ > បបក់
- ប៉ាច់ > ប៉បាច់
- ពូន > ពពូន
- មើក > មមើក
- សិត > សសិត ...។

**១.៧.២- ករណីពិសេស**, ឧទាហរណ៍ :

- ក្អាកក្អាយ > កក្អាកកក្អាយ
- ភ្លឹបភ្លែត > ពភ្លឹបពភ្លែត
- ខ្ទេសខ្ទាស > កខ្ទេសកខ្ទាស ...។

<u>សង្កេត</u> : មានពាក្យមួយចំនួនដែលសម្គាល់ទង្វើផ្ទួនដែរ តែមិនកើតចេញពីពាក្យឫសណាមួយទេ ដូចជា៖ ដដែល/ដដែលៗ, ឥឡូវ/ឥឡូវៗ, ...។

## <u>តារាងសរុប បង្ហាញការបង្កើតពាក្យសម្គាល់ទង្វើផ្ទួន</u>

| ពាក្យកម្លាយ / ពាក្យឫស | ទ្វេនីយកម្មក្នុងករណីទូទៅ | ទ្វេនីយកម្មក្នុងករណីពិសេស |
|---|---|---|
| កាយ | កកាយ | |

| | | |
|---|---|---|
| ងក់ | ងងក់ | |
| ចឹក | ចចឹក | |
| ជីក | ជជីក | |
| ញាក់ | ញញាក់ | |
| ទើម | ទទើម | |
| បក់ | បបក់ | |
| ប៉ាច់ | ប៉ប៉ាច់ | |
| ពូន | ពពូន | |
| មើក | មមើក | |
| ក្អាកក្អាយ | | កក្អាកកក្អាយ |
| ក្លឹបក្លែត | | ពក្លឹបពក្លែត |
| ខ្វេសខ្វាស | | កខ្វេសកខ្វាស |

## ២- វិធីស្មើរកម្លាយនិងវិធីស្មើរបន្សំ

### ២.១- វិធីស្មើរកម្លាយ

វិធីស្មើរកម្លាយកើតចេញពីធាតុបន្ថែមចុង ដែលឥតមានអត្ថិភាពជាពាក្យឯករាជ្យនៅក្នុងភាសាខ្មែរទេ ដូចជា -ឧបនីយកម្ម/-នីយកម្ម, -ករ, -វិទូ, -វិទ្យា, -សាស្ត្រ, ...។ ពាក្យក្រុមនេះ មិនត្រូវបានគេចាត់ទុកជាពាក្យកម្លាយទេ ពីព្រោះអ្នកភាសាវិទ្យាខ្មែរមួយចំនួនមិនទទួលស្គាល់ថាធាតុបន្ថែមចុងខាងលើជាផ្នត់ចុង(ឬបច្ឆិមបទ)ទេ។

**២.១.១- ធាតុបន្ថែមចុង -ឧបនីយកម្ម/-នីយកម្ម សម្គាល់«ការធ្វើឱ្យទៅជា ការធ្វើឱ្យមានលក្ខណៈជា ...», ឧទាហរណ៍ :**

- ជាតិ + -ឧបនីយកម្ម > ជាតូបនីយកម្ម
- នគរ + -ឧបនីយកម្ម > នគរូបនីយកម្ម

| | |
|---|---|
| - ឯកភាព + -ឧបនីយកម្ម > ឯកភាវូបនីយកម្ម[៣២] | - ឯកជន + -នីយកម្ម > |
| - ខ្មែរ + -នីយកម្ម > ខ្មែរនីយកម្ម | ឯកជននីយកម្ម ...។ |

**២.១.២- ធាតុបន្ថែមចុង -ករ សម្គាល់ "ភ្នាក់ងារ", ឧទាហរណ៍ :**

| | |
|---|---|
| - កសិ + -ករ > កសិករ | - សិល្បៈ + -ករ > សិល្បករ |
| - កីឡា + -ករ > កីឡាករ | - កម្ម + -ករ > កម្មករ |
| - ពល + -ករ > ពលករ | - ពាណិជ្ជ + -ករ > ពាណិជ្ជករ |
| - ពិធី + -ករ > ពិធីករ | - តន្ត្រី + -ករ > តន្ត្រីករ ...។ |

**២.១.៣- ធាតុបន្ថែមចុង -វិទូ សម្គាល់«អ្នកប្រាជ្ញ», ឧទាហរណ៍ :**

| | |
|---|---|
| - ភាសា + -វិទូ > ភាសាវិទូ | - គណិត + -វិទូ > គណិតវិទូ |
| - ប្រវត្តិ + -វិទូ > ប្រវត្តិវិទូ | - ទស្សនៈ + -វិទូ > ទស្សនវិទូ ...។ |

**២.១.៤- ធាតុបន្ថែមចុងសម្គាល់«មុខវិជ្ជា»**

**(១)- ធាតុបន្ថែមចុង -វិទ្យា, ឧទាហរណ៍ :**

| | |
|---|---|
| - ភាសា + -វិទ្យា > ភាសាវិទ្យា | - គណិត + -វិទ្យា > គណិតវិទ្យា |
| - ប្រវត្តិ + -វិទ្យា > ប្រវត្តិវិទ្យា | - គីមី + -វិទ្យា > គីមីវិទ្យា ...។ |

**(២)- ធាតុបន្ថែមចុង -សាស្ត្រ, ឧទាហរណ៍ :**

| | |
|---|---|
| - វិទ្យា + -សាស្ត្រ > វិទ្យាសាស្ត្រ | - វេជ្ជ + -សាស្ត្រ > វេជ្ជសាស្ត្រ ...។ |

---

[៣២] «-ភាវូបនីយកម្ម» មិនមែនជាធាតុបន្ថែមចុងទេ គឺជាលទ្ធផលនៃការគួបផ្សំរវាងព្យាង្គ«ភាព» ខាងចុងនៃពាក្យ *ឯកភាព* ជាមួយនឹង «-ឧបនីយកម្ម» ដូចមានឧទាហរណ៍ខាងលើស្រាប់។ ម្យ៉ាងទៀត កាលពីថ្ងៃពុធ ទី២១ ខែឧសភា ឆ្នាំ២០០៨ គណៈកម្មាធិការជាតិភាសាខ្មែរ(គ.ជ.ភ.ខ.) បានសម្រេចឱ្យប្រើត្រឹមតែធាតុ «-ឧបនីយកម្ម/-នីយកម្ម» ប៉ុណ្ណោះ។

## ២.២- វិធីស្ទើរបន្សំ

វិធីស្ទើរបន្សំជាវិធីដែលគេប្រើជាមួយធាតុបន្ថែមដើម[៣៣] ដែលមាន *ការ, សេចក្ដី, អ្នក, មេ,* ...។ វិធីស្ទើរបន្សំនៅចន្លោះពាក្យកម្លាយនិងពាក្យបន្សំ ដូចវិធីស្ទើរកម្លាយដែរ។

ធាតុដែលគេប្រើសម្រាប់បង្កើតពាក្យនៅចំណុចនេះ មិនឆ្លើយទៅនឹងនិយមន័យនៃផ្នត់ទេ ពីព្រោះធាតុទាំងនេះមានអត្ថិភាពជាពាក្យឯករាជ្យក្នុងភាសាខ្មែរ ប៉ុន្តែពាក្យដែលកើតដោយធាតុទាំងនេះ ក៏មិនមែនជាពាក្យបន្សំធម្មតាដែរ ពីព្រោះធាតុនីមួយៗក្នុងក្រុមនេះអាចប្រើបានជាមួយពាក្យជាច្រើនសន្ធឹកសន្ធាប់។ បើយើងពិនិត្យធាតុ *ការ-* យើងនឹងឃើញថា គេអាចផ្គុំធាតុនេះនៅខាងឆ្វេងជាប់នឹងកិរិយាសព្ទដែលមានទាំងប៉ុន្មានក្នុងភាសាខ្មែរ ហើយ ពាក្យដែលកើតឡើងពីការផ្គុំនេះមានប្រភេទជានាម ប្លែកពីពាក្យឫសដែលជាកិរិយាសព្ទ ថ្វីបើពាក្យស្ទើរបន្សំខ្លះទៀត មានប្រភេទពាក្យដូចពាក្យឫសដែរ ដូចជា *មេទ័ព, អ្នកស្រែ* ដែលមានទម្រង់ដូចពាក្យបន្សំ *ទេះភ្លើង, ដីស* ជាដើម។

### ២.២.១- ធាតុបន្ថែមដើម *ការ-, សេចក្ដី-*

តាមភាពសមហេតុផល គេត្រូវប្រើ *ការ-* ជាមួយកិរិយាសព្ទ, *សេចក្ដី-* ជាមួយគុណនាម ពីព្រោះនាមស្ទើរបន្សំកើតចេញពីកិរិយាសព្ទសម្គាល់អំពើ រីឯនាមស្ទើរបន្សំកើតចេញពីគុណនាមសម្គាល់លក្ខណៈ/ភាព ប៉ុន្តែការចែកមុខងារគ្នាដាច់ណាត់បែបនេះ មិនត្រូវបានអ្នកប្រើប្រាស់ភាសា គោរពជាទូទៅទេ។ ជួនកាល គេប្រើ *សេចក្ដី-* ជាមួយកិរិយាសព្ទ ដូច *សេចក្ដីអត្ថាធិប្បាយ, សេចក្ដីសន្និដ្ឋាន, សេចក្ដីរៀបរាប់* ជាដើម ពីព្រោះគេចង់សំដៅទៅលើលទ្ធផលដែលចេញជាសក្ដិកម្ម ក្រោយពីអត្ថាធិប្បាយ/សន្និដ្ឋាន/រៀបរាប់, ... ត្រូវបានធ្វើរួចហើយ។

---

[៣៣] ចំពោះឈ្មោះនៃធាតុជំពូកនេះ អ្នកខ្លះហៅថា «ឧបអត្ថសបទ» ដែលមានន័យថា «ស្ទើរតែជា/សឹងតែជាអត្ថសបទ (ស្ទើរតែជា/សឹងតែជាផ្នត់)» និង អ្នកខ្លះទៀតហៅថា «អឌ្ឍអត្ថសបទ» ដែលមានន័យថា «ពាក់កណ្ដាលអត្ថសបទ (ពាក់កណ្ដាលផ្នត់)»។

ដោយវិធីផ្គុំ *ការ-* និង *សេចក្ដី-* ទៅនឹងពាក្យឫស ឥតមានលក្ខណៈស្មុគស្មាញអ្វីទេនោះ យើងមិនផ្ដល់ឧទាហរណ៍អ្វីទេ សម្រាប់វិធីប្រើ *ការ-* និង *សេចក្ដី-*នេះ។

### ២.២.២- ធាតុបន្ថែមដើម *អ្នក-*

*អ្នក-* អាចប្រើបានជាមួយប្រភេទពាក្យសំខាន់ទាំងបី គឺ កិរិយាសព្ទ, នាម និង គុណនាម, ឧទាហរណ៍ :

(១)- ជាមួយកិរិយាសព្ទ

| | |
|---|---|
| - អ្នកដេក | - អ្នកដាំដំណាំ |
| - អ្នកដើរ | - អ្នកធ្វើស្រែ |
| - អ្នកសើរើ | - អ្នកជីកដី ...។ |

(២)- ជាមួយនាម

| | |
|---|---|
| - អ្នកស្រែ | - អ្នកដំណើរ |
| - អ្នកចម្ការ | - អ្នកចម្រៀង |
| - អ្នកក្រុង | - អ្នកជំងឺ |
| - អ្នកស្រុក | - អ្នករបាំ |
| - អ្នកភូមិ | - អ្នកជំនាញ ...។ |
| - អ្នកភ្នំពេញ | |

<u>សង្កេត</u> :

(១)- ពាក្យកើតចេញពី *អ្នក-* + កិរិយាសព្ទ មានទម្រង់បែបជាឈ្មោះជាងជាមេពាក្យ ហើយ មានខ្លះប្រើជាប់ជាមួយ *កម្ម* ទៀតផង ដូច អ្នកជីកដី, អ្នកធ្វើស្រែ, អ្នកជួញគ្រឿងញៀន ជាដើម។

(២)- បើយើងទាញពាក្យកម្លាយចេញពីកិរិយាសព្ទឬពីគុណនាមឱ្យទៅជានាមសិន សឹមផ្គុំជាមួយ *អ្នក-* យើងបានពាក្យស្ទើរបន្សំ ដូច *អ្នកដំណើរ, អ្នកចម្រៀង, អ្នកជំនួញ* ជាដើម។

ពាក្យទាំងនេះមានទម្រង់ជាពាក្យស្ទើរបន្សំ ជាងពាក្យ *អ្នកដើរ, អ្នកច្រៀង, អ្នកជួញគ្រឿងញៀន* ដែលមានទម្រង់ជាឈ្មោះច្រើនជាង។

(៣)- ជាមួយគុណនាម

| | |
|---|---|
| - អ្នកធំ | - អ្នកតូចតាច |
| - អ្នកក្រ | - អ្នកខ្លាំងពូកែ |
| - អ្នកមាន | - អ្នកខ្លាំង |
| - អ្នកខ្សោយ | - អ្នកក្លាហាន |
| - អ្នកកំសាក | - អ្នកស្គម |
| - អ្នកឈឺ | - អ្នកជា ...។ |

**២.២.៣- ជាតុបន្ថែមដើម *មេ-*, ឧទាហរណ៍** :

| | |
|---|---|
| - មេឃុំ | - មេទ័ព |
| - មេភូមិ | - មេការ |
| - មេចោរ | - មេដៃ |
| - មេខ្លោង | - មេកង |
| - មេកាំបិត | - មេបញ្ជាការ |
| - មេក្រុម | - មេស្រុក ...។ |

<u>សង្កេត</u> : ចំពោះភាសាខ្មែរបច្ចុប្បន្ន ធាតុ *មេ* ក្នុង *មេគោ/មេក្របី* ... និង ធាតុ *មេ* ក្នុង *មេឃុំ/មេទ័ព* ... ជាសទិសសូរនឹងគ្នា : " មេគោ/មេក្របី" សម្គាល់ "គោ/ក្របីញី" រីឯ «មេឃុំ/មេទ័ព» សម្គាល់អ្នកដឹកនាំ : គឺក្នុងន័យទី២នេះហើយ ដែលធាតុ *មេ* អាចចាត់ទុកថាជា "ធាតុបន្ថែមដើម"។

## ៣- វិធីបន្សំ

វិធីដែលកើតពីការផ្គុំពាក្យឯករាជ្យនិងពាក្យឯករាជ្យ។ ជាទូទៅ ពាក្យដែលគេផ្គុំដើម្បីឱ្យបានជាពាក្យបន្សំ ជាពាក្យខ្មែរសុទ្ធឬពាក្យកម្ចីដែលបានចូលស៊ប់ក្នុងភាសាខ្មែរ។ ក្នុងពាក្យបន្សំមានពាក្យគោលនិងពាក្យរណប ដូចជាក្នុងពាក្យ *រទេះភ្លើង, រទេះ* ជាពាក្យគោល និង ពាក្យ *ភ្លើង* ជាពាក្យរណប។ ប៉ុន្តែពាក្យបន្សំមួយចំនួនឥតមានពាក្យគោលនិងពាក្យរណបទេ ដូច ជា *ឪពុកម្ដាយ, បងប្អូន, កូនចៅ, គោក្របី, ទប់ស្កាត់, រៀបរៀង, ជំជាត់, ...* ហើយ ពាក្យបន្សំ ខ្លះទៀត មានន័យប្លែកពីន័យនៃធាតុផ្សំនីមួយៗ ដូចជា *ជើងល្អ, ត្រចៀកស, ...*។

### ៣.១- ទម្រង់នៃនាមបន្សំ

#### ៣.១.១- នាម + នាម

| | |
|---|---|
| - ស្បែកជើង | - រទេះភ្លើងឬរថភ្លើង |
| - ចានដែក | - វត្ថុបំណាង |
| - ក្បាលរុយ | - កងទ័ព |
| - អាវភ្លៀង | - ប្រវត្តិរូប[៣៤] |
| - ផ្ទះបាយ | - បទបញ្ញត្តិ[៣៥] ...។ |

#### ៣.១.២- នាម + គុណនាម

| | |
|---|---|
| - ខ្លង់រាប | - ដីស |
| - ឈើទាល | - ថ្មស្អុយ |
| - ទឹកខ្មៅ | - ទោសឧក្រិដ្ឋ[៣៦] ...។ |

[៣៤] យើងជ្រើសរើសឧទាហរណ៍ដែលមានពាក្យខ្ចីពីភាសាបាលី-សំស្ក្រឹតជាធាតុផ្សំដោយចេតនា ដើម្បីបង្ហាញឱ្យឃើញថា ពាក្យខ្ចីពីភាសានេះអាចសម្របខ្លួនតាមទម្រង់ខ្មែរ-មននៃភាសាខ្មែរ គឺ "ពាក្យគោល + ពាក្យរណប"។

[៣៥] ក្នុងវចនានុក្រមរបស់ព្រះអង្គ សម្ដេចព្រះសង្ឃរាជ **ជួន ណាត** ប្រើពាក្យ *បទបញ្ញត្តិ* នេះជាកូនពាក្យ ដោយឥតមានសន្ធិព្យញ្ជនៈទេ(*សូមមើលមេពាក្យ អនុប្រការ*)៖ «*អនុប្រការ(...) ប្រការតូចៗ, ប្រការរង គឺប្រការតូចៗឬប្រការរងដែលរៀបរៀងតាមលំដាប់នៅក្នុងប្រការនីមួយៗនៃប្រកាស ឬ **បទបញ្ញត្តិ** ជាដើម ...*»។

[៣៦] នេះក៏ជាឧទាហរណ៍ជ្រើសរើសឡើង ដើម្បីបង្ហាញទម្រង់ខ្មែរ-មននៃធាតុផ្សំខ្ចីពីភាសាបាលី-សំស្ក្រឹត ដូចគ្នានឹងពាក្យ *ប្រវត្តិរូប* ដែរ។

### ៣.១.៣- នាម + សំខ្យាសព្ទ

| | |
|---|---|
| - ចំណុចពីរ | - (ផ្កា)ម៉ោងដប់ |
| - ជីដូនមួយ | - (ផ្កា)ម៉ោងប្រាំបី ...។ |

### ៣.១.៤- នាម + កិរិយាសព្ទ

| | |
|---|---|
| - យន្តហោះ | - ឈើច្រត់ |
| - ឈើគូស | - ចបកាប់ |
| - ថ្នាំជក់ | - កែវយឺត ...។ |

### ៣.១.៥- គុណនាម + នាម

| | |
|---|---|
| - ទន់ជី | - ខ្មៅដៃ ...។ |

### ៣.១.៦- កិរិយាសព្ទ + នាម

| | |
|---|---|
| - បាត់ដំបង | - បែកចាន ...។ |
| - ចង្កុលខ្មោច | |

### ៣.១.៧- កិរិយាសព្ទ + កិរិយាសព្ទ

| | |
|---|---|
| - បង់បត់ | - បាញ់វង ...។ |
| - បង់បាញ់ | |

### ៣.១.៨- នាម + នាម + នាម

| | |
|---|---|
| - ដំឡូងឈាមមាន់ | - ចានពងក្រពើ[៣៧] |
| - កន្សែងពោះគោ | - ពស់វែកក្របី ...។ |

### ៣.១.៩- នាម + នាម + គុណនាម

---

[៣៧] ពាក្យដែលកើតពីដំណូចឬពីការប្រៀបធៀបភាគច្រើនជាពាក្យបន្សំ : ឧទាហរណ៍បីក្នុងចំណោមឧទាហរណ៍ទាំងបួននៃចំណុចនេះ ជាពាក្យបន្សំកើតពីពង្វេរន័យ។

- កញ្ជើបាយដាច[៣៨] | - ទាហានជើងក្រហម
- ទឹកត្នោតជូរ | - អាវបំពង់វែង ...។

### ៣.១.១០- នាម + កិរិយាសព្ទ + នាម

- ឈើចាក់ធ្មេញ | - ស្វាញាក់ចិញ្ចើម[៣៩]
- ចានគោះបារី | - ថ្ងៃបណ្ដើរកូន
- ថ្មសំលៀងកាំបិត ...។

### ៣.១.១១- នាម + នាម + សំខ្យាសព្ទ

- បងជីដូនមួយ | - ប្អូនជីដូនមួយ ...។

### ៣.១.១២- នាម + ធ្នាក់ + នាម

- កូនក្រៅខោ ...។

### ៣.១.១៣- នាម + គុណនាម + នាម + គុណនាម

- អាវងោដៃវែង ...។

### ៣.១.១៤- នាម + កិរិយាសព្ទ + នាម + កិរិយាសព្ទ

- កន្សែងបក់កន្សែងបោយ | - ប៉ែនពោយនំបញ្ចុក ...។
- ផ្កាវាំទឹកវាំ

## ៣.២- ទម្រង់នៃគុណនាមចន្សំ

### ៣.២.១- នាម + នាម

---

[៣៨] តាមវចនានុក្រមខ្មែរ ពាក្យ "កញ្ជើបាយដាច" គឺជាឈ្មោះរុក្ខជាតិមួយប្រភេទ ដើមមានបន្លាខ្លីៗ មានផ្លែក្លិនហាងបន្តិចៗ។

[៣៩] តាមវចនានុក្រមខ្មែរ ពាក្យ«ស្វាញាក់ចិញ្ចើម» គឺផ្លែកបន្ទោរមួយបែប ដែលចេញពន្លឺព្រិចៗ ព្រើតៗ រឿយៗ។

- ទទឹងថ្ងៃ | - បណ្ដោយថ្ងៃ ...។

**៣.២.២- នាម + គុណនាម**

- ជើងល្អ | - ត្រចៀកស ...។

**៣.២.៣- នាម + កិរិយាសព្ទ**

- គោលោត | - ស្វាយត្រាំ ...។

**៣.២.៤- គុណនាម + គុណនាម**

- កំសាកញី | - ធំធាត់ ...។
- ទៀងត្រង់ |

**៣.២.៥- គុណនាម + នាម**

- ខ្វាក់មាន់ | - រម្ជួលក្រពើ ...។
- បោរមុខ |

**៣.២.៦- គុណនាម + កិរិយាសព្ទ**

- រាក់ទាក់ | - រឹងរូស ...។

**៣.២.៧- កិរិយាសព្ទ + នាម**

- ចុះប្រេង | - (ជំងឺ)សង់ផ្ទះ ...។

**៣.២.៨- កិរិយាសព្ទ + គុណនាម**

- បាំងស្មើរ ...។

**៣.២.៩- កិរិយាសព្ទ + កិរិយាសព្ទ**

- ដុះដាល | - រារែក ...។

**៣.៣- ទម្រង់នៃកិរិយាសព្ទចន្សំ**

**៣.៣.១- នាម + គុណនាម**

- តានតឹង ...។

### ៣.៣.២- គុណនាម + នាម

- ចង្អៀតចិត្ត | - តូចចិត្ត ...។

### ៣.៣.៣- កិរិយាសព្ទ + កិរិយាសព្ទ

- ជិះជាន់ | - រកស៊ី
- ចុះចូល | - ដើរហើរ ...។

### ៣.៣.៤- កិរិយាសព្ទ + នាម

- ចាប់ចិត្ត | - ដេញថ្លៃ
- ទល់ផ្អក | - បាក់ទ័ព ...។

### ៣.៣.៥- កិរិយាសព្ទ + នាម + នាម

- ចងស្ពានមេត្រី | - បាក់ជំរបាយ
- ដោះទុក្ខសត្វ | - លើកទឹកចិត្ត ...។

### ៣.៣.៦- កិរិយាសព្ទ + នាម + កិរិយាសព្ទ + កិរិយាសព្ទ

- យកចិត្តទុកដាក់ ...។

## ៣.៤- ទម្រង់នៃគុណកិរិយាចនរុំ

### ៣.៤.១- កិរិយាសព្ទ + នាម + នាម

- គងអន្ទាក់ខ្លា ...។

## ៣.៥- ទម្រង់នៃធ្នាក់ចនរុំ

### ៣.៥.១- កិរិយាសព្ទ + សំខ្យាសព្ទ

- ជាមួយ ...។

### ៣.៥.២- ធ្នាក់ + នាម

- ដោយសារ ...។

## ៤- វិធីសមាស

វិធីបន្សំមួយបែបដែលមាន**<u>សម្ព័ន្ធផ្សេង</u>**គ្នាពីសម្ព័ន្ធនៃពាក្យបន្សំបែបខ្មែរ។

### ៤.១- ពាក្យសមាសដែលគ្មានប្រើសន្ធិសម្រាប់តភ្ជាប់

៤.១.១- ការផ្គុំពាក្យឯករាជ្យដែលចូលស៊ប់ក្នុងភាសាខ្មែរជាមួយនឹងពាក្យឯករាជ្យដែលបានចូលស៊ប់ក្នុងភាសាខ្មែរដូចគ្នា, ឧទាហរណ៍ :

| | |
|---|---|
| - នាមបណ្ណ | - កាយពល |
| - វេជ្ជសភា | - សង្គមកិច្ច ...។ |

៤.១.២- ការផ្គុំធាតុដែលគ្មានអត្ថិភាពជាពាក្យឯករាជ្យជាមួយនឹងពាក្យឯករាជ្យដែលបានចូលស៊ប់ក្នុងភាសាខ្មែរ, ឧទាហរណ៍ :

| | |
|---|---|
| - អត្តសញ្ញាណ | - ពហុព្យាង្គ |
| - ឥទ្ធិពល | - សមិទ្ធផល ...។ |

៤.១.៣- ការផ្គុំពាក្យឯករាជ្យដែលបានចូលស៊ប់ក្នុងភាសាខ្មែរជាមួយនឹងធាតុដែលគ្មានអត្ថិភាពជាពាក្យឯករាជ្យ, ឧទាហរណ៍ :

| | |
|---|---|
| - សីលវន្ត | - អាជ្ញាធរ ...។ |

៤.១.៤- ការផ្គុំធាតុដែលគ្មានអត្ថិភាពជាពាក្យឯករាជ្យជាមួយនឹងធាតុដែលគ្មានអត្ថិភាពជាពាក្យឯករាជ្យដូចគ្នា, ឧទាហរណ៍ :

| | |
|---|---|
| - អភិធម្ម | - ធម្មនុញ្ញ ...។ |

### ៤.២- ពាក្យសមាសដែលមានប្រើសន្ធិសម្រាប់តភ្ជាប់

**៤.២.១- សន្ធិស្រៈ**

(១) - អ + អ > អា, ឧទាហរណ៍ :

- ធន + អគារ > ធនាគារ | - វេជ្ជ[៤០] + អភិបាល > វេជ្ជាភិបាល ...។

(២) - អ + អា > អា, ឧទាហរណ៍ :

- សព្វ + អាវុធ > សព្វាវុធ | - រូប + អារម្មណ៍ > រូបារម្មណ៍ ...។

(៣) - អា + អ > អា, ឧទាហរណ៍ :

- សិក្សា + អធិការ > សិក្សាធិការ |- ប្រឹក្សា + អភិបាល > ប្រឹក្សាភិបាល ...។

(៤) - អា + អា > អា, ឧទាហរណ៍ :

- វិទ្យា + អាល័យ > វិទ្យាល័យ | - អាជ្ញា + អាយុកាល > អាជ្ញាយុកាល ...។

**៤.២.២- សន្ធិព្យញ្ជនៈ, ឧទាហរណ៍ :**

- អាហារ + ឋាន > អាហារដ្ឋាន | - វិញ្ញាណ + ខន្ធ > វិញ្ញាណក្ខន្ធ ...។

__**សម្គាល់**__ : *តាមទម្លាប់ ខ្មែរយើងសរសេរពាក្យដូចជា ចតុប្បាទ ចតុនាគី ចតុមុខ ... ឥតប្រើសន្ធិព្យញ្ជនៈទេ។ ចំពោះពាក្យ **បទបញ្ញត្តិ** សម្ដេចព្រះសង្ឃរាជ ជួន ណាត ក៏ឥតប្រើសន្ធិព្យញ្ជនៈដែរ សូមមើលពាក្យ **អនុប្រការ** ក្នុងវចនានុក្រមរបស់ព្រះអង្គ។*

## ៥- វិធីរូប-សទ្ទតា

វិធីរូប-សទ្ទតាជាវិធីបង្កើតពាក្យមួយបែបផ្អែកលើវាក្យសព្ទ «រូប-សទ្ទតា» ដែលជាបម្រែនៃវាក្យសព្ទបារាំង «morpho-phonologique»។ ទោះវាក្យសព្ទ «រូប-សទ្ទតា» ជាខ្មែរក្ដីឬវាក្យសព្ទ «morpho-phonologique» ជាបារាំងក្ដី វាជាបញ្ញត្តិដែលមានបច្ចេកភាពនិងអរូបីភាពខ្ពស់ ប៉ុន្តែដោយសារឧទាហរណ៍ខាងក្រោម វិធីនេះងាយយល់ទេ។

### ៥.១- ពាក្យកាត់

គេយកពាក្យពហុព្យាង្គណាមួយមកកាត់ឱ្យខ្លី ឱ្យទៅជាមេពាក្យថ្មី ដើម្បីស្រួលប្រើប្រាស់,

---

[៤០] ក្នុងការផ្គុំពាក្យទោលជាមួយពាក្យទោល ឱ្យទៅជាពាក្យសមាស ព្យញ្ជនៈប្រកបនៃពាក្យទី១ ត្រូវចាត់ទុកថា មានស្រៈ អ (អខ្លី) នៅជាប់ជាមួយ។

ឧទាហរណ៍ :

- ពាក្យកាត់ដើម : ពុក < (ឪ)ពុក ...។

- ពាក្យកាត់ចុង : ឪ < ឪ(ពុក) ...។

**៥.២- ពាក្យកន្សោមកាត់**

គេយកកន្សោមពាក្យណាមួយ មកកាត់ពាក្យចោលខ្លះ ឱ្យទៅជាមេពាក្យ,ឧ.សមត្ថកិច្ច < អាជ្ញាធរមានសមត្ថកិច្ច ...។

**៥.៣- ពាក្យអក្សរកាត់** គេកាត់ពាក្យឬកន្សោមពាក្យដែលសម្គាល់ស្ថាប័នឬអង្គភាពណាមួយ ដោយទុកតែព្យញ្ជនៈដើមនៃពាក្យឬកន្សោមពាក្យនោះ ដើម្បីឱ្យបានជា «ពាក្យអក្សរកាត់», ឧទាហរណ៍ :

- គ.ជ.ប.[៤១] < គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
- ក.ជ.ភ.ខ. < ក្រុមប្រឹក្សាជាតិភាសាខ្មែរ
- អ.ស.ប. < អង្គការសហប្រជាជាតិ
- ន.ប. < នគរបាល
- អ.ហ. < អាវុធហត្ថ ...។

**៥.៤- ពាក្យកាត់កម្លាយ**

គេយកពាក្យពហុព្យាង្គណាមួយមកកាត់មួយព្យាង្គចេញ ហើយ យកព្យាង្គដែលនៅសល់ទៅធ្វើកម្លាយ, ឧ. និយាយ > (និ)យាយ > យាយ + [-ប-] > យ្បាយ > យោបាយ[៤២] ...។

---

[៤១] តាមធម្មតា គេតាងដោយព្យញ្ជនៈឬស្រៈទី១នៃធាតុឬពាក្យណាដែលជានាម, គុណនាម, កិរិយាសព្ទ ហើយ គេត្រូវតាងធាតុឬពាក្យទាំងអស់ដែលមានក្នុងកន្សោមពាក្យ លើកលែងតែធ្នាក់និងឈ្នាប់។ ក្នុងកន្សោមពាក្យ «គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត» មានពាក្យ«រៀបចំ» ដែលឥតត្រូវបានគេតាងដោយព្យញ្ជនៈ«រ» ទេ។

[៤២] យកលំនាំតាម (សរ)សេរ + [-អម.ណ-] > សំណេរ។

### ៥.៥- ពាក្យកាត់ចូក

**៥.៥.១-** គេកាត់ព្យាង្គដើមឬព្យាង្គចុងនៃពាក្យណាមួយ ទុកពាក្យមួយទៀតឱ្យនៅដដែល រួចផ្គុំគ្នា, ឧទាហរណ៍ :

- កសិឧស្សាហកម្ម < កសិ(កម្ម) + ឧស្សាហកម្ម
- កសិដ្ឋាន < កសិ(កម្ម) + ឋាន ...។

**៥.៥.២-** គេកាត់ព្យាង្គចុងនៃពាក្យណាមួយនិងកាត់ព្យាង្គដើមនៃពាក្យណាមួយរួចផ្គុំគ្នា,

ឧ. ការិយាធិបតេយ្យ < ការិយា(ល័យ) + (អ)ធិបតេយ្យ ...។

# II- ប្រភេទពាក្យ

## ១- នាម

### ១.១- និយមន័យ

នាមគឺជាពាក្យស្តែងពីមនុស្ស, សត្វ, រុក្ខជាតិ, ទីកន្លែង, ស្ថានភាព, សកម្មភាព, គំនិត, ... ឧ. និស្សិត, ចាន, ពូសុខ, តុ, គោ, ដំណើរ, រដ្ឋាភិបាល, ...។

### ១.២- ប្រភេទរបស់នាម

គេអាចចែកនាមជាប្រភេទផ្សេងៗ ដូចតទៅ៖

#### ១.២.១- នាមសាធារណ៍និងនាមអសាធារណ៍

-នាមសាធារណ៍ គឺនាមសម្គាល់ឈ្មោះមិនចំពោះ ទូទៅរបស់មនុស្ស សត្វ វត្ថុ ទីកន្លែង, ឧ. កសិករ, គោ, ប្រាសាទ, ប្រទេស, ...។

- នាមអសាធារណ៍ គឺនាមសម្គាល់ឈ្មោះប្រាកដ ចំពោះ មិនទូទៅរបស់មនុស្ស សត្វ វត្ថុ ទីកន្លែងណាមួយ, ឧ. ពូសុខ, អាត្មោត, អង្គរវត្ត, កម្ពុជា, ...។

#### ១.២.២- នាមរូបីនិងនាមអរូបី

- នាមរូបី គឺនាមសម្គាល់ឈ្មោះ មនុស្ស សត្វ វត្ថុ ឬ ទីកន្លែង ដែលមានរូប អាចមើលឃើញ ឬអាចស្ទាល់ អាចដឹងដោយវិញ្ញាណទាំងប្រាំ, ឧ. និស្សិត, សៀវភៅ, គោ, ផ្ទះ, ទន្លេ, ...។

- នាមអរូបី គឺនាមសម្គាល់អ្វីៗដែលគ្មានរូបរាងពិតប្រាកដ មើលមិនឃើញឬមិនអាចដឹង មិនអាចស្គាល់ដោយវិញ្ញាណទាំងប្រាំ, ឧ. ការរីកចម្រើន, ចំណេះ, កំហឹង, សេចក្ដីស្រឡាញ់, ...។

**<u>បញ្ជាក់</u>** : មាននាមមួយចំនួន សម្គាល់អ្វីៗដែលគ្មានរូបរាងពិតប្រាកដ មិនអាចដឹងឬស្គាល់ដោយវិញ្ញាណទាំងប្រាំទេ ប៉ុន្តែគេសន្មតថាជានាមរូបីដោយគេមានជំនឿថា អ្វីៗដែលសម្គាល់ដោយនាមខ្លះមានរូបបែបណាៗ, ឧ. ទេវតា, បិសាច, ខ្មោច, ព្រាយ, នាគ, ...។

### ១.២.៣- នាមជីវចលនិងនាមអជីវចល

- នាមជីវចល គឺនាមសម្គាល់អ្វីៗដែលមានជីវិត អាចធ្វើចលនាដោយខ្លួនឯង តាមលក្ខណៈធម្មជាតិ, ឧ. គោ, កុមារ, ឪពុក, មេអំបៅ, កង្កែប, ...។

- នាមអជីវចល គឺនាមសម្គាល់អ្វីៗដែលគ្មានជីវិត គ្មានវិញ្ញាណ មិនអាចធ្វើចលនាដោយខ្លួនឯងតាមលក្ខណៈធម្មជាតិ, ឧ. ផ្ទះ, សៀវភៅ, ភ្នំ, តុ, កៅអី, ...។

## ១.៣- មុខងាររបស់នាមក្នុងសម្ព័ន្ធ

ក្នុងសម្ព័ន្ធ នាមអាចមានមុខងារជា៖

**(១)- ប្រធាន,** ឧទាហរណ៍ :

- <u>កសិករ</u>ច្រូតស្រូវ( *កសិករ* ជាប្រធានរបស់កិរិយាសព្ទ *ច្រូត*)។
- <u>មាន់</u>រងាវ( *មាន់* ជាប្រធានរបស់កិរិយាសព្ទ *រងាវ* )។

**(២)- កម្មបទផ្ទាល់ឬកម្មបទមិនផ្ទាល់**

- **កម្មបទផ្ទាល់,** ឧទាហរណ៍ :
  - កសិករច្រូត<u>ស្រូវ</u>( *ស្រូវ* ជាកម្មបទផ្ទាល់ )។
  - គោស៊ី<u>ស្មៅ</u>( *ស្មៅ* ជាកម្មបទផ្ទាល់ )។
- **កម្មបទមិនផ្ទាល់,** ឧទាហរណ៍ :
  - មិត្តបាននិយាយពីប្រទេសបារាំង( *ពីប្រទេសបារាំង* ជាកម្មបទមិនផ្ទាល់ )។
  - គាត់គិតដល់ការប្រមូលផល( *ដល់ការប្រមូលផល* ជាកម្មបទមិនផ្ទាល់ )។

**(៣)- កម្មរបស់នាមមួយទៀត,** ឧទាហរណ៍ :

- ផ្ទះ<u>ឈើ</u>( *ឈើ* ជាកម្មរបស់*ផ្ទះ*)។

- ស្រុក<u>កំណើត</u>( *កំណើត* ជាកម្មរបស់*ស្រុក*)។

- ទុរេន<u>កំពត</u>( *កំពត* ជាកម្មរបស់ *ទុរេន*)។

**(៤)- គុណប្រធាន**, ឧ. ឪពុកវាជា<u>គ្រូបង្រៀន</u>( *គ្រូបង្រៀន* ជាគុណប្រធាន)។

## ២- សព្វនាម

### ២.១- និយមន័យ

សព្វនាមជាពាក្យប្រើសម្រាប់ស្តែងពីអ្នកនិយាយនិងអ្នកដែលគេនិយាយទៅរក ឬ សម្រាប់ជំនួសនាមឬកន្សោមនាមដែលគេនិយាយរួចហើយដើម្បីជៀសវាងការប្រើពាក្យច្រំដែល។

នៅក្នុងល្បះ សព្វនាមបំពេញមុខងារដូចនាមឬកន្សោមនាមដែរ គឺវាអាចជាប្រធានឬកម្មបទនៃកិរិយាសព្ទ។ ពាក្យ ខ្ញុំ យើង អ្នក វា គាត់ នេះ នោះ អ្វី នរណា ដែល ខ្លះ ... គឺជាសព្វនាម។

### ២.២- ប្រភេទផ្សេងៗនៃសព្វនាម

#### ២.២.១- សព្វនាមបុរិសៈ

សព្វនាមបុរិសៈ ជាពាក្យប្រើសម្រាប់ស្តែងពីអ្នកនិយាយនិងអ្នកដែលគេនិយាយទៅរក (សព្វនាមបុរិសៈបុរសទី១ សព្វនាមបុរិសៈបុរសទី២) ឬ សម្រាប់ជំនួសអ្នកឬអ្វីៗដែលគេបានលើកយកមកនិយាយរួចមកហើយ(សព្វនាមបុរិសៈបុរសទី៣)។

**សព្វនាមបុរិសៈ មាន៖**

- បុរសទី១ : ខ្ញុំ ខ្ញុំបាទ អាត្មា អញ នាងខ្ញុំ យើង យើងខ្ញុំ ពួកយើង ពួកខ្ញុំ ...។

- បុរសទី២ : ឯង អ្នក អ្នកឯង ពួកឯង ពួកអ្នកឯង ...។

- បុរសទី៣ : វា គាត់ នាង គេ ពួកវា ពួកគាត់ ពួកនាង ពួកគេ ...។

សព្វនាម**បុរិសៈប្រើជា៖**

- ប្រធាន, ឧទាហរណ៍ :

  - ខ្ញុំទៅសាលារៀន។

- គាត់ទៅផ្សារ ។
- អ្នកឯងកំពុងធ្វើអ្វី?

• កម្មបទផ្ទាល់, ឧទាហរណ៍ :
  - ពូសយវាយខ្ញុំ។
  - នាងស្រឡាញ់ឯង។
  - មនុស្សទូទៅ តែងតែគោរពគាត់។

• កម្មបទមិនផ្ទាល់, ឧទាហរណ៍ :
  - ពូឃុនតែងគិតពីខ្ញុំ។
  - កាលពីម្សិលមិញ មេឃុំបាននិយាយពីឯង។
  - អ្នកដឹកនាំប្រទេសតែងគិតពីយើង។

### ២.២.២- សព្វនាមចង្អុល

សព្វនាមចង្អុល ប្រើសម្រាប់សម្គាល់ មនុស្ស សត្វ វត្ថុ រុក្ខជាតិ ... ដែលគេទើបនឹងនិយាយ ឬ ដែលគេប្រុងនឹងនិយាយក្នុងគំនិតចង្អុលទីតាំងជិតឬឆ្ងាយ។

**សព្វនាមចង្អុល មាន៖**

- សម្រាប់ទីជិត : នេះ, អានេះ, អាមួយនេះ, អ្នកនេះ, អ្នកទាំងនេះ, អ្នកទាំងអស់នេះ, ទាំងនេះ, ទាំងអស់នេះ, ...។
- សម្រាប់ទីឆ្ងាយ : នោះ, អានោះ, អាមួយនោះ, អ្នកនោះ, អ្នកទាំងនោះ, អ្នកទាំងអស់នោះ, ទាំងនោះ, ទាំងអស់នោះ, ...។

**សព្វនាមចង្អុលប្រើជា៖**

• ប្រធាន, ឧ. នេះជាសៀវភៅរបស់ខ្ញុំ នោះជាសៀវភៅរបស់ឯង។
• កម្មបទផ្ទាល់, ឧ. នៅលើតុ មានសៀវភៅពីរក្បាល។ ខ្ញុំចង់យកអានេះ ខ្ញុំទុកអានោះឱ្យឯង។
• កម្មបទមិនផ្ទាល់, ឧ. មនុស្សពីរនាក់នេះ ម្នាក់ស្លូត ម្នាក់កាច។ ខ្ញុំនិយាយទៅកាន់អ្នកនេះ ខ្ញុំមិននិយាយទៅកាន់អ្នកនោះទេ។

• កម្មទេសកាល, ឧ. ខ្ញុំចូលចិត្តដើរជាមួយអ្នកនេះ មិនចូលចិត្តដើរជាមួយអ្នកនោះទេ។

### ២.២.៣- សព្វនាមសំណួរ

សព្វនាមសំណួរ ជាពាក្យនៅក្នុងល្បះសំណួរ ដែលប្រើសម្រាប់ជំនួសនាមឬកន្សោមនាមដែលគេនិយាយរួចហើយឬនៅក្នុងចម្លើយ។

**សព្វនាមសំណួរ មានៈ**

អ្វី អី នរណា អ្នកណា នរណាខ្លះ អ្នកណាខ្លះ អ្វីខ្លះ នរណាមួយ អ្នកណាមួយ ...។

**សព្វនាមសំណួរប្រើជាៈ**

- ប្រធាន, ឧ. តើនរណាកងឯង?
- កម្មបទផ្ទាល់, ឧ. តើឯងចង់បានអ្វី?
- កម្មបទមិនផ្ទាល់, ឧ. ឯងចង់ជួបនឹងនរណា?

### ២.២.៤- សព្វនាមឈ្នាប់

សព្វនាមឈ្នាប់ជាពាក្យសម្រាប់ប្រើជំនួសនាមឬកន្សោមនាមដែលគេនិយាយរួចមកហើយ និង សម្រាប់បង្កើតល្បះរណប។

**សព្វនាមឈ្នាប់ មានៈ**

ដែល, ដែលក្នុងនោះ, ដែលខណៈនោះ, ដែលតាមរយៈនោះ, ដែលពេលនោះ, ...។

**សព្វនាមឈ្នាប់ប្រើជាៈ**

- ប្រធាន, ឧទាហរណ៍ :
  - «យាយនួន**ដែល**មានព្រលឹងអណ្តែតទៅលើអាកាស មិនបានចាប់ចិត្តស្តាប់សម្តីលើកក្រោយនេះទេ»។ សព្វនាម *ដែល* ជំនួស *យាយនួន* និង ជាប្រធានរបស់កិរិយាសព្ទ «មាន»។
  - អ្នកដែលខិតខំរៀនតែងប្រឡងជាប់។

- កម្មបទផ្ទាល់, ឧ. "វត្ថុតាង**<u>ដែល</u>**ប៉ូលិសដកហូត មានកាំភ្លើងខ្លីមួយដើម"។ សព្វនាម *ដែល* ជំនួស *វត្ថុតាង* និង ជាកម្មបទផ្ទាល់នៃកិរិយាសព្ទ"ដកហូត"។

- កម្មបទមិនផ្ទាល់, ឧទាហរណ៍ :

  - ខ្ញុំបានជួបនឹងមិត្តម្នាក់ដែលខ្ញុំមិនបានគិតដល់។
  - បុរសដែលខ្ញុំនិយាយទៅកាន់ កាលពីម្សិលមិញនោះ ជាប្អូនប្រុសរបស់ខ្ញុំ។

- កម្មទេសកាលបញ្ជាក់ទីកន្លែង, ឧទាហរណ៍ :

  - "ទីក្រុង**<u>ដែល</u>**គាត់រស់នៅ បានទទួលការខូចខាតយ៉ាងធំណាំ"។ សព្វនាម *ដែល* ជំនួស *ទីក្រុង* ជាទីកន្លែងដែលគាត់រស់នៅ, បំពេញមុខងារជាកម្មទេសកាលបញ្ជាក់ទីកន្លែង។
  - ព្រៃដែលក្នុងនោះ គេកប់គ្រាប់មីនពាសពេញផ្ទៃដី មិនអាចឱ្យកសិករយើងស្វែងរកអនុផលបានឡើយ។

- កម្មទេសកាលបញ្ជាក់ពេលវេលា, ឧ. "ថ្ងៃ**<u>ដែល</u>**គាត់ចេញដំណើរ មានការប្រយុទ្ធគ្នាយ៉ាងខ្លាំង"។ សព្វនាម *ដែល* ជំនួស *ថ្ងៃ*, ជាកម្មទេសកាលបញ្ជាក់ពេលវេលា។

### ២.២.៥- សព្វនាមមិនច្បាស់

ពាក្យប្រើជំនួសនាមឬកន្សោមនាមដែលមិនបង្ហាញច្បាស់ចំពោះនរណាម្នាក់ អ្វីមួយ ចំនួនណាមួយពិតប្រាកដ។

**សព្វនាមមិនច្បាស់ មាន៖**

ខ្លះ ខ្លះទៀត អ្វី អ្វីៗ អ្វីមួយ ម្នាក់ៗ មួយចំនួន ...។

**សព្វនាមមិនច្បាស់ប្រើជា៖**

- ប្រធាន, ឧ. ការប្រកួតបាល់ទាត់ឆ្នាំនេះ មានអ្នកចូលទស្សនាច្រើនណាស់ <u>ខ្លះ</u>ឈរ <u>ខ្លះ</u>អង្គុយ <u>ខ្លះទៀត</u>ចេញក្រៅវិញព្រោះចង្អៀតពេក។

- កម្មបទផ្ទាល់, ឧ. ខ្ញុំមានសៀវភៅប្រាំក្បាលនៅលើតុ។ តើឯងចង់បានណាមួយ?

• កម្មបទមិនផ្ទាល់, ឧ. ពូឈុនកំពុងតែនិយាយពីអ្វីៗដែលគាត់បានធ្វើ កាលគាត់នៅជាមេភូមិ។

## ៣- គុណនាម

គុណនាមជាពាក្យសម្រាប់ប្រើជាពាក្យណែបឱ្យនាម។ គុណនាមមានពីរយ៉ាងៈ គុណនាមប្រក្រតី និង គុណនាមកំណត់។

### ៣.១- គុណនាមប្រក្រតី

គុណនាមប្រក្រតីជាប្រភេទពាក្យដែលមិនអាចប្រើជាប្រធានឬកម្មបទនៃកិរិយាសព្ទបានទេ(ប្រើបានតែជាពាក្យណែបឱ្យនាម) លើកលែងតែក្នុងករណីដ៏កម្រ ដូចជាក្នុងពាក្យទំនឹមទំនៀម "ធ្វើល្អបានល្អ ធ្វើអាក្រក់បានអាក្រក់" ជាដើម។ គុណនាមប្រក្រតីប្រើសម្រាប់បញ្ជាក់លក្ខណៈឱ្យនាម(គុណភាព ទំហំ បរិមាណ សភាព ...) ហើយ មានទីតាំងនៅជាប់ផ្ទាល់ខាងស្ដាំនាម ឬអាចញែកពីនាមដោយពាក្យ "ដ៏" ដើម្បីបង្កើតជាកន្សោមពង្រីក, ឧទាហរណ៍ :

- គាត់មានផ្ទះធំមួយ( *ធំ* ជាគុណនាមប្រក្រតី បញ្ជាក់លក្ខណៈរបស់*ផ្ទះ*)។
- នៅខាងក្រោយវត្ត មានភ្នំខ្ពស់មួយ( *ខ្ពស់* ជាគុណនាមប្រក្រតី បញ្ជាក់លក្ខណៈរបស់*ភ្នំ*)។
- សៀវភៅដ៏ក្រាស់មួយនេះ និយាយពីប្រវត្តិសាស្ត្រប្រទេសកម្ពុជា( *ក្រាស់* ជាគុណនាមប្រក្រតី បញ្ជាក់លក្ខណៈរបស់*សៀវភៅ*)។

គុណនាមប្រក្រតី មាន ធំ តូច ខ្ពស់ ទាប ក្រាស់ ស្ដើង ស ក្រហម ចាស់ ថ្មី ស្អាត ល្អ អាក្រក់ ត្រង់ កោង រលោង ...។

**គុណនាមប្រក្រតីអាចប្រើៈ**

• ជាគុណបទរបស់នាម, ឧទាហរណ៍ :
  - ឡានថ្មី( *ថ្មី* ជាគុណបទរបស់ *ឡាន*)
  - មនុស្សអាក្រក់( *អាក្រក់* ជាគុណបទរបស់ *មនុស្ស*)
  - ផ្លូវកោង( *កោង* ជាគុណបទរបស់ *ផ្លូវ*)។

• ក្នុងកម្រិតបណ្ដាច់, ឧទាហរណ៍ :
  - ពូសុខជាមនុស្សឆ្លាតណាស់។

- ដោយសារគាត់ជាមនុស្សស្លូតពេក នារីនេះត្រូវប្ដីជិះជាន់។

ពាក្យដែលប្រើជាមួយគុណនាម ដើម្បីឱ្យមានកម្រិតបណ្ដាច់ មាន ណាស់ ពេក បំផុត បង្អស់ ក្រៃលែង ...។

## ៣.២- គុណនាមកំណត់

គុណនាមកំណត់ ប្រើជាប់ផ្ទាល់ពីខាងស្ដាំនាមដើម្បីចង្អុល(ទីតាំង ពេលវេលា...) ប្រាប់ពីចំនួន បញ្ជាក់ភាពមិនច្បាស់លាស់និងដើម្បីសួរ។

គុណនាមកំណត់ចែកជា គុណនាមកំណត់ចង្អុល(គុណនាមចង្អុល) គុណនាមកំណត់ចំនួន(គុណនាមចំនួន) គុណនាមកំណត់មិនច្បាស់(គុណនាមមិនច្បាស់) និង គុណនាមកំណត់សំណួរ(គុណនាមសំណួរ)។

### ៣.២.១- គុណនាមចង្អុល

គុណនាមចង្អុល ប្រើសម្រាប់ចង្អុលបង្ហាញឱ្យឃើញច្បាស់លាស់នូវមនុស្ស សត្វ វត្ថុ ឬរុក្ខជាតិក្នុងទីតាំងណាមួយដោយធៀបនឹងអ្នកនិយាយ, ឧទាហរណ៍ :

- ផ្ទះនេះសង់ក្បែរវត្ត។
- ផ្ទះនោះសង់ក្បែរសាលារៀន។
- ក្មេងៗទាំងនោះនាំគ្នាទៅធ្វើពលកម្ម។

គុណនាមចង្អុលមាន នេះ នោះ ទាំងនេះ ទាំងនោះ ទាំងអស់នេះ ទាំងអស់នោះ ជាដើម។

### ៣.២.២- គុណនាមសំណួរ

គុណនាមសំណួរប្រើសម្រាប់សួរបញ្ជាក់អំពីនាមឬកន្សោមនាមដែលនៅជាប់ខាងឆ្វេង, ឧទាហរណ៍ :

- លោកចង់បានសៀវភៅអ្វី?
- តើលោកមកពីខេត្ត<u>ណា</u>?

គុណនាមសំណួរ មាន អ្វី ណា ប៉ុន្មាន ប៉ុនណា ...។

### ៣.២.៣- គុណនាមមិនច្បាស់

គុណនាមមិនច្បាស់ ប្រើសម្រាប់បង្ហាញមនុស្ស សត្វ ឬ វត្ថុ ដោយមិនបញ្ជាក់ច្បាស់លាស់, ឧទាហរណ៍ :

- កម្ពុជាមានកិច្ចសហប្រតិបត្តិការជាមួយប្រទេសនានាក្នុងលោក។
- សមាជិកទាំងឡាយសុទ្ធតែបំពេញការងារបានល្អ។
- ពូម៉ៅ គាត់ទៅផ្សារទិញត្រជាក់គោមួយ កណ្តៀវមួយ ពូថៅមួយ និង វត្ថុផ្សេងៗទៀត។

គុណនាមមិនច្បាស់ មាន នានា នីមួយៗ ផ្សេងៗ ទាំងឡាយ ទាំងពួង ...។

### ៣.២.៤- គុណនាមចំនួន

គុណនាមចំនួន ជាពាក្យដែលប្រើសម្រាប់បញ្ជាក់ពីចំនួន លំដាប់ ឬ របៀប, ឧទាហរណ៍ :

- ផ្ទះ*មួយ*ដែលធំជាងគេ គឺជាផ្ទះរបស់ខ្ញុំ។
- សុខអង្គុយនៅតុ*ទីពីរ*។

#### ៣.២.៤.១- គុណនាមចំនួនសម្រាប់រាប់

គុណនាមចំនួនសម្រាប់រាប់មានដូចជា សូន្យ មួយ ពីរ បី បួន ប្រាំ ប្រាំមួយ ដប់ ដប់ពីរ ម្ភៃ ម្ភៃប្រាំ មួយរយ មួយពាន់ បីម៉ឺន ប្រាំសែន ប្រាំបួនលាន ប្រាំបីលាន មួយទ្រីលាន ..., ឧទាហរណ៍ :

- គាត់ទិញតុ*ប្រាំ*។
- គាត់មានស្លាបព្រា*មួយ*។

#### ៣.២.៤.២- គុណនាមចំនួនសម្រាប់របៀប

គុណនាមចំនួនសម្រាប់របៀបកើតឡើងដោយពាក្យ «លេខ ទី លំដាប់ទី ថ្នាក់ទី ជាន់ទី គ្រាទី...» ភ្ជាប់ជាមួយនឹងគុណនាមកំណត់ចំនួនរាប់, ឧទាហរណ៍ :

- សុខជាសិស្ស*លេខមួយ*ក្នុងថ្នាក់។
- វាអង្គុយនៅតុ*ទីពីរ*។

#### ៣.២.៤.៣- គុណនាមចំនួនសម្រាប់បញ្ជាក់លំដាប់

គុណនាមចំនួនសម្រាប់បញ្ជាក់លំដាប់មានដូចជា ជំពូកមួយ ជំពូកពីរ មាត្រាមួយ មាត្រាពីរ ខមួយ ខពីរ វគ្គមួយ វគ្គពីរ ...។

## ៤- កិរិយាសព្ទ

### ៤.១- និយមន័យ

កិរិយាសព្ទ គឺជាពាក្យដែលសម្ដែងអំពើ ឬ ប្រាប់សភាពរបស់មនុស្ស សត្វ រុក្ខជាតិ វត្ថុ អ្វីមួយ និង ជាពាក្យដែលគេអាចដាក់ឱ្យទៅជាទម្រង់បដិសេធន៍បាន។ កិរិយាសព្ទជាស្នូលនៃល្បះ។

ពាក្យ ដើរ តែង ទៅ ដឹក ហៅ ជា ... គឺជាកិរិយាសព្ទ, ឧទាហរណ៍ :

- សុខមើលទូរទស្សន៍( *មើល* ជាកិរិយាសព្ទសម្ដែងអំពើ)។
- គាត់ស្រេកទឹក( *ស្រេក* ជាកិរិយាសព្ទប្រាប់សភាព)។

### ៤.២- ប្រភេទផ្សេងៗនៃកិរិយាសព្ទ

#### ៤.២.១- កិរិយាអកម្ម

កិរិយាអកម្ម ជាកិរិយាសព្ទដែលមិនត្រូវការកម្មបទ, ឧទាហរណ៍ :

- ទឹកហូរ។
- ចាបយំ។

កិរិយាអកម្ម មាន ហូរ, យំ, ដើរ, ហើរ, រងាវ, ព្រុស, ស្លាប់, ...។

#### ៤.២.២- កិរិយាសកម្ម

កិរិយាសកម្ម ជាកិរិយាសព្ទដែលត្រូវការកម្មបទ ដើម្បីឱ្យល្បះមានវេយ្យាករណភាព(ស្របតាមក្បួនវេយ្យាករណ៍), ឧទាហរណ៍ :

- សិស្សអានសៀវភៅ។
- គាត់និយាយជាមួយអ្នកកាសែត។

កិរិយាសកម្ម មាន អាន, ហូប, មើល, ទិញ, ពន្យល់, ស្គាល់, រៀន, និយាយ, គិត, ...។

កិរិយាសកម្មមានពីរបែបគឺ កិរិយាសកម្មផ្ទាល់និងកិរិយាសកម្មមិនផ្ទាល់៖

**៤.២.២.១- កិរិយាសកម្មផ្ទាល់**

កិរិយាសកម្មផ្ទាល់ ជាកិរិយាសព្ទដែលត្រូវការកម្មបទផ្ទាល់, ឧទាហរណ៍ :

- កសិករច្រូតស្រូវ។
- គោស៊ីស្មៅ។
- កសិករផ្តួលដើមឈើ។

**៤.២.២.២- កិរិយាសកម្មមិនផ្ទាល់**

កិរិយាសកម្មមិនផ្ទាល់ ជាកិរិយាសព្ទដែលត្រូវការកម្មបទមិនផ្ទាល់(មានប្រើធ្នាក់ជាមួយផង), ឧទាហរណ៍ :

- សិស្សជជែកពីការប្រឡង(*ពីការប្រឡង* ជាកម្មបទមិនផ្ទាល់ ពីព្រោះមានការប្រើធ្នាក់ *ពី* ជាមួយផង)។
- កសិករនឹកដល់ស្រុកកំណើត(*ដល់ស្រុកកំណើត* ជាកម្មបទមិនផ្ទាល់ ពីព្រោះមានការប្រើធ្នាក់ *ដល់* ជាមួយផង)។

**៤.២.៣- កិរិយាចំណង**

កិរិយាចំណងមិនសម្តែងអំពើរបស់ប្រធានទេ តែវាគ្រាន់តែភ្ជាប់គុណប្រធានទៅនឹងប្រធាន, ឧ. មិត្តខ្ញុំជាមន្ត្រីក្រសួងអប់រំ។

**៤.២.៤- កិរិយាជំនួយ**

កិរិយាជំនួយ ជាកិរិយាសព្ទដែលគេប្រើអមជាមួយកិរិយាសព្ទមួយទៀត (កិរិយាស្នូលនៃល្បះ) ដើម្បីបន្ថែមន័យឱ្យកាន់តែច្បាស់, ឧទាហរណ៍ :

- ក្មួយស្រីខ្ញុំអាចនិយាយភាសាចិននិងភាសាកូរ៉េ។
- គាត់ចង់ទិញឡានថ្មី។

## ៥- គុណកិរិយា

### ៥.១- និយមន័យ

គុណកិរិយាជាពាក្យដែលប្រើសម្រាប់សម្តែងលក្ខណៈឱ្យកិរិយាសព្ទ គុណនាម និង គុណកិរិយាដូចគ្នា។

គុណកិរិយា មានដូចជា យឺត លឿន ល្អ ណាស់ ពេក ..., ឧទាហរណ៍ :

- គោនេះបោលលឿន( *លឿន* ជាគុណកិរិយាបញ្ជាក់ឱ្យ *បោល*)។
- សំជាសិស្សល្អណាស់( *ណាស់* ជាគុណកិរិយាបញ្ជាក់ឱ្យ *ល្អ* )។
- វាសរសេរយឺតពេក( *ពេក* ជាគុណកិរិយាបញ្ជាក់ឱ្យ *យឺត* )។

## ៥.២- ប្រភេទផ្សេងៗនៃគុណកិរិយា

ដោយផ្អែកលើន័យ គេអាចចែកគុណកិរិយាក្នុងភាសាខ្មែរជា ៥ប្រភេទ៖

### ៥.២.១- **គុណកិរិយាបំណែប**

គុណកិរិយាបំណែបមាន យឺត លឿន ខ្សោយ ខ្លាំង ពូកែ ..., ឧ. នាងសរសេរ**លឿន**។

### ៥.២.២- **គុណកិរិយាទីកន្លែង**

គុណកិរិយាទីកន្លែងមាន នេះ នោះ ឯណេះ ឯនោះ មុខ ក្រោយ លើ ក្រោម ...,ឧទាហរណ៍ :

- គាត់ទៅ**នោះ** មួយភ្លែត។
- ប្តីដើរ**មុខ** ប្រពន្ធដើរ**ក្រោយ**។

### ៥.២.៣- **គុណកិរិយាកាល**

គុណកិរិយាកាលមាន ស្អែក ម្សិលមិញ ម្សិលម៉្ងៃ ព្រឹក ព្រឹកមិញ ខានស្អែក ខានស្អែកមួយ អម្បាញ់មិញ ឥឡូវនេះ ..., ឧទាហរណ៍ :

- វាទៅវិញ**ស្អែក**។
- ខ្ញុំទៅវិញ**ឥឡូវនេះ**។
- គាត់ទើបមកដល់**អម្បាញ់មិញ**។

### ៥.២.៤- **គុណកិរិយាបរិមាណ**

គុណកិរិយាបរិមាណមាន ច្រើន តិច ល្មម ណាស់ ពេក បំផុត ..., ឧទាហរណ៍ :

- គាត់និយាយ**ច្រើន**។
- ឯងចាយ**តិច** ខ្ញុំចាយ**ល្មម**។

### ៥.២.៥- **គុណកិរិយាសំណួរ**

គុណកិរិយាសំណួរមាន អង្កាល់? ពីអង្កាល់? ដូចម្ដេច? យ៉ាងម៉េច? យ៉ាងណា? ណា? ពីណា? ប៉ុនណា? ប៉ុន្មាន? ..., ឧទាហរណ៍ :

- វាមក**ពីអង្កាល់**?
- វាទៅវិញ**អង្កាល់**?
- គាត់គិត**យ៉ាងម៉េច**?
- ឯងទៅ**ណា**?

## ៦- ធ្នាក់

### ៦.១- និយមន័យ

ធ្នាក់ជាពាក្យប្រើជាមួយនឹងនាម កន្សោមនាម កិរិយា កន្សោមកិរិយា ដើម្បីបង្កើតកន្សោមមានធ្នាក់។

ធ្នាក់មានដូចជា លើ ក្រោម ជាមួយ អំពី រវាង នៃ កាលពី ដើម្បី ដោយសារ ...។

### ៦.២- ប្រភេទនៃធ្នាក់

ដោយផ្អែកលើន័យ គេអាចចែកធ្នាក់ជាច្រើនប្រភេទ ដូចជា៖

### ៦.២.១- ធ្នាក់បង្ហាញទីកន្លែង

ធ្នាក់បង្ហាញទីកន្លែងមាន លើ ក្រោម នៅ នៅលើ នៅក្រោម ក្នុង ក្រៅ ក្បែរ ..., ឧទាហរណ៍ :

- គាត់ដាក់សៀវភៅនៅលើតុ។
- កសិករសម្រាកក្រោមដើមឈើ។

### ៦.២.២- ធ្នាក់បង្ហាញពេលវេលា

ធ្នាក់បង្ហាញពេលវេលាមាន នៅ ប្រហែល ចាប់ពី បន្ទាប់ពី កាលពី ..., ឧទាហរណ៍ :

- នៅពេលព្រឹក គាត់តែងតែជូនកូនទៅសាលា។
- រថយន្តក្រុងចេញដំណើរ នៅម៉ោងប្រាំមួយព្រឹក។
- កាលពីព្រេងនាយ មានបុរសម្នាក់រកស៊ីជីកក្ដាម។
- ចាប់ពីថ្ងៃនោះមក នាងលែងបានជួបមុខគាត់ហូត។

### ៦.២.៣- ធ្នាក់បង្ហាញបំណែប

ធ្នាក់បង្ហាញបំណែបមាន ដោយ តាម ..., ឧទាហរណ៍ :

- វាធ្វើការដោយអំណត់។
- គាត់ធ្វើការតាមលទ្ធភាព។

### ៦.២.៤- ធ្នាក់បង្ហាញកម្មបទមិនផ្ទាល់

ធ្នាក់បង្ហាញកម្មបទមិនផ្ទាល់មាន អំពី នឹង ..., ឧទាហរណ៍ :

- គាត់ជួបនឹងគ្រោះភ័យ។
- អ្នកជំនាញពិភាក្សាអំពីការប្រែប្រួលធាតុអាកាស។

### ៦.២.៥- ធ្នាក់បង្ហាញកម្មសិទ្ធិ

ធ្នាក់បង្ហាញកម្មសិទ្ធិមាន នៃ របស់, ឧទាហរណ៍ :

- ភ្នំពេញជារាជធានីនៃប្រទេសកម្ពុជា។
- ឡានរបស់គាត់នៅល្អនៅឡើយ។

### ៦.២.៦- ធ្នាក់បង្ហាញមធ្យោបាយ

ធ្នាក់បង្ហាញមធ្យោបាយមាន ដោយ ដោយសារ នឹង តាម ..., ឧទាហរណ៍ :

- គាត់ហូបបាយនឹងស្លាបព្រា។
- គាត់ទៅអង្គរវត្តដោយរថយន្តផ្ទាល់ខ្លួន។

### ៦.២.៧- ធ្នាក់បង្ហាញគោលបំណង

ធ្នាក់បង្ហាញគោលបំណងមាន ដើម្បី សម្រាប់ ..., ឧទាហរណ៍ :

- ដើម្បីជីវភាពគ្រួសារ គាត់សុខចិត្តទៅធ្វើការទាំងថ្ងៃទាំងយប់។
- ខ្ញុំទិញបាយសម្រាប់អាហារថ្ងៃត្រង់។

## ៧- ឈ្នាប់

### ៧.១- និយមន័យ

ឈ្នាប់ ជាពាក្យដែលគេប្រើសម្រាប់ភ្ជាប់ពាក្យទៅនឹងពាក្យ កន្សោមពាក្យទៅនឹងកន្សោមពាក្យ ឬ ល្បះទៅនឹងល្បះ។

### ៧.២- ប្រភេទផ្សេងៗនៃឈ្នាប់

ឈ្នាប់មានពីរប្រភេទគឺ ឈ្នាប់ចងនិងឈ្នាប់រណប។

### ៧.២.១- ឈ្នាប់ចង

ឈ្នាប់ចងប្រើសម្រាប់ចងពាក្យនិងពាក្យ, កន្សោមពាក្យនិងកន្សោមពាក្យ, ឈ្នាប់និងឈ្នាប់, ឧទាហរណ៍ :

- សាស្ត្រាចារ្យនិងនិស្សិត បានជួបជុំគ្នានៅក្នុងសាលប្រជុំ។
- ប្រទេសកម្ពុជាមានអាកាសធាតុក្តៅហើយសើម។
- គាត់ចង់ទៅសមុទ្រប៉ុន្តែប្រពន្ធគាត់ចង់ទៅអង្គរវត្ត។

ឈ្នាប់ចងមានដូចជា និង ឬ ឯ រីឯ ចំណែក ចំណែកឯ តែ ប៉ុន្តែ ហើយ ...។

### ៧.២.២- ឈ្នាប់រណប

ឈ្នាប់រណប ប្រើនៅខាងដើមឃ្លារណបនៃឃ្លាធំ, ឧទាហរណ៍ :

-វាប្រាប់ខ្ញុំថា ខ្ញុំប្រឡងជាប់អាហារូបករណ៍។

-បើអ្នកមិនប្រាប់តាមត្រង់ទេ ខ្ញុំនឹងទៅប្តឹងប៉ូលិស។

-គាត់មិនបានមកប្រជុំ ព្រោះតែគាត់មានជំងឺ។

ឈ្នាប់រណបមានដូចជា ថា ដើម្បី ដើម្បីឱ្យ ពេលណា កាលណា បើ ប្រសិនបើ ព្រោះ ពីព្រោះ ព្រោះតែ ទាល់តែ លុះត្រាតែ ទោះបី ដរាបណា ថ្វីត្បិតតែ ...។

## ៨- ឧទានសព្ទ

ឧទានសព្ទជាពាក្យឬកន្សោមពាក្យដែលគេប្រើភ្ជាប់ជាមួយកន្សោមពាក្យឬឃ្លា សម្រាប់សម្តែងការភ្ញាក់ផ្អើល ត្រេកអរ តក់ស្លុត ងឿងឆ្ងល់ កោតសរសើរ ខឹង បញ្ចេញកំហឹង ... ដែលកើតឡើងភ្លាមៗ។ ឧទានសព្ទគ្មានមុខងារវេយ្យាករណ៍ទេ។

ឧទានសព្ទមានដូចជា យី! យើស! អ៊ំា! អី! អើ! នែ៎! ណ៎ែ! ពុទ្ធោ! ឱ! អុញ! ..., ឧទាហរណ៍ :

- យី! ខ្លាចណាស់!
- យើ! ដល់ម្លឹងម៉ឹង!
- យីអើ! នាងល្អណាស់តើ!
- អ៊ំា! អ្វីហ្នឹ!
- អ៊ំា! ដូច្នេះទេឬ?!
- អ៊ំា! មិនទាន់ទៅទេឬ?!

# ផ្នែកទី៣
# សម្ព័ន្ធវិទ្យា

# បញ្ញត្តិមូលដ្ឋាន

## ១- សម្ព័ន្ធវិទ្យា

សម្ព័ន្ធវិទ្យា ជាផ្នែកមួយនៃវេយ្យាករណ៍ដែលសិក្សាអំពីក្បួនចងក្រងពាក្យ ដើម្បីបង្កើតបានជាកន្សោមពាក្យឬឃ្លា។

## ២- កន្សោមពាក្យ

កន្សោមពាក្យ ជាកម្រងពាក្យដែលមានធាតុចាប់ពីពីរឡើងទៅ។ កន្សោមពាក្យក៏អាចជាពាក្យទោលផងដែរ,ឧ. ផ្ទះតូច តុបាយ សៀវភៅសរសេរ បាក់ទំព ដេញថ្លៃ ...។

## ៣- ឃ្លា

ឃ្លាជាពាក្យទាំងឡាយដែលបានចងសម្ព័ន្ធគ្នាជាបន្តបន្ទាប់ ត្រឹមត្រូវតាមវេយ្យាករណ៍។ ជាទូទៅ ក្នុងឃ្លា ត្រូវមានកន្សោមនាមប្រធាននិងកន្សោមកិរិយាប្រណាប់ប្រធាន,ឧទាហរណ៍ :

- សិស្សានុសិស្សទៅសាលារៀន។
- លោកគ្រូគារី ចូលចិត្តអានសៀវភៅ។

<u>កំណត់សម្គាល់</u> :

(១)- តាមធម្មតា កន្សោមពាក្យជាធាតុសំណង់នៃឃ្លា គឺកន្សោមនាមប្រធាននិងកន្សោមកិរិយាប្រណាប់ប្រធាន ហើយ កន្សោមពាក្យទាំងនោះ អាចកាត់បន្ថយឱ្យនៅតែពាក្យមួយម៉ាត់, ឧ. ខ្ញុំដេក។

(២)- ជាទូទៅ វេយ្យាករណ៍តាពត្រូវការឱ្យឃ្លាមានកន្សោមនាមប្រធាននិងកន្សោមកិរិយាប្រណាប់ប្រធាន ប៉ុន្តែ ក្នុងការសម្តែងមតិ ជួនកាល គេត្រូវការកម្មទេសកាលដែលភាគច្រើនជាកន្សោមមានធ្នាក់ ហើយ ដែលមិនរណបកន្សោមនាមប្រធាននិងកន្សោមកិរិយាប្រណាប់ប្រធានទេ, ឧ. ខ្ញុំបានទិញសៀវភៅមួយក្បាល កាលពីម្សិលមិញ (*កាលពីម្សិលមិញ* ជាកម្មទេសកាល)។

# I- ឃ្លា

## ១- ប្រភេទឃ្លា

ឃ្លាមាន៤ប្រភេទគឺ ឃ្លាប្រកាស ឃ្លាសំណួរ ឃ្លាបញ្ជា និង ឃ្លាឧទាន។

## ១.១- ល្បះប្រកាស

ល្បះដែលគេប្រើសម្រាប់បញ្ជាក់ឱ្យដឹងរឿងអ្វីមួយ។ ក្នុងការសរសេរ គេប្រើសញ្ញាខណ្ឌ(។) នៅទីបញ្ចប់នៃល្បះ, ឧទាហរណ៍ :

- សិស្សស្តាប់លោកគ្រូទាំងអស់គ្នា។
- កសិករច្រូតស្រូវដោយរីករាយ។
- គាត់ចូលចិត្តហូបនំដែលម្តាយគាត់ទិញពីផ្សារ។

## ១.២- ល្បះសំណួរ

ល្បះដែលគេប្រើសម្រាប់សួរចង់ដឹងអំពីអ្វីមួយ ដោយប្រើពាក្យសួរ ដូចជា តើ ឬ ឬទេ ទេឬ ណាមួយ អ្វី អ្វីខ្លះ ...។ ក្នុងការសរសេរ គេប្រើសញ្ញាសួរ( ? ) នៅទីបញ្ចប់នៃល្បះ, ឧទាហរណ៍ :

- តើអ្នកយល់ព្រមឬទេ?
- ថ្ងៃនេះ អ្នកមិនទៅរៀនទេឬ?
- លោកចង់បានសៀវភៅណាមួយ?
- បងត្រូវការអ្វី?
- តើគាត់បានដឹងថា កូនគាត់មានគ្រោះថ្នាក់ទេ?

## ១.៣- ល្បះបញ្ជា

ល្បះដែលគេប្រើសម្រាប់បង្គាប់ ផ្តល់ដំបូន្មាន ឬ ហាមប្រាម។ ក្នុងការសរសេរ គេប្រើសញ្ញាឧទាន( ! ) នៅទីបញ្ចប់នៃល្បះ, ឧទាហរណ៍ :

- ចូរអ្នករៀបចំបន្ទប់ឱ្យបានស្អាត!
- ត្រូវខិតខំរៀនសូត្រ!
- ហាមខាកស្តោះ!
- ចូរឯងខិតខំរៀនសូត្រនិងឆ្លៀតជួយធ្វើការឪពុកម្តាយផង!

### ១.៤- ល្បះឧទាន

ល្បះដែលគេប្រើសម្រាប់សំដែងអំណរ កំហឹង ការរំជួលចិត្ត ការកោតសរសើរ ការងឿងឆ្ងល់ ការភ្ញាក់ផ្អើល ដែលកើតឡើងភ្លាមៗ។ ក្នុងការសរសេរ គេប្រើសញ្ញាឧទាន( ! )នៅទីបញ្ចប់នៃល្បះ, ឧទាហរណ៍ :

- យី! អស្ចារ្យណាស់!
- វេងាណាស់!
- នាងឆ្លាតមែនទែន!

## ២- ទម្រង់ល្បះ

ល្បះមានបីទម្រង់ គឺទម្រង់វិជ្ជមានឬអវិជ្ជមាន ទម្រង់មិនសង្កត់បញ្ជាក់ឬសង្កត់បញ្ជាក់ និងទម្រង់កត្តុវាចកៈឬកម្មវាចកៈ។

### ២.១- ទម្រង់វិជ្ជមានឬអវិជ្ជមាន

#### ២.១.១- ទម្រង់វិជ្ជមាន

ទម្រង់វិជ្ជមាន គឺជាទម្រង់ដែលមិនមានប្រើអវិជ្ជមានបទដូចជា មិន មិន...ទេ ពុំ ពុំ...ទេ គ្មាន គ្មាន...ទេ មិន មិន...សោះ កុំ កុំ...ឡើយ ជាដើម។

#### ២.១.១.១- ប្រើក្នុងល្បះប្រកាស

- សិស្សទៅសាលារៀន។
- វាស្អប់អ្នកជិតខាង។
- សិស្សានុសិស្សទៅសាលារៀន ដើម្បីស្វែងរកចំណេះដឹង។

#### ២.១.១.២- ប្រើក្នុងល្បះសំណួរ

- ម្ដេចក៏ថ្ងៃនេះ ឯងមានទឹកមុខស្រពាប់ស្រពោនម្ល៉េះ?
- តាំងពីរាជរដ្ឋាភិបាលបានទទួលបដិមាបីរូបពីរដ្ឋាភិបាលអាម៉េរិក តើអ្នកដែលបានទៅទស្សនាសារមន្ទីរឬទេ?

### ២.១.១.៣- ប្រើក្នុងល្បះបញ្ជា

- កូនទៅទីនោះចុះ!
- ចូរអ្នកខំធ្វើការងារ ដើម្បីឱ្យគ្រួសាររបស់អ្នកមានជីវភាពធូរធារ!

### ២.១.១.៤- ប្រើក្នុងល្បះឧទាន

- ពុទ្ធោអើយ! គួរឱ្យអាណិតណាស់!
- យី! នាងនេះស្អាតម្ល៉េះ!

## ២.១.២- ទម្រង់អវិជ្ជមាន

ទម្រង់អវិជ្ជមាន គឺជាទម្រង់ដែលមានប្រើអវិជ្ជមានបទដូចជា មិន មិន...ទេ ពុំ ពុំ...ទេ គ្មាន គ្មាន...ទេ មិន មិន...សោះ កុំ កុំ...ឡើយ ជាដើម។

### ២.១.២.១- ប្រើក្នុងល្បះប្រកាស

- ថ្ងៃនេះ សិស្សមិនទៅសាលារៀនទេ។
- វាមិនដែលស្អប់អ្នកជិតខាងសោះ។

### ២.១.២.២- ប្រើក្នុងល្បះសំណួរ

- តើឯងមិនចង់បានសៀវភៅនេះទេឬ?
- ម្ដេចក៏ថ្ងៃនេះ ឯងមិនទៅរៀន?

### ២.១.២.៣- ប្រើក្នុងល្បះបញ្ជា

- សូមកុំពិសាបារី នៅទីនេះ!
- ទីនោះមានក្មេងទំនើងច្រើនណាស់ ចូរឯងកុំទៅទីនោះឱ្យសោះ!

### ២.១.២.៤- ប្រើក្នុងល្បះឧទាន

- យីអើ! មិនគួរបើដល់ម្លឹងសោះ!
- យី! រឿងនេះមិនគួរកើតឡើងសោះ!

## ២.២- ទម្រង់មិនសង្កត់បញ្ជាក់ឬសង្កត់បញ្ជាក់

### ២.២.១- ទម្រង់មិនសង្កត់បញ្ជាក់

ទម្រង់មិនសង្កត់បញ្ជាក់ គឺជាទម្រង់ដែលក្នុងនោះគេពុំផ្ដោតអារម្មណ៍លើធាតុសំណង់ណាមួយ(ប្រធាន កម្មបទ កម្មទេសកាល) នៃល្បះទេ។

#### ២.២.១.១- ប្រើក្នុងល្បះប្រកាស

- សិស្សចូលចិត្តអានសៀវភៅ។
- ខ្ញុំស្អប់មនុស្សនេះណាស់។
- ខ្ញុំមិនធ្លាប់រស់នៅទីនេះទេ។

#### ២.២.១.២- ប្រើក្នុងល្បះសំណួរ

- ម្ដេចក៏ថ្ងៃនេះ ឯងមានទឹកមុខស្រពាប់ស្រពោនម្ល៉េះ?
- តើឯងមិនចង់បានសៀវភៅនេះទេឬ?

#### ២.២.១.៣- ប្រើក្នុងល្បះបញ្ជា

- កូនទៅទីនោះចុះ!
- ទីនោះមានក្មេងទំនើងច្រើនណាស់ ចូរឯងកុំទៅទីនោះឱ្យសោះ!

#### ២.២.១.៤- ប្រើក្នុងល្បះឧទាន

- ពុទ្ធោអើយ! គួរឱ្យអាណិតណាស់!
- យីអើ! មិនគួរបើដល់ម្លឹងសោះ!

### ២.២.២- ទម្រង់សង្កត់បញ្ជាក់

ទម្រង់សង្កត់បញ្ជាក់ គឺជាទម្រង់ដែលក្នុងនោះគេផ្ដោតអារម្មណ៍លើធាតុសំណង់ណាមួយនៃល្បះ(ប្រធាន កម្មបទ កម្មទេសកាល) ដោយប្ដូរទីតាំងនិង/ឬបន្ថែមសព្វនាមលើធាតុសំណង់នោះ។

### ២.២.២.១- ប្រើក្នុងល្បះប្រកាស

(១)- សង្កត់បញ្ជាក់ប្រធាន៖

- ពូសុក គាត់ចូលចិត្តដក់បារី។
- ពូសំ គាត់មិនចូលចិត្តជក់បារីទេ។

(២)- សង្កត់បញ្ជាក់កម្មបទផ្ទាល់៖

- មនុស្សនោះ ខ្ញុំស្អប់វាណាស់។
- មនុស្សនេះ ខ្ញុំមិនស្អប់គាត់ទេ។

(៣)- សង្កត់បញ្ជាក់កម្មបទមិនផ្ទាល់៖

- អំពីរឿងនេះ ខ្ញុំបាននិយាយប្រាប់គាត់រួចហើយ។
- ចំពោះបងខ្ញុំ ខ្ញុំទិញតុមួយជូនគាត់។
- ចំពោះកូនខ្ញុំ ខ្ញុំទិញសៀវភៅមួយឱ្យវា។
- ចំពោះកូនខ្ញុំ ខ្ញុំមិនដែលទិញអ្វីឱ្យឡើយ។

(៤)- សង្កត់បញ្ជាក់កម្មទេសកាល៖

- ដោយសេចក្តីអនុគ្រោះ ចៅហ្វាយស្រីវត្តបានអនុញ្ញាតឱ្យនាងឈប់មួយថ្ងៃ ដើម្បីចូលរួមអាពាហ៍ពិពាហ៍របស់មិត្តនាង[៤៣]។
- គឺទីនេះហើយដែលខ្ញុំធ្លាប់រស់នៅ។

### ២.២.២.២- ប្រើក្នុងល្បះសំណួរ

---

[៤៣] ជាទូទៅ កម្មទេសកាលស្ថិតនៅខាងក្រោយកន្សោមកិរិយា ប៉ុន្តែកម្មទេសកាលមួយចំនួនត្រូវបានគេដាក់ញឹកញាប់ប្រហែលគ្នា មុនកន្សោមនាមប្រធានឬក្រោយកន្សោមកិរិយា ដូច្នេះហើយ ការដាក់កម្មទេសកាលខ្លះនៅមុន(ខាងឆ្វេង)នៃកន្សោមនាមប្រធានមិនសូវមានលក្ខណៈជាទម្រង់សង្កត់ទេក្នុងអារម្មណ៍សាធារណជន, ឧ. *(កាលពី) ម្សិលមិញ ខ្ញុំបានទិញម៉ូតូមួយគ្រឿងឱ្យកូនខ្ញុំ។*

(១)- សង្កត់បញ្ញាក់ប្រធានៈ

- ពូសយ តើគាត់ចេះបើកឡានឬទេ?

- ពូសយ តើគាត់មិនចេះបើកឡានទេឬ?

(២)- សង្កត់បញ្ញាក់កម្មបទផ្ទាល់ៈ

- នារីនេះ តើឯងស្រឡាញ់នាងឬទេ?

- នារីនោះ តើឯងមិនស្រឡាញ់នាងទេឬ?

(៣)- សង្កត់បញ្ញាក់កម្មបទមិនផ្ទាល់ៈ

- អំពីរឿងនេះ តើឯងបាននិយាយប្រាប់គាត់រួចហើយឬនៅ?

- ចំពោះបងឯង តើឯងទិញតុមួយជូនគាត់មែនឬទេ?

- ចំពោះកូនឯង តើឯងមិនដែលទិញអ្វីឱ្យវាមែនឬទេ?

(៤)- សង្កត់បញ្ញាក់កម្មទេសកាលៈ

- គឺទីនេះឬដែលអ្នកធ្លាប់រស់នៅ?

## ២.២.២.៣- ប្រើក្នុងល្បះបញ្ជា

(១)- សង្កត់បញ្ញាក់ប្រធានៈ

- បង បងឯងអញ្ជើញទៅប្រជុំទៅ!

- សំ ចូរឯងទៅស្រែចុះ!

- បង សូមបងអញ្ជើញទៅប្រជុំទៅ!

(២)- សង្កត់បញ្ញាក់កម្មបទផ្ទាល់ៈ

- នាងតូចនេះ ចូរឯងថែរក្សាវាឱ្យបានល្អ!

- តុ ទូ កៅអី ចូរឯងកុំទិញវាច្រើនពេក!

- ឡានចាស់នេះ លក់វាចោលទៅ!

(៣)- សង្កត់បញ្ជាក់កម្មបទមិនផ្ទាល់៖

- ជាមួយគាត់ ចូរឯងទៅទាក់ទងនឹងគាត់ទៅ!

- ចំពោះគាត់ ចូរឯងទិញផ្លែឈើជូនគាត់ផង!

(៤)- សង្កត់បញ្ជាក់កម្មទេសកាល៖

- ថ្ងៃស្អែកព្រឹក ចូរយើងជួបគ្នានៅពេលនោះកុំខាន!

## ២.៣- ទម្រង់កត្តុវាចកៈឬកម្មវាចកៈ

### ២.៣.១- ទម្រង់កត្តុវាចកៈ

ទម្រង់កត្តុវាចកៈ គឺជាទម្រង់នៃល្បះដែលក្នុងនោះប្រធានធ្វើអំពើ។ ឧទាហរណ៍ទាំងប៉ុន្មានខាងលើ សុទ្ធតែជាល្បះដែលក្នុងនោះប្រធានធ្វើអំពើ : អាស្រ័យហេតុនេះ យើងមិនចាំបាច់ផ្តល់ឧទាហរណ៍សម្រាប់ទម្រង់នេះទេ។

### ២.៣.២- ទម្រង់កម្មវាចកៈ

ទម្រង់កម្មវាចកៈ គឺជាទម្រង់នៃល្បះដែលក្នុងនោះប្រធានរងអំពើ ហើយ កម្មភ្នាក់ងារជាអ្នកធ្វើអំពើ។ កន្សោមកិរិយាកម្មវាចកៈមាន ពីរទម្រង់ គឺ

- កន្សោមកិរិយា + កម្មភ្នាក់ងារ (ដោយ+កន្សោមនាម)
- ត្រូវបាន + កិរិយា + កម្មភ្នាក់ងារ (ដោយ+កន្សោមនាម)

កំណត់សម្គាល់ : គេអាចប្រើឬមិនប្រើកម្មភ្នាក់ងារក្នុងល្បះកម្មវាចកៈ, ឧ. ផ្ទះនេះសង់នៅកណ្តាលស្រែ (ល្បះបែបនេះ ជាល្បះកម្មវាចកៈមិនប្រើកម្មភ្នាក់ងារ តែត្រូវមានកម្មទេសកាល)។

#### ២.៣.២.១- ប្រើក្នុងល្បះប្រកាស

- រឿងកុលាបប៉ៃលិននិពន្ធដោយលោក ញ៉ុក ថែម។
- សមាជិកក្រុមប្រឹក្សាជាតិភាសាខ្មែរពីររូប ត្រូវបានតែងតាំងដោយព្រះមហាក្សត្រ កាលពីប្រាំខែមុន។

### ២.៣.២.២- ប្រើក្នុងល្បះសំណួរ

- តើរឿងនោះនិពន្ធដោយអ្នកណា?
- តើឃាតករនោះត្រូវបានឃាត់ខ្លួននៅខេត្តតាកែវ មែនឬទេ?
- តើគាត់ត្រូវបានបាញ់សម្លាប់ដោយចោរប្លន់ពីអង្កាល់?

### ២.៣.២.៣- ប្រើក្នុងល្បះបញ្ជា

- សូមឱ្យកូនខ្ញុំត្រូវបានដោះលែងក្នុងថ្ងៃនេះ!
- ចូរឱ្យការងារនេះត្រូវបានបញ្ចប់ដោយពួកឯងក្នុងពេលដ៏ខ្លីខាងមុខ!

### ២.៣.២.៤- ប្រើក្នុងល្បះឧទាន

- អុញ្ចឹង! ផ្ទះនោះត្រូវបានវាយកម្ទេចអស់រលីង!
- អស្ចារ្យ! អគារនេះត្រូវបានសាងសង់យ៉ាងស្អាត!
- អស្ចារ្យ! ពិធីនេះត្រូវបានប្រារព្ធឡើងយ៉ាងអធឹកអធម!

## ៣- ប្រភេទនៃល្បះ

ល្បះមានបីបែបគឺ ល្បះទោល ល្បះផ្សំ និង ល្បះក្រុង។

### ៣.១- ល្បះទោល

ល្បះទោល គឺជាល្បះដែលក្នុងនោះមានកន្សោមកិរិយាប្រណាប់ប្រធានតែមួយ,ឧទាហរណ៍ :

- ទឹកហូរក្រោមស្ពាន។
- គាត់ទិញតុមួយ។
- បងសំ កសិករឆ្នើម ក្លាយជាប្រធានភូមិ។
- បងប្រុសនិងបងស្រីខ្ញុំ មានប្រពន្ធឬប្តីគ្រប់គ្នាអស់ហើយ។

## ៣.២- ល្បះផ្សំ

ល្បះផ្សំគឺជាល្បះដែលកើតឡើងដោយការផ្សំរវាងល្បះគោលនិងល្បះរណប។ ល្បះរណបអាចភ្ជាប់ទៅនឹងល្បះគោលដោយសព្វនាមឈ្នាប់ឬឈ្នាប់រណប។

### ៣.២.១- ល្បះផ្សំដែលប្រើសព្វនាមឈ្នាប់ *ដែល*, ឧទាហរណ៍ :

- វាមើលសៀវភៅដែលឪពុកវាទើបនឹងទិញ( *វាមើលសៀវភៅ*ជាល្បះគោល, *ដែលឪពុកវាទើបនឹងទិញ* ជាល្បះរណប )។

- មនុស្សដែលខ្ញុំស្រឡាញ់មានគុណធម៌ខ្ពស់( *ដែលខ្ញុំស្រឡាញ់* ជាល្បះរណប, *មនុស្សមានគុណធម៌ខ្ពស់* ជាល្បះគោល )។

### ៣.២.២- ល្បះផ្សំដែលប្រើឈ្នាប់រណប, ឧទាហរណ៍ :

- គាត់សង្ឃឹមថា យើងនឹងមានសុភមង្គល។

- គាត់ខិតខំធ្វើការទាំងថ្ងៃទាំងយប់ ពីព្រោះគាត់ចង់ឱ្យគ្រួសារគាត់មានជីវភាពធូរធារ។

## ៣.៣- ល្បះក្រុង

ល្បះក្រុង គឺជាល្បះដែលកើតឡើងដោយល្បះទោលនិងល្បះទោល ដោយល្បះទោលនិងល្បះផ្សំ ឬ ដោយល្បះផ្សំនិងល្បះផ្សំ ចាប់ពីពីរឡើងទៅ, ឧទាហរណ៍ :

- មាន់រងាវ សេះកញ្ជៀវ គោពេទ៍។

- ពិចិតជាសិស្សពូកែ ដូច្នេះ បើគេចង់រៀនដល់ថ្នាក់បណ្ឌិត គេនឹងអាចសម្រេចបំណងរបស់គេមិនខាន។

- បុរសដែលទើបមកដល់ជាកម្មករជំនាញក្នុងរោងចក្រជំឡើងត្រាក់ទ័រ ឯបុរសដែលមកដល់មុននេះបន្តិចជាអ្នកជំនាញការក្នុងរោងចក្រនោះដែរ។

## ៤- មុខងារនៃកន្សោមពាក្យក្នុងល្បះនិងមុខងារនៃពាក្យឬកន្សោមពាក្យក្នុងកន្សោមពាក្យ

## ៤.១- មុខងារនៃកន្សោមពាក្យក្នុងឃ្លា

ដូចយើងបានឃើញមកហើយ ក្នុងឃ្លាមានកន្សោមនាមប្រធាន កន្សោមកិរិយាប្រណាប់ប្រធាន និង កន្សោមមានធ្លាក់ឯករាជ្យពីកន្សោមកិរិយាប្រណាប់ប្រធាន។

កន្សោមទាំងបីនេះ ជាធាតុសំណង់នៃឃ្លា ហើយ ក៏មានមុខងារវេយ្យាករណ៍ផងដែរ។

<u>កំណត់សម្គាល់</u> : ដូចយើងបានឃើញរួចមកហើយ កន្សោមពាក្យអាចជាពាក្យទោលផងដែរ, ឧ. ខ្ញុំដេក (*ខ្ញុំ* ជាកន្សោមនាមប្រធាន *ដេក* ជាកន្សោមកិរិយាប្រណាប់ប្រធាន)។

## ៤.២- មុខងារនៃពាក្យឬកន្សោមពាក្យក្នុងកន្សោមពាក្យ

### ៤.២.១- មុខងារនៃពាក្យឬកន្សោមពាក្យក្នុងកន្សោមនាមប្រធាន

**ក- គុណបទ, ឧទាហរណ៍ :**

- មនុស្សល្អតែងតែរស់នៅដោយសុខសាន្តជាមួយអ្នកជិតខាង( *ល្អ* ជាគុណបទនៃ *មនុស្ស*)។
- ឡានថ្មីនេះ ទិញពីឃ្លាំងកាលពីម្សិលមិញ( *ថ្មី* ជាគុណបទនៃ *ឡាន*)។

**ខ- កម្មរបស់នាម, ឧទាហរណ៍ :**

- ផ្ទះរបស់ខ្ញុំ សង់ពីឈើ( *របស់ខ្ញុំ* ជាកម្មរបស់ *ផ្ទះ*)។
- ប្រជាជននៃប្រទេសកម្ពុជា ភាគច្រើនប្រកបមុខរបរកសិកម្ម( *នៃប្រទេសកម្ពុជា* ជាកម្មរបស់ *ប្រជាជន*)។

**គ- ឧបបទ, ឧ.** បងសំ កសិករឆ្នើម ក្លាយជាប្រធានភូមិ( *កសិករឆ្នើម* ជាឧបបទរបស់ *បងសំ*)។

### ៤.២.២- មុខងារនៃពាក្យឬកន្សោមពាក្យក្នុងកន្សោមកិរិយាប្រណាប់ប្រធាន

**ក- កម្មបទផ្ទាល់, ឧទាហរណ៍ :**

- គាត់បានទិញសៀវភៅមួយក្បាល( *សៀវភៅមួយក្បាល* ជាកម្មបទផ្ទាល់របស់

របស់កិរិយាសព្ទ *ទិញ*)។

- ចាបស៊ីស្រូវ( *ស្រូវ* ជាកម្មបទផ្ទាល់របស់កិរិយាសព្ទ *ស៊ី*)។

**ខ- កម្មបទមិនផ្ទាល់, ឧទាហរណ៍ :**

- ខ្ញុំនឹកដល់ស្រុកកំណើតខ្ញុំ ( *ដល់ស្រុកកំណើតខ្ញុំ* ជាកម្មបទមិនផ្ទាល់របស់កិរិយាសព្ទ *នឹក*)។

- គាត់និយាយពីការប្រមូលផល( *ពីការប្រមូលផល* ជាកម្មបទមិនផ្ទាល់របស់កិរិយាសព្ទ *និយាយ*)។

**គ- កម្មភ្នាក់ងារ, ឧ.** ស្រូវពូសយត្រូវបានបំផ្លាញដោយសត្វល្អិត ( *ដោយសត្វល្អិត* ជាកម្មភ្នាក់ងារនៃកន្សោមកិរិយា *ត្រូវបានបំផ្លាញ ដែលមានទម្រង់ជាកម្មវាចកៈ*)។

**ឃ- គុណប្រធាន, ឧទាហរណ៍** :

- ចៅសេង ជាសិស្សឆ្នើម( *សិស្សឆ្នើម* ជាគុណប្រធានរបស់ *ចៅសេង*)។

- ផ្ទះនេះ ធំ[៤៤]ណាស់( *ធំ* គុណនាមកិរិយា គឺជាកិរិយាសព្ទមួយបែប ដែលមិនធ្វើអំពើដូចកិរិយាសកម្មឬកិរិយាអកម្មទេ វាផ្តល់លក្ខណៈឱ្យ *ផ្ទះ* ដែលជាប្រធាន : ដូច្នេះវាជាគុណប្រធាន )។

<u>កំណត់សម្គាល់</u> : *ធំ* ក្នុងឈ្មោះ *ផ្ទះនេះធំណាស់* មានមុខងារប្លែកពី *ធំ* ក្នុងឈ្មោះ *ផ្ទះធំនេះ ជារបស់ពូសុក*។

### ៤.២.៣- មុខងារកន្សោមមានធ្នាក់ ឯករាជ្យពីកន្សោមកិរិយាប្រណាប់ប្រធាន

កន្សោមមានធ្នាក់នេះ មានមុខងារជាកម្មទេសកាល, ឧទាហរណ៍ :

- ខ្ញុំដេកលើគ្រែ( *លើគ្រែ* ជាកម្មទេសកាលរបស់ឈ្មោះ *ខ្ញុំដេក*)។

---

[៤៤] តាមលោកគ្រូ សូ មុយឃៀង លោកយល់ថា *ធំ* ជាគុណនាមកិរិយាដែលជាកិរិយាគោលនៃកន្សោមកិរិយាប្រណាប់ប្រធាន *ធំណាស់*។

- ពូសយដាំដំណាំក្បែរមាត់បឹង ( *ក្បែរមាត់បឹង* ជាកម្មទេសកាលរបស់ល្បះ *ពូសយដាំដំណាំ*)។

<u>កំណាត់សម្គាល់</u> : កន្សោមមានធ្នាក់កម្មទេសកាល អាចជាពាក្យទោល, ឧ. ស្អែក ខ្ញុំនឹងទៅលេងកែប (*ស្អែក* ជាកម្មទេសកាលរបស់ល្បះ *ខ្ញុំនឹងទៅលេងកែប*)។

## II- សញ្ញាល្បះ

សញ្ញាដែលគេប្រើក្នុងល្បះ។ សញ្ញាល្បះមានៈ

### ១- សញ្ញាខណ្ឌ(។ )

គេប្រើសញ្ញានេះនៅចុងបញ្ចប់នៃល្បះប្រកាសឬនៅចុងបញ្ចប់នៃវគ្គរបស់កំណាព្យ, ឧទាហរណ៍ :

- អូនកុំនិយាយយ៉ាងនេះនាំឱ្យបាបនឹងទេវតា[៥៥]។
- នរូអ្នកណា នឹងស្វែងប្រាជ្ញា ឱយបានខ្លួនថ្លៃ

  ចូរដឹងខុសគាប់ ដោយអធ្យាស្រ័យ ផ្តាប់ដោយហឫទ័យ អ្នកជាបាធ្យាយ[៥៦]។

### ២- សញ្ញាខណ្ឌចប់ (៕)

គេប្រើសញ្ញានេះ សម្រាប់បញ្ចប់អត្ថបទ។

### ៣- ដកឃ្លាឬដំណកឃ្លា

ដកឃ្លាឬដំណកឃ្លាជាគម្លាតឬចន្លោះរវាងពាក្យពីរម៉ាត់ឬកន្សោមពាក្យពីរកន្សោម។ ដោយខ្មែរយើងសរសេរមិនដកឃ្លាពីពាក្យមួយទៅពាក្យមួយ បុព្វបុរសយើងប្រើដំណកឃ្លាក្នុងករណីមួយចំនួន។ គោលបំណងនៃការប្រើដំណកឃ្លាគឺចង់ឱ្យពាក្យឬកន្សោមពាក្យក្នុងករណីជាក់លាក់មួយចំនួនលេចថ្កោលឡើង ដើម្បីឱ្យងាយយល់។ ពិតមែនតែនៅមានការស្ទាក់ស្ទើរ

---

[៥៥] ឧទាហរណ៍ខ្ទីពី នូ ហាច រឿងផ្កាស្រពោន, បោះពុម្ពដោយអគារបោះពុម្ពផ្សាយវប្បធម៌, ឆ្នាំ១៩៦០, ទំ.៤២។

[៥៦] ឧទាហរណ៍ខ្ទីពី ច្បាប់ក្រម ក្នុងសៀវភៅច្បាប់ផ្សេងៗ បោះពុម្ពផ្សាយដោយពុទ្ធសាសនបណ្ឌិត្យ ព.ស. ២៥៣៩, ទំ.០៤។

បន្តិចបន្តួច ប៉ុន្តែ ជាទូទៅអ្នកអក្សរសាស្ត្រ ខ្មែរបានប្រើដំណកឃ្លាសមស្របតាមលក្ខណៈសម្ព័ន្ធរបស់ល្បះ។ គេដកឃ្លា៖

(១) - នៅចន្លោះពាក្យឬកន្សោមពាក្យដែលមានមុខងារដូចគ្នា, ឧ. សត្វពាហនៈមាន គោ ក្របី សេះ ដំរី ។ល។

(២)- នៅខាងស្តាំសញ្ញាខណ្ឌ, ឧ. *កាយវិញ្ញាណ* សេចក្តីដឹងច្បាស់នូវអារម្មណ៍តាមទ្វារកាយ គឺកាយជាតុនិងផោដ្ឋព្វជាតុដែលមានការប៉ះទង្គិចគ្នានាំឱ្យកើតសេចក្តីដឹងឡើង។ *កាយវិវេក* សេចក្តីស្ងប់ស្ងាត់នៃកាយ(ម.ព.*វិវេក*)[៤៧]។

(៣)- នៅចន្លោះនាមត្រកូលនិងនាមខ្លួននៃឈ្មោះមនុស្ស ព្រមទាំងនៅខាងឆ្វេងនិងខាងស្តាំនៃឈ្មោះទាំងមូល, ឧ. លោក តន់ ព្រឿង, លោក ស៊ុន ម៉េងស្រ៊ុន អធិការនគរបាលជាតិ, លោក កិម ធុក និង លោក ក្លូង ភិន នាយត្រួតនគរបាលជាតិ បានជួយឧបត្ថម្ភដោយពុំញញើត(...)[៤៨]។

<u>សង្កេត</u> : ដូចមានចែងខាងលើ យើងបានឃើញថា ការប្រើដំណកឃ្លាត្រូវគោរពតាមគោលការណ៍ពីរប្រការ គឺ ចង់ឱ្យពាក្យឬកន្សោមពាក្យលេចធ្លោលឡើងផង និង ឱ្យស្របតាមលក្ខណៈសម្ព័ន្ធក្នុងល្បះផង ប៉ុន្តែ ចំណុច(៣) ខាងលើនេះជាការលើកលែង ពីព្រោះគោលការណ៍តែមួយ(លើគោលការណ៍ពីរ) ត្រូវបានទទួលការអនុវត្ត។

**៤- បេយ្យាលៈ( ។ល។ ) (ដែលគេតែងតែអានសង្ខេបថា "ល៉ៈ")**

គេប្រើសញ្ញានេះសម្រាប់ប្រាប់ថា ពាក្យឬសេចក្តីដែលគេបានរៀបរាប់នោះមិនទាន់ចប់ទេ នៅមានតទៅទៀត, ឧទាហរណ៍ :

- ប្រទេសកម្ពុជាមានរាជធានី ខេត្ត ចំនួន២៥ គឺ រាជធានីភ្នំពេញ ខេត្តកណ្តាល ខេត្តកំពង់ស្ពឺ ខេត្តតាកែវ។ល។
- សត្វពាហនៈមាន គោ ក្របី សេះ។ល។

<u>កំណត់សម្គាល់</u> : អ្នកខ្លះប្រើ«ល៉ៈ» ដូចនេះ «-ល-»។

**៥-ដំពីរ( ៖ )**

គេប្រើដំពីរដើម្បី៖

---

[៤៧] វចនានុក្រមខ្មែរ, ដ.ឯ.ម. ("កាយ")។

[៤៨] ឧទាហរណ៍ខ្ចីពី ស៊ីសុវត្ថិ ប៉ូរក្ខស៊ី, *បរិភាសព្ទក្នុងភាសាខ្មែរ*, សមាគមសម្តេច ជួន ណាត, ឆ្នាំ១៩៧៣, ទំព័រ គ។

(១)- រៀបរាប់, ឧ. គណៈកម្មការបានប្រឹក្សាយ៉ាងយូរ ក៏មូលមតិគ្នាជាឯកច្ឆន្ទ ដូចរាយខាងក្រោមនេះ៖

ខ១-(...)

ខ២-(...)[៤៩]។

(២)- ប្រើនៅក្នុងកថាផ្ទាល់, ឧ. គាត់និយាយ៖«ខ្ញុំមិនសុខចិត្តទេ»។

**៦- រង្វះសញ្ញាឬគំនូស ( - )**

គេប្រើសញ្ញានេះ ដើម្បី៖

ក- សម្រាប់តម្រៀបអ្វីៗដែលគេរាប់ ដើម្បីឱ្យអ្វីៗនោះលេចធ្លោលឡើង(ផ្ទុយពីការរាប់បន្តៗគ្នាតាមបន្ទាត់តែមួយ)។ គេប្រើរង្វះសញ្ញាបន្ទាប់ពីមានជំពីរ, ឧទាហរណ៍ :

ព្រហ្មញ្ញសាសនា គោរពព្រះអាទិទេព៣ព្រះអង្គ៖

- ព្រះវិស្ណុ
- ព្រះសិវៈ
- ព្រះព្រហ្ម[៥០]។

ខ- សម្រាប់ដាក់ក្រោយលេខរៀង, ឧទាហរណ៍ :

ក្រុមជំនុំ

១- សម្តេចព្រះរាជអយ្យកោ វរចក្ររណឫទ្ធិ សុជាតេ (កាលនៅក្នុងឋានៈជាព្រះអង្គម្ចាស់);

២- សម្តេចក្រុមព្រះ ភាណុវង្ស (កាលនៅក្នុងឋានៈជាព្រះអង្គម្ចាស់);

៣- ព្រះវនរ័ត ចន្ទ (វត្តឧណ្ណាលោម ក្រុងភ្នំពេញ);

(...)[៥១]។

[៤៩] ឧទាហរណ៍ខ្ចីពីវចនានុក្រមខ្មែរ, ដ.ឯ.ម. ត្រង់និទាន ទំព័រ ក។

[៥០] ឧទាហរណ៍ខ្ចីពី មៀច ប៉ុណ្ណ កម្រងឯកសារស្តីពីប្រពៃណីនិងទំនៀមទំលាប់ខ្មែរ ពុទ្ធសាសនបណ្ឌិត្យ គ.ស.១៩៩៩ ទំ.៥១។

[៥១] ឧទាហរណ៍ខ្ចីពី វចនានុក្រមខ្មែរ ដ.ឯ.ម ទំព័រ ត។

គ- សម្រាប់បង្ហាញការឆ្លើយឆ្លងគ្នា, ឧទាហរណ៍ :

- នាងអញ្ជើញនៅពិសាបាយនឹងខ្ញុំនេះហើយ ។

- ចាំសចៃ កុំព្រួយ, ខ្ញុំមានការបន្ទាន់បន្តិច[៩២]។

ឃ- សម្គាល់ន័យថា រហូតដល់, ឧ. ទស្សនាវដ្តី ឥន្ទ្រទេវី លេខ៣១ ថ្ងៃ ២៥ ធ្នូ ១៩៩៩-១០ មករា ២០០០។

ង- ក្នុងវេយ្យាករណ៍ សម្រាប់បញ្ជាក់ពីប្រភេទផ្នត់ (ផ្នត់ដើម ផ្នត់ដែក), ឧទាហរណ៍ :

- ផ្នត់ដើម [ប៉-](ប៉្តឹង <ដឹង), ផ្នត់ដើម [រ-](របេក <បក)។

- ផ្នត់ដែក [-ន-](ឃ្នាប <គាប), ផ្នត់ដែក [-ម-](ធ្មាំ <ចាំ)។

## ៧- វង់ក្រចក (( ))

គេប្រើវង់ក្រចកដើម្បីប្រាប់ព័ត៌មានបញ្ជាក់ឬបន្ថែមអំពីអ្វីដែលគេទើបនិយាយរួច, ឧ. ព្រះបាទភវវរ្ម័នទី១(គ.ស.៥៥០-៦០០)។

## ៨- ចំណុចមួយ (.)

គេប្រើសញ្ញានេះជាមួយអក្សរកាត់, ឧទាហរណ៍ :

- ន.(នាម)
- គុ.(គុណនាម)
- ឧ.(ឧទាហរណ៍)
- គ.ជ.ប.(គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត)។ល។

## ៩- ចំណុចពីរ(:)

គេប្រើសញ្ញានេះដើម្បីបែងចែកប្លង់វាទកម្មពីរផ្សេងគ្នា, ឧទាហរណ៍ :

---

[៩២] ឧទាហរណ៍ខ្ចីពី នូ ហាច រឿងផ្កាស្រពោន ដ.ង.ម. ទំព័រ៦៨។

| ព្រះរាជាណាចក្រកម្ពុជា |
|---|
| ទីស្ដីការគណៈរដ្ឋមន្ត្រី ជាតិ សាសនា ព្រះមហាក្សត្រ |
| ក្រុមប្រឹក្សាជាតិភាសាខ្មែរ |
| លេខ : |
| **សូមគោរពជូន** |
| កម្មវត្ថុ : |
| យោង : |

- តារា : តើអូនទៅណា ?
- ទេវី : ខ្ញុំទៅផ្សារ។

**១០- ចំណុចបី (...)**

គេប្រើសញ្ញានេះដើម្បីបញ្ជាក់ថាអាចនៅមានធាតុដែលត្រូវរៀបរាប់បន្តទៅទៀត, ឧ. ឫស្សីស្រុក ឫស្សីរលៀក ឫស្សីគ្រាច់ ឫស្សីឃ្លៃ ឫស្សីថ្ង ឫស្សីទ្រនំមាន់ ...។

**១១- ចំណុចបីក្នុងវង់ក្រចក( (...) )**

សញ្ញានេះប្រើសម្រាប់ជំនួសសេចក្ដីដែលអ្នកនិពន្ធមិនស្រង់យក, ឧ. លោកអគ្គលេខាធិការនៃពុទ្ធសាសនបណ្ឌិត្យ បានសុំព្រះសាសនមុនី កិម-តូរ(ចន្ទមង្គលោ)សមាជិកក្រុមជំនុំព្រះត្រៃបិដក(...)ឱ្យទទួលបំពេញមុខការនេះ, (...)(វចនានុក្រមខ្មែរ និវេទនកថា, ទំព័រ ជ)[៩៣] ។

**១២- ក្បៀស (,)**

គេប្រើក្បៀស ក្នុងករណីដែលមានដំណាកឃ្លាច្រើនកន្លែង ដើម្បីចៀសវាងកុំឱ្យច្រឡំត្រង់កន្លែងណាមួយ ក្នុងការភ្ជាប់ពាក្យនិងពាក្យ ឬ កន្សោមនិងកន្សោម, ឧទាហរណ៍ :

[៩៣] ព្រុំ ម៉ល់, ពិនិត្យពិចារណាលើការប្រើប្រាស់សញ្ញាប្រយោគមួយចំនួន ក្នុងភាសាខ្មែរបច្ចុប្បន្ន, សន្និសីទជាតិស្ដីពីការសិក្សាស្រាវជ្រាវឯកភាព និង អភិវឌ្ឍន៍ភាសាខ្មែរ លើកទី២ ថ្ងៃទី១៨ ខែតុលា ឆ្នាំ២០០៥ រៀបចំដោយវិទ្យាស្ថានភាសាជាតិនៃរាជបណ្ឌិត្យសភាកម្ពុជា ទំព័រ៦។

- ខ្ញុំបានចាប់ផ្តើមកិច្ចអភិវឌ្ឍន៍ ដោយបានបបួលបងប្អូនអ្នកភូមិលុបផ្លូវរទេះគោ លើកដីឱ្យខ្ពស់ឱ្យក្លាយទៅជាផ្លូវលំ ចាប់ពីផ្លូវរដ្ឋ, ផ្លូវរដ្ឋពីវត្តឈើទាលទៅកំពង់ជ្រៃ, ចូលទៅភូមិធ្នង់(...)[៥៤]។

- ក្នុងសិលាចារឹក ខ្មែរបុរាណច្រើនប្រើ ៸ពេញតួ, សម្រាប់ប្រើដាក់លើអក្សរចុង[៥៥] ដើម្បីធ្វើអក្សរតួដើម បន្ទាប់នោះឱ្យមានសូរសំឡេងញ័រ, ប្រើចំពោះតែភាសាសំស្ក្រឹតឬសំស្ក្រឹតក្លាយ, ដូចជា គ័ភ៌,ទុគ៌ត, ទុព៌ល, ធម៌, បព៌ត, ព័ណ៌, ធម៌អាថ៌ ជាដើម[៥៦]។

**១៣- សញ្ញាសួរ(?)**

គេប្រើសញ្ញានេះនៅចុងបញ្ចប់នៃឈ្នះសំណួរ, ឧ. បង! យីបង មកពីកាលណាហ្នឹង?[៥៧]

**១៤- សញ្ញាឧទាន (!)**

សញ្ញានេះប្រើនៅខាងចុងពាក្យឧទាននិងនៅចុងបញ្ចប់នៃឈ្នះឧទាន, ឧទាហរណ៍ :

- ឈប់ពីរខែ, ជយោ![៥៨]

- ឱវាលស្រែនេះ! ដូរដងអូរនេះ! ឱ! ត្រដោកហ្វូងគោក្របីដែលស៊ីស្មៅព្រាតនេះ![៥៩]

**១៥- អព្ភន្តរៈ(«»)**

គេប្រើសញ្ញានេះ ដើម្បីៈ

**ក-** បង្ហាញសម្តីរបស់នរណាម្នាក់ដែលគេដកស្រង់, ឧទាហរណ៍ :

---

[៥៤] ព្រុំ ម៉ល់ ព្រឹត្តិបត្រព័ត៌មាននៃសមាគមអភិវឌ្ឍន៍ភូមិធ្នង់ លេខ១ បោះផ្សាយដោយអ្នកនិពន្ធ, ទំព័រ១។

[៥៥] ដោយយើងគ្មានលទ្ធភាពដាក់អក្សរ ៸ពេញតួលើតួអក្សរឯទៀត សូមសាធារណជនជ្រាបថា គឺនៅកន្លែងដែលមានសញ្ញារបាទនេះហើយ ដែលខ្មែរបុរាណដាក់អក្សរ ៸ពេញតួ។

[៥៦] សេចក្តីដកស្រង់ចេញពីការពន្យល់ពាក្យ «របាទ» នៅក្នុងវចនានុក្រមខ្មែរ ជ.ឯ.ម។

[៥៧] ឧទាហរណ៍ខ្ចីពី នូហាច ដ.ឯ.ម. ទំព័រ៤២។

[៥៨] -ដ-, ទំព័រ៤។

[៥៩] -ដ-, ទំព័រ៥។

- ថ្ងៃនោះឯង នាងបានហៅសំឡាញ់នាងជាល្បែងថា «បងប៉ូលៗ»[៦០];

- ចំណែកលោក ម៉ូរីស ហ្គ្រេវីស (Maurice Grevisse) បានសរសេរថា«នាម គឺជាពាក្យសម្រាប់សម្តែងពី មនុស្ស សត្វ វត្ថុ និង គំនិត»[៦១]។

**ខ-** បង្ហាញចំណងជើងឬឈ្មោះសៀវភៅឬសារព័ត៌មាន, ឧទាហរណ៍ :

- នាងនឹកឃើញកាលដែលប៊ុន-ធឿននិទានរឿង«ប៉ូលនឹងវៀហ្ស៊ីនី»ប្រាប់នាង[៦២];

- នៅឆ្នាំ១៩៤៧ គេបានយករឿងរបស់លោកទៅចុះផ្សាយនៅក្នុង«កាសែតកម្ពុជា»រាល់ថ្ងៃសៅរ៍ តាំងពីថ្ងៃទី១៩ កក្កដា រហូតដល់ថ្ងៃ ២៧ កញ្ញា ទើបចប់[៦៣]។

**គ-** សម្គាល់ក្នុងវេយ្យាករណ៍ថា ពាក្យដែលគេដាក់ក្នុងអព្ភន្តរៈជាពាក្យដែលគេចង់ពន្យល់, ឧ. «លើ»ឬ«ក្រោម» ជាធ្នាក់។

**ឃ-** សម្គាល់ពាក្យថ្មីដែលតាមរយៈសញ្ញានេះ អ្នកប្រើហាក់បីដូចជាសុំសេចក្តីអនុគ្រោះ, ឧ. ដើម្បីសិក្សាពីភាសាជនជាតិភាគតិច អ្នកស្រាវជ្រាវត្រូវការ «អ្នកបម្រាប់»[៦៤] ពីរនាក់។

**១៦-គំនូសទ្រេត( / )**

គេប្រើសញ្ញានេះ ដើម្បី៖

**ក-** ចុះលេខក្នុងច្បាប់ផ្សេងៗ, ឧទាហរណ៍ :

-ព្រះរាជក្រមលេខ នស រកម ០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ស្តីពី

---

[៦០] ឧទាហរណ៍ខ្ចីពី នូហាច ដ.ឯ.ម., ទំព័រ២៥។

[៦១]- ប៊ី សុខគង់, ប្រភេទពាក្យក្នុងភាសាខ្មែរទំនើប, សារណាបញ្ចប់ថ្នាក់បរិញ្ញាប័ត្រជាន់ខ្ពស់នៅរាជបណ្ឌិត្យសភាកម្ពុជា ឆ្នាំ២០០២ ទំព័រ៣៧។

[៦២] ឧទាហរណ៍ខ្ចីពី នូ ហាច ដ.ឯ.ម. ទំព័រ២៥។

[៦៣] ឧទាហរណ៍ខ្ចីពី នូ ហាច ដ.ឯ.ម. ទំព័រ, ទំព័រ ក។

[៦៤] «អ្នកបម្រាប់» ត្រូវបានបង្កើតឡើងដោយផ្គុំ «បម្រាប់» (ដែលមានស្រាប់ក្នុងវចនានុក្រម) ជាមួយនឹង «អ្នក» : «អ្នកបម្រាប់» មានលំនាំដូច «អ្នកជំនួញ/អ្នកជំនិត/អ្នកជំងឺ»។

ការបង្កើតក្រសួងមហាផ្ទៃ[៦៥];

- ព្រះរាជក្រឹត្យលេខ នស/រកត ១២៩៧-៩១ ចុះថ្ងៃទី ៣១-១២-៩៧ ស្តីពីលក្ខន្តិកៈ គតិយុត្តិនៃគ្រឹះស្ថានសាធារណៈរដ្ឋបាល[៦៦];

**ខ-** ជំនួសឈ្នាប់ "ឬ", ឧទាហរណ៍ :

- តាវកាលិក Eng. Prestation / Performance Fr. Prestation (...)[៦៧]

- តុលាការ Eng. court Fr. Juridiction / Tribunal (...)[៦៨]។

*កំណាត់សម្គាល់* : សញ្ញាបន្ទាត់ទ្រេតអាចប្រើសម្គាល់ប្រភាគ, ខ្ញ. ១/២, ១/៣, ១/៤, ...។

## III- សញ្ញាក្រៅល្បះ

សញ្ញាក្រៅល្បះមួយចំនួន មានដូចជាៈ

### ១- សញ្ញាស្មើ (=)

គេប្រើសញ្ញានេះ ដើម្បីសម្គាល់ន័យថា «ស្មើឬមានន័យថា»ៈ

**ក-** ក្នុងអក្សរសាស្ត្រ សញ្ញានេះសម្គាល់ន័យថា «មានន័យថា», ឧទាហរណ៍ :

- វប្ប = ការសាបព្រោះ ការបណ្ដុះពូជ ការបង្កបង្កើត ...។

- ធម៌ = ធាតុ វិធី ធម៌ភាព សភាវៈទ្រទ្រង់ ...[៦៩]។

**ខ-** ក្នុងគណិតវិទ្យា សញ្ញានេះសម្គាល់ន័យថា «ត្រូវជាឬស្មើ», ឧ. ១ + ៦ = ៧ ។

---

[៦៥] កៅ មុយថង ការគ្រប់គ្រងរដ្ឋបាល វិទ្យាស្ថានអន្តរជាតិនៃកម្ពុជា ២០០៥, ទំព័រ១៦៤ ។

[៦៦] កៅ មុយថង, ដ.ឯ.ម. ទំព័រដដែល។

[៦៧] សទ្ទានុក្រមពាក្យច្បាប់ ភាគ១, គណៈកម្មការបណ្ឌិតសភាទទួលបន្ទុកអនុម័តពាក្យច្បាប់នៃទីស្តីការគណៈរដ្ឋមន្ត្រី, ទំព័រ៧។

[៦៨] -ដ-, ទំព័រដដែល។

[៦៩] អ្នកស្រី ត្រឹង ងា *អរិយធម៌ខ្មែរ ថ្នាក់បញ្ចប់* ការផ្សាយរបស់អ្នកនិពន្ធ, ១៩៧៤ ទំព័រ១២។

**២- សញ្ញា «ទៅជាឬធំជាង» (>)**

គេប្រើសញ្ញានេះ ដើម្បី៖

**ក-** ក្នុងអក្សរសាស្ត្រ សញ្ញានេះសម្គាល់ន័យថា «ទៅជា គឺ ក្លាយទៅជាឬប្រែទៅជា», ឧទាហរណ៍ :

- ដេក + [ប៉-] > ផ្ដេក
- រុក + [-ន-] > រ្នុក > រនុក។

**ខ-** ក្នុងគណិតវិទ្យា សញ្ញានេះសម្គាល់ន័យថា «ធំជាង» គឺ ចំនួនឬលទ្ធផលគណនាចំនួននៅខាងឆ្វេងធំជាងចំនួនឬលទ្ធផលគណនាចំនួន ដែលនៅខាងស្ដាំសញ្ញានេះ, ឧ. ៥ + ៧ > ១០។

<u>សង្កេត</u> : ក្នុងចំណុច ក គេអាចប្រើសញ្ញាព្រួញ (→) ជំនួសសញ្ញា «ទៅជា» ក៏បានដែរ : ដេក + [ប៉-] → ផ្ដេក។

**៣- សញ្ញា «មកពីឬតូចជាង» (<)**

គេប្រើសញ្ញានេះ ដើម្បី៖

**ក-** ក្នុងអក្សរសាស្ត្រ សញ្ញានេះសម្គាល់ន័យថា «មកពី» គឺពាក្យ ឬ កន្សោមពាក្យ ឬ ល្បះនៅខាងឆ្វេងសញ្ញានេះបានមកពីពាក្យ ឬ កន្សោមពាក្យ ឬ ល្បះដែលនៅខាងស្ដាំសញ្ញានេះ, ឧ. វប្បធម៌ < វប្ប + ធម៌[៣០]។

**ខ-** ក្នុងគណិតវិទ្យា សញ្ញានេះសម្គាល់ន័យថា « ចំនួនឬលទ្ធផលគណនាចំនួននៅខាងឆ្វេងតូចជាងចំនួន ឬ លទ្ធផលគណនាចំនួននៅខាងស្ដាំ», ឧ. ៥ + ៧ < ១៥។

<u>សង្កេត</u> : ក្នុងចំណុច ក នៃការប្រើសញ្ញា «មកពី» គេអាចប្រើសញ្ញាព្រួញ (←) ក៏បាន : វប្បធម៌ ← វប្ប + ធម៌។

**៤- សញ្ញា«ផ្ទុយពី ... ឬ ខុសពី ...»(≠)**

គេប្រើសញ្ញានេះ ដើម្បីសម្គាល់ន័យថា ពាក្យនៅខាងឆ្វេងមានន័យផ្ទុយឬខុសពីពាក្យនៅខាងស្ដាំ, ឧ. ទាប ≠ ខ្ពស់, ល្អ ≠ អាក្រក់ ...។

---

[៣០] អ្នកស្រី ត្រឹង ងា, ដ.ឯ.ម. ទំព័រដដែល។

<u>កំណត់សម្គាល់</u> :  មិនត្រូវប្រើសញ្ញាទាំងនេះ (=) (>) (<) និង (≠) ជំនួសពាក្យ *ស្មើ ទៅជា មកពី* និង *ផ្ទុយពី/ខុសពី* នៅក្នុងល្បះឡើយ។

# គន្ថនិទ្ទេស

## ១- ភាសាខ្មែរ


- គឹម កែវកល្យាណ, កិរិយាសព្ទក្នុងភាសាខ្មែរបច្ចុប្បន្ន, សារណាបញ្ចប់បរិញ្ញាប័ត្រជាន់ខ្ពស់ មុខជំនាញភាសាវិទ្យា ជំនាន់ទី១ រាជបណ្ឌិត្យសភាកម្ពុជា ភ្នំពេញ, ២០០២។
- កេង វ៉ាន់សាក់, មូលភាពនៃការបង្កើតពាក្យថ្មី, ភាគទី១, ភ្នំពេញ, ១៩៦៣។
- កេង វ៉ាន់សាក់, សូរស័ទ្ទខ្មែរ, ភ្នំពេញ, ១៩៦៦។
- ក្រសួងអប់រំ, វេយ្យាករណ៍ ថ្នាក់ទី៥, រោងពុម្ពរណសិរ្ស, ភ្នំពេញ, ១៩៨៣។
- ក្រសួងអប់រំ, វេយ្យាករណ៍ ថ្នាក់ទី៦, រោងពុម្ពរណសិរ្ស, ភ្នំពេញ, ១៩៨២។
- ក្រសួងអប់រំ, វេយ្យាករណ៍ ថ្នាក់ទី៧, រោងពុម្ពរណសិរ្ស, ភ្នំពេញ, ១៩៨៣។
- ក្រសួងអប់រំ, វេយ្យាករណ៍ ថ្នាក់ទី៨, គ្រឹះស្ថានបោះពុម្ពផ្សាយអប់រំ, ភ្នំពេញ, ១៩៨៦។
- ខៀវ ជុំ (ភិក្ខុ ធម្មបាលោ), វេយ្យាករណ៍យើង សម្រាប់បឋមសិក្សា បឋមភូមិ អាទិកង្វាន, ផ្សាយដោយ ទៀន ហុងសេង, ភ្នំពេញ, ១៩៦៦។
- គឹម សែត, វេយ្យាករណ៍ទំនើបនិងវិធីសម្ព័ន្ធ, បណ្ណាគារវង់ស្មើ, កំពង់ចាម, ១៩៦៣។
- គុយ រិន, កិរិយាវិសេសន៍, សារណាបញ្ចប់បរិញ្ញាប័ត្រជាន់ខ្ពស់ មុខជំនាញភាសាវិទ្យា ជំនាន់ទី២ រាជបណ្ឌិត្យសភាកម្ពុជា ភ្នំពេញ, ២០០៣។
- ឃួន សុខម្ភូ, ទម្រង់សូរវិទ្យាខ្មែរ, មជ្ឈមណ្ឌលរកឯកសារនិងស្រាវជ្រាវ ផ្នែកភាសាវិទ្យាអនុវត្ត នៃមហាវិទ្យាល័យ អក្សរសាស្ត្រ និង មនុស្សសាស្ត្រ នាសាកលវិទ្យាល័យភ្នំពេញ, ១៩៧០។
- ច័ន្ទ សំណព្វ, សំណេរនិងអក្ខរាវិរុទ្ធខ្មែរ, រាជបណ្ឌិត្យសភាកម្ពុជា សាកលវិទ្យាល័យភូមិន្ទ ភ្នំពេញ, ហ្វូណន, ២០០៨។
- ច័ន្ទ សំណព្វ, យុគលពិន្ទុឬសញ្ញាចុចពីរ, ផ្សាយដោយអ្នកនិពន្ធ, ២០១០។
- ច័ន្ទ សំណព្វ, បង្កើតពាក្យ កម្ទីពាក្យ និងបម្រើបម្រាស់ពាក្យ, ផ្សាយដោយអ្នកនិពន្ធ, ២០១០។
- ច័ន្ទ សំណព្វ, ដំណាក់ឃ្លាក្នុងភាសាខ្មែរ, ផ្សាយដោយអ្នកនិពន្ធ, ២០១០។
- ជួរ គារី, អវិជ្ជមានន័យក្នុងភាសាខ្មែរ តាមរយៈអវិជ្ជមានបទនិងអវិជ្ជមានសព្ទមួយចំនួន(មិន ឥត កុំ គ្មាន អត់ ពុំ ..., ខុស អាក្រក់ ចាំតើ នាងល្អ ...), និក្ខេបបទថ្នាក់បណ្ឌិត មុខជំនាញ ភាសាវិទ្យា ជំនាន់ទី១ រាជបណ្ឌិត្យសភាកម្ពុជា, ភ្នំពេញ, ២០១១។

- ជុំ ស៊ុនណាង, បកតិគុណនាមក្នុងភាសាខ្មែរទំនើប, សារណាបញ្ចប់បរិញ្ញាប័ត្រជាន់ខ្ពស់ មុខជំនាញភាសាវិទ្យា ជំនាន់ទី២ រាជបណ្ឌិត្យសភាកម្ពុជា, ភ្នំពេញ, ២០០៣។
- ញ៉ុក នូវ (អ្នកឧកញ៉ាមហាមន្ត្រី), វេយ្យាករណ៍ខ្មែរ, រោងពុម្ពព្រះបរមរាជវាំង, ភ្នំពេញ, ១៩៥៩។
- ឌ. គាមមុនី, វេយ្យាករណ៍ខ្មែរ, រោងពុម្ព វ៉ាក់ វ៉ា, ភ្នំពេញ, ១៩៥៥។
- ធន់ ហ៊ិន, វេយ្យាករណ៍ខ្មែរ សម្រាប់គ្រប់ភូមិសិក្សា, ផ្សាយដោយអ្នកនិពន្ធ, ភ្នំពេញ, ២០១១។
- ប៊ី សុខគង់, ប្រភេទពាក្យក្នុងភាសាខ្មែរទំនើប, សារណាបញ្ចប់បរិញ្ញាប័ត្រជាន់ខ្ពស់ មុខជំនាញភាសាវិទ្យា ជំនាន់ទី១ រាជបណ្ឌិត្យសភាកម្ពុជា, ភ្នំពេញ, ២០០២។
- ប៊ី សុខគង់, កិរិយាសកម្មក្នុងភាសាខ្មែរទំនើប, និក្ខេបបទថ្នាក់បណ្ឌិត មុខជំនាញភាសាវិទ្យា ជំនាន់ទី១ រាជបណ្ឌិត្យសភាកម្ពុជា, ភ្នំពេញ, ២០១៣។
- ប៉ួយ វុទ្ធី, ការស្រាវជ្រាវអំពីសំនួនវោហារស័ព្ទនៃភាសាខ្មែរដែលមានកំណាកំណើតចេញពីបម្រើបម្រាស់វាក្យស័ព្ទសម្គាល់សរីរាង្គកាយមនុស្ស, សារណាបញ្ចប់បរិញ្ញាប័ត្រជាន់ខ្ពស់ មុខជំនាញភាសាវិទ្យា ជំនាន់ទី៤ រាជបណ្ឌិត្យសភាកម្ពុជា, ភ្នំពេញ, ២០០៦។
- ពូវ អ៊ុម, វេយ្យាករណ៍ខ្មែរសម្រាប់ថ្នាក់មធ្យមដ្ឋាន-ឧត្តមដ្ឋាន, បណ្ណាគារ គឹម សេង, ភ្នំពេញ, ១៩៥៨។
- ព្រុំ ម៉ល់, មូលដ្ឋាននៃសូរវិទ្យា សទ្ទតាវិទ្យា & វិជ្ជាសន្តាន ផ្សាយដោយអ្នកនិពន្ធ, ភ្នំពេញ, ២០០៣។
- ព្រុំ ម៉ល់, មូលដ្ឋាននៃន័យកម្មវិទ្យា, ផ្សាយដោយអ្នកនិពន្ធ, ភ្នំពេញ, ២០០៣។
- ព្រុំ ម៉ល់ និង អ្នកឯទៀត, វេយ្យាករណ៍ទម្រង់និយមនៃភាសាខ្មែរទំនើប ភាគទី១ : សូរ សទ្ទតា & អក្ខរាវិរុទ្ធ, ផ្សព្វផ្សាយដោយអ្នកនិពន្ធ, ភ្នំពេញ, ២០០៦។
- ព្រុំ ម៉ល់ និង អ្នកឯទៀត, វេយ្យាករណ៍ទម្រង់និយមនៃភាសាខ្មែរទំនើប ភាគទី២ : អំពីសព្ទ និងពាក្យ, ផ្សព្វផ្សាយដោយអ្នកនិពន្ធ, ភ្នំពេញ, ២០០៦។
- ព្រុំ ម៉ល់, អំពីសញ្ញាប្រយោគចម្រុងចម្រាសមួយចំនួនក្នុងភាសាខ្មែរបច្ចុប្បន្ន, ផ្សព្វផ្សាយដោយអ្នកនិពន្ធ, ភ្នំពេញ, ២០១២។
- ព្រុំ ម៉ល់, មូលដ្ឋាននៃសង្គមភាសាវិទ្យា, ផ្សាយដោយអ្នកនិពន្ធ, ចេញនៅខែកុម្ភៈ ឆ្នាំ២០០៣ កែសម្រួលនិងបង្គ្រប់បន្ថែម, ចេញនៅខែឧសភា ឆ្នាំ ២០១៣។

- ព្រំ ចន្ថា : ស័ព្ទតម្រាប់សូរ, សារណាបញ្ចប់បរិញ្ញាប័ត្រជាន់ខ្ពស់ មុខជំនាញភាសាវិទ្យា ជំនាន់ទី៣ រាជបណ្ឌិត្យសភាកម្ពុជា, ភ្នំពេញ, ២០០៤។
- មាឃ បូរ៉ា, ការស្រាវជ្រាវវេយ្យាករណ៍ភាសាខ្មែរបុរេអង្គរ,សារណាបញ្ចប់បរិញ្ញាប័ត្រជាន់ខ្ពស់ មុខជំនាញភាសាវិទ្យា ជំនាន់ទី១ រាជបណ្ឌិត្យសភាកម្ពុជា, ភ្នំពេញ, ២០០២។
- មាឃ បូរ៉ា, កម្មវាចកៈក្នុងភាសាខ្មែរ, និក្ខេបបទថ្នាក់បណ្ឌិត មុខជំនាញភាសាវិទ្យា ជំនាន់ទី១ រាជបណ្ឌិត្យសភាកម្ពុជា, ភ្នំពេញ, ២០១៣។
- វង្ស មេង, ពាក្យសមាសក្នុងភាសាខ្មែរទំនើប, សារណាបញ្ចប់បរិញ្ញាប័ត្រជាន់ខ្ពស់ មុខជំនាញភាសាវិទ្យា ជំនាន់ទី១ រាជបណ្ឌិត្យសភាកម្ពុជា, ភ្នំពេញ, ២០០២។
- វ៉ាន់ ម៉ូន, កន្សោមកិរិយាស័ព្ទក្នុងភាសាខ្មែរទំនើប, សារណាបញ្ចប់បរិញ្ញាប័ត្រជាន់ខ្ពស់ មុខជំនាញភាសាវិទ្យា ជំនាន់ទី៣ រាជបណ្ឌិត្យសភាកម្ពុជា, ភ្នំពេញ, ២០០៤។
- សូ មុយឃៀង & ថោង ធែល, វេយ្យាករណ៍ខ្មែរ, បណ្ណាគារ ពេជ្រនិល, ភ្នំពេញ, ១៩៧១-១៩៧២។
- សេ អឿន, ពាក្យកម្ចីសំស្ក្រឹត-បាលី ក្នុងភាសាខ្មែរទំនើប, សារណាបញ្ចប់បរិញ្ញាប័ត្រជាន់ខ្ពស់ មុខជំនាញភាសាវិទ្យា ជំនាន់ទី១ រាជបណ្ឌិត្យសភាកម្ពុជា, ភ្នំពេញ, ២០០២។
- ហ៊ុយ ឆេងរតនា, ការស្រាវជ្រាវអំពីប្រវត្តិកំណាកំណើតមុខងារនៃបុរិសសព្វនាមក្នុងភាសាខ្មែរ , សារណាបញ្ចប់បរិញ្ញាប័ត្រជាន់ខ្ពស់ មុខជំនាញភាសាវិទ្យា ជំនាន់ទី២ រាជបណ្ឌិត្យសភាកម្ពុជា, ភ្នំពេញ, ២០០៣។
- ឡុង សៀម, បញ្ហាវចនស័ព្ទវិទ្យាខ្មែរ, បោះផ្សាយដោយអ្នកនិពន្ធ, ភ្នំពេញ, ១៩៩៩។
- អ៊ឹង ម៉ាល័យ, អាយតនិបាតក្នុងភាសាខ្មែរបច្ចុប្បន្ន, សារណាបញ្ចប់បរិញ្ញាប័ត្រជាន់ខ្ពស់ មុខជំនាញភាសាវិទ្យា ជំនាន់ទី៣ រាជបណ្ឌិត្យសភាកម្ពុជា, ភ្នំពេញ, ២០០៤។
- អ៊ុក វិបុល, វេយ្យាករណ៍ខ្មែរទំនើប ថ្នាក់ទី១២, គ្រឹះស្ថានបោះពុម្ពនិងចែកផ្សាយរបស់ក្រសួង អប់រំ យុវជន និង កីឡា, ២០០១។
- អ៊ុយ ជួន, វេយ្យាករណ៍ពិសេស, រោងពុម្ព គីម គី, ភ្នំពេញ, ១៩៥៨។
- អៀវ កើស, ភាសាខ្មែរ, បណ្ណាគារ មិត្តសេរី, ភ្នំពេញ, ១៩៦៧។

## ២- ភាសាបរទេស

- Carton Femand, Introduction à la phonétique du français, Bordas, 1974;

- Chomsky Noam & Halle Morris, Principes de phonologie générative, Editions du Seuil, 1973;
-Chomsky Noam, La nouvelle syntaxe, Editions du Seuil, Paris, 1987;
- Chomsky Noam, Aspects de la théorie syntaxique, Editions du Seuil, Paris, 1971;
- Chomsky Noam, Structures syntaxiques, Editions du Point, Paris, 1969;
- Gorgoniyev Y. A., The Khmer Language, "Nauka" Publishing House, Central Department of Oriental Literature, Moscow, 1966;
- Grammont Maurice, Traité de phonétique, Delagrave, 1960;
- Gross Maurice, Méthodes en syntaxe, Hermann, 1975;
- Gross Maurice, Grammaire transformationnelle du français : Syntaxe du verbe, Larousse, 1968;
- Haudricourt André G., Thomas Jacqueline M. C., La notation des langues : Phonétique et phonologie, Institut géographique national, 1967;
- Huffman E. Franklin, Modern Spoken Cambodian, New Haven and London, 1970;
- Huffman E. Franklin, Cambodian System of Writing and Beginning Reader, New Haven and London, 1970;
- Jacob M. Judith, Introduction to Cambodian, Oxford University Press, London, 1968;
- Khin Sok, La grammaire du khmer moderne, You-Feng Librairie éditeur, Paris, 1999;
- Maspéro Georges, Grammaire de la langue khmère, sous le patronage de l'École Française d'Extrême-Orient, Paris, 1915;
- Malmerg Bertil, La phonétique, P. U. F. (Que sais-je ? ) , 1975;
- Malmerg Bertil, Les nouvelles tendances de la linguistique, P. U. F., 1966;
- Marchand F., La phonétique et ses applications, Delagrave, 1975;
- Martini François, Aperçu phonologique du cambodgien , BSL de Paris tome 42, fasc.1, numéro 124, 1942-1945, p.112-131.
- Troubetzkoy Nicolaï, Principes de phonologie, Editions Klincksieck, 1976;

**៣-វចនានុក្រម**

- តិប យក់ និង ថាវ គន្ធ, វចនានុក្រមបារាំង-ខ្មែរ សង្ខេប, បណ្ណាគារភ្នំពេញ៥៥ប៉ាស្ទ័រ, ភ្នំពេញ, ១៩៦៧។
- វចនានុក្រមខ្មែរ, ការផ្សាយរបស់ពុទ្ធសាសនបណ្ឌិត្យ, ភ្នំពេញ,១៩៦៧-១៩៦៨។
- Dubois Jean et alii, Dictionnaire de linguistique, Larousse, 1973;
- Jack C. Richards, Richard Schmidt, Longman Dictionary of Language Teaching & Applied Linguistics, Longman, Third Edition, 2002;

បោះពុម្ពលើកទី១ ចំនួន ២៦០០ ច្បាប់
នៅរោងពុម្ព ជី . អ៊ី . ធី . ប៊ីហ្សនេស
ផ្ទះលេខ 2320 ផ្លូវ45 សង្កាត់ ទួលសង្កែ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ